# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ២៧ ខែមេសា លេខ ៤

ព.ស. ២៤៩៧ – គ.ស. ១៩៥៥

A 6 26-5-5

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង


| | | |
|---|---|---|
| *ផ្នែកសាសនា* | | *ទំព័រ* |
| — វិបារណកថា . . . . . . . . . . . . . . | លោកប៊ូ-ប៉ូ . . . . . . . . . . . | ២៤៣ |
| — យោគលិចអំបែងអណ្ដែត . . . . . . . . . | ព្រះទេពសត្ថា កិម-តូ . . . . . | ២៥៣ |
| — បញ្ញាសជាតក ភាគទី ៣ (តមក) . . . . | បណ្ឌិតមហា ឈឹម -ស៊ុម . . . . | ២៦១ |
| *ផ្នែកអក្សរសាស្ត្រ* | | |
| — រឿងសៅរ៍សោយ (តមក) . . . . . . . . | ព្រះមហាឧត្ដមវិជ្ជា ប៊ុង—ប៉ម . . . | ២៦៩ |
| — រឿងសាមកុក (តមក) . . . . . . . . . . | ឧកញ៉ា នូ- កន . . . . . . . . . | ២៧៤ |
| — ដំណឹងតាមខ្យល់ក្នុងកន្ដារៈ (តមក) . . . | លោក ផេង - ដើរ . . . . . . . . | ២៨២ |
| — រឿងបល្ល័ង្កទិព្យ (តមក) . . . . . . . . . | លោក ភ៉ោយ- ប៊ុក . . . . . . . . | ២៨៨ |
| *កំណត់ទិនប្បវត្តិការណ៍* | | |
| — ពិធីចែកព្រហ្មទាន ដល់សមណនិស្សិត សាលាបាលីជាន់ខ្ពស់ . . . . . . . . . . | ពុទ្ធសាសនបណ្ឌិត្យ . . . . . . . | ២៩៥ |
| — ពិធីបុណ្យបូជាសពលោកគ្រូ ចិន - ទិត ចៅអធិការវត្តបឹងរៃខេត្តស្វាយរៀង . . . . | លោក ញ៉ែម - ទឹម . . . . . . . . | ៣១០ |
| — បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី (តមក) | ក្រសួងធម្មការ . . . . . . . . . . | ៣១៩ |


មួយឆ្នាំមាន ១២ សៀវភៅ — ថ្លៃជាវ ២០០រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## TABLE DES MATIÈRES


PARTIE RELIGIEUSE: Page

- Editorial . . . . . . . . . M. BOU-PO . . . . . . . . . 243
- Proverbe cambodgien . . . . Vén. KEM-TO . . . . . . . . 253
- Pannasajataka- vol.3 (suite) . M. CHHIM-SOUM . . . . . 261

PARTIE LITTERAIRE:

- Le «SAU SOY» ou l'influence saturnienne (suite) . . . . . Vén. PEUNG-PAM . . . . . 269
- Histoire de samkok (suite). . Oknha NOU-KAN . . . . . . 274
- Le souffle du désert (suite) . . M. PHENG-CHRIV . . . . . 282
- Les trente deux récits du Trône (suite) . . . . . . . . M. RAY-BUC . . . . . . . . . 288

NOTES ET CHRONIQUES:

- Distribution des prix à l'Ecole Supérieure de Pâli . . . . . . Institut Bouddhique . . . . . 295
- L'incinération du vén. CHEN-TIT, Chef de la pagode de Beng-Rai (Svay-Rieng) . . . . . . . . M. NHEM-KHEM . . . . . . 310
- Nomination des nouveaux Chau Adhikars (suite) . . . . . . . Ministère des Cultes . . . 319


Prix d'abonnement annuel (comprenant 12 numéros) 210$00

# ឃុនបណ្ណាគុរក្សប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ
## រៀបរៀង

## លោកមុខមានមែនឬទេ?(១)

លោកមុខ បើនិយាយតាមពុទ្ធសាសនា ថាលោកមុខមានមែន ព្រោះមានស្ថានសួគ៌, ស្ថាននរក; បើនិយាយតាមមតិនៃអ្នកប្រាជ្ញខាងពុទ្ធសាសនាថា ចាប់តាំងពីពេលផុតអស់ខ្យល់ដង្ហើមចេញចូល គឺស្លាប់ហៅថា លោកមុខ ៗ នានាជាតិក្នុងលោកច្រើនប្រកាន់ជឿថា លោកមុខមានមែន សឹងមានទំនៀមទម្លាប់ប្រព្រឹត្តជាប់មកជាភស្តុតាងស្រាប់ដូច :

ទំនៀមខ្មែរ, ខ្មែរប្រកាន់ជឿថាអ្នកស្លាប់ហើយត្រូវកើតទៀត ហើយត្រូវកាន់យកវត្ថុផ្សេងៗពីលោកនេះទៅប្រើប្រាស់ក្នុងលោកខាងមុខ ព្រោះតែជំនឿយ៉ាងនេះ ទើបគេយកវត្ថុសម្រាប់ប្រើប្រាស់នោះដាក់កប់ជាមួយនឹងរូបបុគ្គលដែលស្លាប់ហើយ ដូចជាកាលពីឆ្នាំមុន ពួកអ្នកជីកដីរុករកបុរាណវត្ថុក្នុងប្រទេសខ្មែរ គេជីកដីទៅត្រូវចំលើរណ្តៅខ្មោច, ក្នុងរណ្តៅនោះគេឃើញមានកាំបិត, ប៉ូវថៅ, ដាវ នឹងគ្រឿងប្រើប្រាស់ផ្សេងៗទៀតមានតុ ចាស ចាន ឆ្នាំងជាដើម ៗ ម្យ៉ាងទៀត តាមទំនៀមទម្លាប់ខ្មែរបុរាណ, ចំពោះមនុស្សចាស់ជរា កាលបើដឹងខ្លួនថាជិតស្លាប់ហើយ ច្រើនតែប្រាប់កូនចៅឲ្យរៀបចំគ្រឿងបន្ទុងទុកបុងឲ្យខ្លួនជាមុន បើដល់ខ្លួន

១ រៀបរៀងតាមប្រវត្តិរបស់នានាជាតិដែលមានសេចក្តីវិស្តារក្នុងច្បាប់ប្រវត្តិសាស្ត្រសាកល ។

ស្តាប់ហើយ ឲ្យកូនចៅនិមន្តព្រះសង្ឃមកទស់យកទៅ ដោយសំគាល់ថា របស់ទាំងនោះនឹងបានដល់ខ្លួនៗ នឹងប្រើប្រាស់នៅលោកមុខទៀត ។ ចំណែកកូនចៅ កាលជ្រើសយករបស់ដាក់បួង ច្រើនតែរើសយករបស់ដែលមិនធ្លាប់ប្រើប្រាស់. ធ្លាប់ស្រឡាញ់ ទឹងរបស់ដែលមានដំឡៃ ជូនកាលទិញរបស់ថ្មីៗ ពីផ្សារមកធ្វើជាបន្ទង់តែម្តង, ត្រៀមបន្ទង់នេះ អ្នកខ្លះនិមន្តព្រះសង្ឃទស់យកទៅកុដិ, អ្នកខ្លះដឹកដកប់ក្នុងផ្នូរសពនោះ ប៉ុន្តែមិនមែនមានដាក់គ្រប់តែរណ្តៅទេ ព្រោះរណ្តៅខ្លះគេដាក់ ខ្លះគេមិនដាក់ នេះទំនៀមខ្មែរ ។

ទំនៀមចិន, ព្រះរាជាធិរាជប្រទេសចិន កាលមុននឹងទិវង្គតទ្រង់បង្គាប់ឲ្យសាងម៉ុងទុកជាស្រេច លុះព្រះអង្គទិវង្គតហើយ អាមាត្យមុខមន្ត្រីយកព្រះរាជទ្រព្យដ៏មានដំឡៃទៅដំកល់ទុកថ្វាយក្នុងម៉ុង មិនតែប៉ុណ្ណោះ ថែមទាំងកប់ស្រីស្នំ ប្តីប្រុសស្រីជាទីសព្វព្រះរាជហឫទ័យទៅក្នុងរណ្តៅទាំងរស់ ដោយគាំងចិត្តថា ឲ្យទៅនៅចាំគាល់បំរើព្រះមហា-ក្សត្រក្នុងលោកមុខទៀត ។ ឯអ្នកដែលត្រូវគេដឹកកប់ទាំងរស់នោះក៏សុខចិត្តស្លាប់ ឥតធុញថប់ ឬឥតគេបង្ខិតបង្ខំចិត្តឡើយ ដ្បិតគេគាំងចិត្តថានឹងតបស្នងព្រះគេជៈព្រះគុណនៃព្រះមហាក្សត្ររបស់ខ្លួន ដែលរាប់ថាជាការធ្វើបុណ្យយ៉ាងច្រើនក្រៃលែង ។

មិនតែប៉ុណ្ណោះ ទំនៀមចិន មុននឹងកប់សពរបស់គេ បើជាអ្នកមានធនធានស្តុកស្តម្ភ គេរៀបចំតែងតួសពដូចជាមន្ត្រី ធ្វើម៉ុងល្អសមៀមណាស់ យកក្រដាសធ្វើជាប្រាក់សន្លឹក, ជារូបមនុស្សបំរើ, ជារូបផ្ទះ,

ជារូបយានពាហនៈ ទីងជាគ្រឿងប្រើប្រាស់ផ្សេងៗទៀត ប៉ុន្តែ វត្ថុទាំងនេះមិនកប់ជាមួយនឹងសពទេ គេដុតភ្លើងឲ្យឆេះទាំងអស់ ដោយតាំងចិត្តឧទ្ទិសបញ្ជូនទៅឲ្យអ្នកស្លាប់ទៅលោកមុខនោះ ។

ទំនៀមជប៉ុន, សម័យបុរាណ ជប៉ុនធ្វើព្រះរាជពិធីព្រះបរមសពនៃព្រះរាជាធិរាជជប៉ុន ដូចជាព្រះរាជាធិរាជចិនដែរ ។ គង់រដ្ឋកាលមួយនោះ មានមន្ត្រីជាន់ខ្ពស់ម្នាក់ជាតិជប៉ុន បានសុខចិត្តឲ្យគេកប់ខ្លួនទាំងរស់ទៅក្នុងដី ដើម្បីតាមហែព្រះមហាក្សត្ររបស់ខ្លួន ដែលស្តេចយាងទៅលោកមុខ ទៅថ្ងៃដែលគេធ្វើព្រះរាជពិធីបញ្ចុះព្រះបរមសពនោះ ។ តែឥឡូវនេះ មានបញ្ញត្តិហាមមិនឲ្យកប់មនុស្សទាំងរស់ទៅតាមសព ។

ទំនៀមអ៊ីហ្ស៊ីប, ប្រជាជនជាតិអ៊ីហ្ស៊ីបសម័យបុរាណ កប់សពដូចចិនទីងជប៉ុនដែរ ប៉ុន្តែគេចេះរក្សាសពទុកឲ្យបានយូរអង្វែង មិនឲ្យស្អុយរលួយ (១) ដោយគេដាក់ថ្នាំរក្សាសព ហើយគេដំកល់សពទុកក្នុងទីកន្លែងដ៏ល្អល្អះមាំមួនផង គេយកចំណីអាហារទីងគ្រឿងប្រើប្រាស់ផ្សេងៗទៅដំកល់ទុកក្នុងទីដំកល់សពផង ព្រោះគេជឿថា " មនុស្សស្លាប់ហើយវិញ្ញាណទីងត្រឡប់មកចូលក្នុងរាងកាយដើមវិញទៀត" ព្រោះហេតុនោះបានជាគេបាត់ការធ្វើទីដំកល់សពរបស់ខ្លួនទុកជាមុន តាំងពីនៅមានជីវិតនៅឡើយ ។

---

១ នៅប្រទេសអ៊ីហ្ស៊ីប មានឆាងស៊ីឈ្លួលកប់សពច្រើនណាស់ ។

ទំនៀមអ្នកកាន់សាសនាគ្រិស្ត និងសាសនាអិស្លាម, ជនកាន់សាសនាទាំងពីរនេះក៏កប់សពដូចជាតិចិន, ជប៉ុន និងអ៊ីហ្សីបដែរ ។ លទ្ធិសាសនាទាំងពីរនេះ យល់ឃើញស្របគ្នាថា កាលដល់ "ថ្ងៃកាត់សេចក្តី ឬថ្ងៃគតិនោះមកទៀត លោកនៃមនុស្សយើងនេះនឹងមិនមានទៀតទេ មនុស្សស្លាប់ហើយនឹងរស់ឡើងវិញទាំងអស់គ្នា អ្នកធ្វើល្អបានឡើងស្ថានសួគ៌ អ្នកធ្វើអាក្រក់ចុះនរក" ។ ប៉ុន្តែ ខាងលទ្ធិសាសនាអ៊ីស្លាមយល់ខុសពីសាសនាគ្រិស្តខ្លះថា "មនុស្សស្លាប់ហើយវិញ្ញាណត្រូវទៅពយការណ៍របស់ខ្លួនចំពោះព្រះម្ចាស់សួគ៌ ហើយត្រឡប់មកនៅនឹងរាងកាយដើមវិញ រង់ចាំថ្ងៃកាត់សេចក្តី" ។ ចំណែកសាសនាគ្រិស្តជឿថា 'វិញ្ញាណរបស់អ្នកស្លាប់ហើយ ត្រូវទៅរក ភ្លើងជម្រះ រង់ចាំថ្ងៃកាត់សេចក្តីដែរ" ។ ហេតុនេះ បានជាជាតិបារាំងមិនចង់តែរួតសពដូចខ្មែរយើងទេ ដ្បិតគេមិនទុកសពឲ្យយូរហួសពី ៤៨ ម៉ោងឡើយ ។

ទំនៀមហិណ្ឌូ, ប្រជាជនជាតិហិណ្ឌូសម័យបុរាណ ធ្វើពិធីដុតសព ។ ជនជាតិនេះធ្វើពិធីដុតសពវិសេសប្លែកជាងជាតិឯទៀតត្រង់កិច្ចមួយគឺក្នុងវេលាដែលគេដុតសពប្តី ប្រពន្ធត្រូវតាក់តែងខ្លួនឲ្យល្អស្រស់ដោយគ្រឿងមង្គលការ ហើយចូលទៅអង្គុយឧបប្តីលើជើងថ្ករ ឲ្យគេដុតខ្លួនទាំងរស់ ដោយតាំងចិត្តថា "នឹងទៅរៀបមង្គលការជាមួយនឹងប្តីនៅលោកមុខម្តងទៀត" ។ ចំណែកប្តីវិញ បើប្រពន្ធស្លាប់ហើយមិនត្រូវដុតខ្លួនឲ្យស្លាប់ទៅតាមប្រពន្ធទេ សុខចិត្តឲ្យប្រពន្ធស្លាប់ទៅតែម្នាក់ឯងចុះ ៗ

# រឿងប្រពន្ធដុតខ្លួនឲ្យស្លាប់ទៅតាមប្ដី(១)

កាលពីក្នុងឆ្នាំ ព.ស. ២៤៨០ នាងរូបាតានី ជាតិឥណ្ឌា កាលប្ដីស្លាប់ហើយ គ្រូពេទ្យប្រចាំតំបន់មកពិនិត្យសពនឹងប្រកាសមរណភាពក្នុងវេលាល្ងាចនៃថ្ងៃនោះ ។ នាងរូបាតានីក៏ស្នើបំណងរបស់នាងឲ្យពពួកញាតិមិត្តទាំងឡាយបានជ្រាប ព្រមទាំងបង្អង់ការឈាបនកិច្ចទុកដល់ថ្ងៃស្អែកឡើង ដើម្បីនាងនឹងមានឱកាសធ្វើកិច្ចដែលគួរធ្វើរបស់នាង ។ គ្រានោះ ពួកអ្នកដែលមកប្រជុំក្នុងបុណ្យសពនោះ ទាំងប្រុសទាំងស្រី ទាំងអ្នកជិតទាំងអ្នកឆ្ងាយ រហូតដល់ទៅខ្ញុំប្រុសខ្ញុំស្រីរបស់នាងក៏ចូលទៅអង្វរករហាមឃាត់នាង មិនឲ្យធ្វើកម្មណាមួយដែលជាការល្មើសច្បាប់អង់គ្លេស ដែលបញ្ញត្តលុបលាងមិនឲ្យប្រពន្ធដុតខ្លួនទាំងរស់ទៅតាមសពប្ដីជាដាច់ខាត ។ ប៉ុន្តែនាងមេម៉ាយឆ្លើយតបតាមបទបញ្ញត្តិដែលមានក្នុងគម្ពីរហិណ្ឌូថា "មុខងាររបស់ភរិយា គឺនៅត្រង់មិនព្រមឃ្លាតចាកស្វាមីក្នុងយាមរស់ឬក្នុងយាមស្លាប់" ។ ពួកញាតិមិត្តដូច្នោះក៏មិនអាចហាមឃាត់នាងបាន ប៉ុន្តែបានស្នើរឿងនោះឲ្យពដការជ្រាបសព្វគ្រប់ ។

គ្រានោះ មានយោគីកន្ទាត់ម្នាក់នៅក្នុងស្រុកនោះ ជាអ្នកបំភ្លឺទំនៀមទម្លាប់នៃឈាបនកិច្ចក្នុងឥណ្ឌាថា គេច្រើនតែធ្វើឈាបនកិច្ចក្នុងវេលាពីរបីម៉ោងជាខាងក្រោយពេលស្លាប់ហើយ វៀរតែអ្នកស្លាប់ក្នុងវេលាល្ងាចដែលមិនអាចនឹងចាត់ការឲ្យទាន់ពេលបាន ។ ការមរណភាពនៃប្ដីនាង

---

១ ស្រង់ចាកប្រវត្តិរបស់ប្រជាជាតិឥណ្ឌា ក្នុងច្បាប់ប្រវត្តិសាស្ត្រសាកល ។

រូបាគានីនៅវេលារដូវរងាខ្លាំង នាងទើបបង្អង់ការឈាបនកិច្ចឲ្យយឺតយូរបន្តិច ដើម្បីប្រុងប្រៀបការដែលនាងត្រូវធ្វើឲ្យរួចជាមុនសិន ៗ លុះវេលាព្រឹកឡើងអរុណជិតរះហើយ នាងរូបាគានីក៏ចាត់ចែងបំពាក់គ្រឿងអាភរណ៍ឲ្យប្ដីយ៉ាងផ្ចិតផ្ចង់តាមទំនៀមស្រុក រួចហើយបែរមកតាក់តែងខ្លួនរបស់នាងវិញ គឺនាងស្លៀកពាក់គ្រឿងវិវាហមង្គល ហើយសៀតផ្កាឈើនិងពាក់មាសពេជ្រគ្រឿងប្រដាប់ដទៃទៀត នាងយកជាតហិង្គុលសម្បុរក្រហមស្រស់មកដៅត្រង់ថ្ងាសរបស់នាង ជាសញ្ញានៃភរិយាភាពក្នុងគ្រាចុងក្រោយបំផុត ស្រេចហើយនាងបើកទ្វារចេញទៅ មានកិរិយាឫកពាជាសុខតាមធម្មតា ហាក់ដូចជានាងក្រមុំដែលកំពុងតែបែរមុខទៅរកមដុមាស(១) ជាមួយប្ដីរបស់នាង មើលទៅដូចជាមិនមែនស្រីមេម៉ាយដែលប្រុងនឹងដុតខ្លួនឲ្យស្លាប់ទៅតាមប្ដីទេ ។ នៅវេលាដែលនាងចេញមកក្រៅផ្ទះ មានស្រីជាញាតិមិត្តមួយពួកបានតៀនស្មារតីឲ្យនាងត្រិះរិះជាថ្មីឲ្យស្រួលបួលសិន ក្នុងការដែលនាងធ្វើលើសច្បាប់លោកដូច្នោះ ប៉ុន្តែ ពាក្យឆ្លើយរបស់នាង ធ្វើឲ្យអ្នកទាំងនោះស្ងាត់មាត់ប្រៀបដូចគេចុកថា " ពួកអ្នកកាលគ្នាដែលមកហាមឃាត់ខ្ញុំដូច្នេះ នឹងត្រូវបណ្ដាសាទេពតាឲ្យធ្លាក់ក្នុងផ្នែករហូតទៅ ព្រោះការដែលខ្ញុំធ្វើពិធីនេះ គឺខ្ញុំធ្វើដោយសេចក្ដីស្មោះត្រង់នឹងស្វាមីរបស់ខ្ញុំ នឹងចំពោះទេពតាដែលជាទីគោរពរបស់ខ្ញុំ " ។

---

១ គឺវេទដែលរៀបមង្គលការ ជាវេទមានឧជារសង្អែមឈ្ងុយឆ្ងាញ់ពិសាធ្លួចទឹកឃ្មុំថ្មី ៗ ។

ខណៈនោះ គេចាប់សែងក្រែសពប្តីរបស់នាងចេញមកដាក់នៅធរណីទ្វារអស់ពេល ៤ ឬ ៥ នាទី ដើម្បីទទួលទឹកពរបស់អ្នកបួស ដែលជាពិធីដំបូង ។ គ្រានោះ នាងរូបាតានីបានយកដាយសំពត់វិហាមគ្គលរបស់នាងទៅចងភ្ជាប់ទីងក្រែដាក់សពប្តី ដើម្បីជាសញ្ញាក្នុងគ្រាចុងបំផុតថា "នាងជាភរិយាពិត មិនមែនជាស្រីមេម៉ាយទេ" ។ កាលអ្នកបួសឲ្យពរទឹកចប់ហើយ នាងក៏ដើរបំបាំងខ្លួនទៅក្នុងពួកទិករជន លុះទៅដល់ទីផុតសពហើយ នាងរូបាតានីក៏ទៅពួនលាក់ខ្លួនក្បែរដើមថ្កុវ ។ អ្នកបួសក៏មកសូត្រមន្តឲ្យពរម្តងទៀត លុះចប់ហើយ គេក៏លើកសពដាក់ទៅលើដើមថ្កុវ ។ គ្រឿងតូរ្យតន្ត្រីក៏ប្រគំឡើងលាន់ទ្រហឹងអឹងកងព្រមគ្នា ។ វេលានោះ ព្រះភ្លើងក៏ឆេះសន្ធោឡើង ។ នាងរូបាតានីបានលបលាបប្រេងជោកខ្លួនទាំងមូល ហើយក៏ស្ទុះចូលទៅឱបប្តីក្នុងគំនរភ្លើងមួយរំពេច ។ សេចក្តីនេះជ្រាបទៅដល់ពួកកងក្រវែល ។ បីនាក់បានរត់ចូលមកការពារ ប៉ុន្តែការពារមិនឈ្នះ ព្រោះវេលានោះមានស្រី ៩ នាក់ដែលជាញាតិមិត្ររបស់នាងបានរាំងរាមិនឲ្យពួកកងក្រវែលចូលចុះ ។ ពេលនោះ គេឮសូរសំឡេងនាងស្រែកច្ងេក ៗ ដោយអំណាចត្រូវកំដៅភ្លើងយ៉ាងក្តៅខ្លាំងដែលនាងមិនអាចទ្រាំបាន ហើយក៏បាត់ឈឹងស្ងៀមទៅវិញ ព្រោះតែសូរសន្ធឹកព្រះភ្លើងឆេះគឹក ៗ ឡើង ។ អ្នកបួសក៏តាំងសូត្រធម៌ម្តងទៀតជាការបង្ហើយកិច្ច ។ ចំណែកគ្រហស្ថក៏ស្រែកសូត្រឲ្យសព្ទសាធុការពរព្រមគ្នាឡើង ។ វេលានោះ វិញ្ញាណរបស់នាងរូបាតានី ក៏រលត់បាត់ឈឹងស្ងៀម

ទៅដោយប្រការដូច្នេះ ។ ពិធីដែលប្រពន្ធដុតខ្លួនទាំងរស់ទៅតាមសពប្ដីនេះ ជាតិឥណ្ឌៀបញ្ញត្តិហៅថា "សត្តិកម្មសុត្តិ" ។

ប្រជាជនជាតិហិណ្ឌូជឿថា "មនុស្សស្លាប់ហើយ វិញ្ញាណចេញពីកន្លែងកាយចាស់ ទៅចូលនៅក្នុងកាយថ្មីទៀត វិលស្លាប់វិលកើតនៅក្នុងកពតផ្សេង ៗ ទាល់តែដល់វិញ្ញាណស្អាតបរិសុទ្ធហើយ ទើបចូលទៅនៅរួមជាមួយនឹងព្រះព្រហ្មលើស្ថានសួគ៌" ។

## ប្រពៃណីរបស់ជនជាតិខ្មែរ លាវ និង ថៃ

ជនជាតិទាំង ៣ នេះ និយមការដុតសពដូចជាតិហិណ្ឌូដែរ មានខ្មែរយើងខ្លះកប់សពក្នុងដីជាបណ្ដោះអាសន្ន ដោយគាំងចិត្តថាថ្ងៃ ខែ ឆ្នាំណាស្រួល នឹងគាស់សពឡើងដុត ។ តាមទំនៀមទម្លាប់របស់ជនជាតិខ្មែរ : កាលមនុស្សស្លាប់ហើយ មុនដំបូងគេលាងជម្រះសពឲ្យស្អាត រួចស្លៀកបំពាក់សពនោះដោយសំពត់អាវយ៉ាងល្អថ្មី ៗ ហើយគេដាក់ប្រាក់ ១ កាក់ក្នុងមាត់សពផង ដោយខ្លាចក្រែងសពនោះគ្មានសំពត់អាវស្លៀកពាក់ និងគ្មានប្រាក់ចាយក្នុងលោកមុខទៀត សូម្បីបាន, ឆ្នាំង, ជើងក្រាន, អង្ករ, ត្រី គេក៏ដាក់បូជាឲ្យសពយកទៅបរិភោគនៅលោកមុខដែរ ។ បើជាអ្នកមានធនធានច្រើន កាលគេដុតសពស្រេចហើយ គេរើសយកឆ្អឹងធាតុទៅធ្វើពិធីដុតក្នុងទីដទៃម្ដងទៀត ។ កិច្ចធ្វើបុណ្យសពនៅប្រទេសខ្មែរមានច្រើនផ្នែកណាស់ គឺគេធ្វើតាមទំនៀមទម្លាប់ស្រុកខ្មែរខ្លះ តាមគម្ពីរសាសនាព្រះពុទ្ធខ្លះ តាមសាសនា

ព្រាហ្មណ៍ខ្វះ ។ កិច្ចសពនេះមានរបៀបកំប៉ិកកំប៉ុកច្រើនណាស់ ខ្ញុំរៀបរាប់ក្នុងទីនេះមិនល្មមវេលាទេ ។

ខាងសាសនាព្រាហ្មណ៍ប្រកាន់ថា "វិញ្ញាណជាអត្តា" ។ ឯខាងព្រះពុទ្ធសាសនាប្រកាន់ថា "វិញ្ញាណជាអនត្តា" ព្រោះមានព្រះពុទ្ធដីកាថា "របស់ផ្សេងៗ នៃគ្រឿងរថ បើរួបរួមចូលគ្នា ទើបយើងហៅថា "រថ" បាន បើគេដោះរបស់អស់នោះឲ្យដាច់ចេញដោយឡែកពីគ្នាហើយ យើងនឹងហៅរបស់ផ្សេងៗនោះថា "រថ" មិនបានទេ ។ រថប្រៀបដូចរូបមនុស្សទាំងមូល ដែលមានកាយនឹងចិត្តថ្មើមនៅរួបរួមគ្នា សន្មតឈ្មោះផ្សេងៗគ្នាថា ដៃ, ជើង, ក្បាលជាដើម ដល់វេលាស្លាប់ហើយ អវយវៈទាំងអស់មានដៃ, ជើង, ក្បាលជាដើមនោះ ក៏បែកខ្ញែកចេញពីគ្នាអស់ មិននៅរួមគ្នាដូចកាលមានជីវិតឡើយ ។ ដូច្នេះពុទ្ធសាសនាក៏បានយល់ឃើញថា "លោកមុខមានមែន" ព្រោះមនុស្សគ្រប់រូបទៀងតែស្លាប់ៗ ហើយទៀងតែកើតទៀត, ត្រង់ការស្លាប់ហើយកើតទៀតនោះ ឈ្មោះថា លោកមុខ ។ ជួនកាលគេហៅថា "កពមុខ" ត្រូវនឹងពាក្យជាគូគ្នាថា "លោកនេះ ជាគូនឹងលោកមុខ, កពនេះ ជាគូនឹងកពមុខ, ជាតិនេះ ជាគូនឹងជាតិមុខ" ។ ពួកបុថុជ្ជនទាំងអស់ទៀងតែមានលោកមុខ ឬកពមុខ ។ មានតែពួកព្រះអរហន្តមួយពួកទេ ដែលគ្មានលោកមុខ ដ្បិតលោកចូលនិព្វានហើយ ។

ប្រជាជនជាតិស្រុស្រីសម័យបច្ចុប្បន្ននេះ គេប្រដៅពួកអ្នកស្រុកគេថា

"យើងធ្វើការក្នុងលោកនេះ យើងត្រូវតែប្រាថ្នាយកផលប្រយោជន៍ឲ្យបានក្នុងលោកនេះ ឲ្យទាន់ចិត្ត កុំបង្អង់ចាំយកផលក្នុងលោកមុខ" ។ ការយល់ឃើញរបស់ជាតិរុស្ស៊ីនេះ បើទុកជាទាស់ខុសផ្ទុយនឹងសាសនានានាក្នុងលោកនេះ ក៏នៅតែមានមនុស្សភាគច្រើនយល់ស្របតាមមតិនៃប្រជាជាតិរុស្ស៊ីដែរ ព្រោះលទ្ធិសាសនានានាក៏បានប្រដៅថា "កើតជាមនុស្សត្រូវតែមានមានះព្យាយាមធ្វើការ ខំធ្វើការឲ្យទាល់តែបានផលនៅនាលោកិយឲ្យទាន់ភ្នែក ហើយធ្វើតែការសុចរិតល្អផង ដើម្បីឲ្យបានផលទៅបរលោក គឺសាសនាខ្លះប្រដៅថា អ្នកធ្វើល្អនឹងបានឡើងទៅនៅជាមួយព្រះព្រហ្មឯស្ថានព្រហ្ម, សាសនាព្រះពុទ្ធ ប្រដៅថា អ្នកធ្វើល្អនឹងបានទៅនៅរួមជាមួយព្រះអរហន្ត (និព្វាន) ។ ហេតុនេះមនុស្សក្នុងលោកភាគច្រើនប្រកាន់ជឿថា លោកមុខមានមែន នេះជាការដោះស្រាយប្រស្នាថា លោកមុខមានមែនឬទេ ។

---

# ផ្នែកសាសនា

## ឃ្លោកលិច អំបែងអណ្ដែត

### ព្រះទេពសត្ថា កិម-គូ

រៀបរៀង

---

ពាក្យថា "ឃ្លោកលិច អំបែងអណ្ដែត" នេះ ជាពាក្យដែលយើងធ្លាប់និយាយរត់មាត់មកហើយ មិនមែនជាពាក្យទំនើបទើបនឹងមានថ្មីទេ ។ ពាក្យនេះ ជាសុភាសិតបុរាណ កើតមានតាំងពីជាន់ពុទ្ធសម័យ រាង ២៥ សតវត្សមកហើយ ដែលព្រះសម្ពុទ្ធជាម្ចាស់នៃយើងទ្រង់ព្យាករ ដោយសេចក្ដីឧបមាឧបមេយ្យ ចំពោះព្រះបាទបសេនទិកោសលដែលក្រាបបង្គំទូលសួរ ។

យើងនឹងលើកពាក្យនេះ មកអត្ថាធិប្បាយឲ្យត្រូវតាមគោលបំណងនៃសុភាសិតនោះ ដើម្បីឲ្យអស់លោកអ្នកអាន គ្រាន់តែបានជាគតិ ព្រោះអស់លោកអ្នកខ្លះចេះថា "ឃ្លោកលិច អំបែងអណ្ដែត" ដែរ ប៉ុន្តែមិនសូវយល់សេចក្ដីជាក់លាក់ ឬក៏យល់ឃ្លាងពីគោលបំណងក្នុងសុភាសិតនេះ ក៏សឹងមាន ។ ដូចត្រង់ពាក្យ "ឃ្លោកលិច" គេច្រើនយល់ថា អ្នកណាមួយកើតក្នុងត្រកូលខ្ពង់ខ្ពស់ ដែលគួរតែទទួលឋានៈជាអ្នកមានយសសក្ដិមានទ្រព្យធន ជាហេតុធ្វើវង្សត្រកូលខ្លួនឲ្យខ្ពង់ខ្ពស់តទៅទៀត តែមិនដូច្នោះ ត្រឡប់ជាលិចចុះក្នុងហីនភាពជាអ្នកគ្មាន

យសសក្តិវិនាស ទ្រព្យសម្បត្តិធ្លាក់ខ្លួនជាមនុស្សក្រីក្រអនាថា គេប្រដូចមនុស្សនោះទៅនឹងឃ្លោកដែលជាវត្ថុស្រាលគួរតែអណ្តែតលើទឹក តែបែរជាលិចក្នុងទឹកទៅវិញ ។ ត្រង់ពាក្យ "អំបែងអណ្តែត" គេយល់ថា អ្នកណាមួយកើតក្នុងត្រកូលៈថោកទាបខ្សត់ខ្សោយ គួរនឹងលិចចុះទៅក្នុងឋានៈទាបថោកដកបទៅ តែបែរជាអណ្តែតមានឋានៈខ្ពង់ខ្ពស់មានយស-សក្តិថ្លៃថ្លា គេប្រដូចមនុស្សនោះទៅនឹងអំបែង ដែលជាវត្ថុមានទម្ងន់គួរតែលិចចុះទៅក្នុងទឹក តែត្រឡប់ជាអណ្តែតទឹកវិញ ។ សេចក្តីយល់បែបនេះមិនត្រូវតាមពុទ្ធដីកាដែលសំដែងទេ ។ ហេតុនេះ យើងសូមៈធ្វើសេចក្តីបរិយាយសុភាសិតនេះ តាមគម្ពីរជាតកឯកនិបាតដែលមានសេចក្តីផ្សាលផ្សៅឲ្យទៅជាភក់ផ្ងារស្តាប់ តាមលំដាប់ហូរហែដូចតទៅនេះ ៖

ពាក្យថា "ឃ្លោកលិច អំបែងអណ្តែត" នេះ បើគេសំឡឹងមើលនូវរូបវត្ថុនេះដោយមិនបេចក្ខុ ឃើញថាផ្ទុយពីពាក្យនេះស្រឡះ ។ ធម្មតាសំបកឃ្លោកដែលក្រៀមស្ងួតស្រាលស្ញើក បើគេបេកទៅបោះក្នុងទឹក ពិតជាអណ្តែត ចុះហេតុអ្វីពាក្យនេះបែរជាថា "ឃ្លោកលិច" ទៅវិញ? ធម្មតាអំបែងមានអំបែងចាន ឬអំបែងឆ្នាំងជាដើម ជាធម្មជាតធ្ងន់ បើគេយកទៅបោះក្នុងទឹក ពិតជាលិចចុះបាត់ទៅក្នុងទឹកមួយរំពេច ចុះហេតុអ្វីពាក្យនេះបែរជាថា "អំបែងអណ្តែត" ទៅវិញ? ហេតុនេះពាក្យទាំងពីរម៉ាត់នេះ ជាសេចក្តីប្រៀប ជាពាក្យប្រដូចដោយពិត ។

យើងសូមទាញយកពាក្យខាងឧបមេយ្យមកអធិប្បាយផ្គូរផ្គងនឹងពាក្យឧបមាខាងលើនោះឲ្យឃើញស្របគ្នាថា: ក្នុងលោកទាំងមូល តាមតែ

ប្រទេសណាជាតិណាក៏ដោយ តែងតែមានមនុស្សជាន់ទាប, ជាន់ខ្ពស់ គឺមនុស្សល្ងង់, មនុស្សបេះ, មនុស្សទុច្ចរិត, មនុស្សសុចរិត, មនុស្សអាក្រក់, មនុស្សល្អ, មនុស្សពាល, មនុស្សបណ្ឌិត, នៅប្រឡូកប្រឡល់លាយឡំជាមួយគ្នាជាដរាប គ្រាន់តែមានចំនួនតិចនឹងច្រើនជាងគ្នាប៉ុណ្ណោះ ។ មនុស្សទាំងប៉ុន្មានប្រភេទដូចថាមកនេះ បើតាមប្រទេសដែលកាន់ពុទ្ធសាសនា បែកជាពីរផ្នែកគឺ គ្រហស្ថ ១ ផ្នែក បព្វជិត ១ ផ្នែក ។ មនុស្សទាំងពីរផ្នែកនេះមានវត្ថុបំណងស្របគ្នាតែបែបមួយ គឺចង់បានសុខ, ចង់រស់នៅយឺនយូរ ចង់បានឋានៈដ៏ខ្ពង់ខ្ពស់ ។ល។ វត្ថុបំណងទាំងនេះឯងដែលដឹកនាំមនុស្សនីមួយ ៗ ទាំងធំទាំងតូចឲ្យមានដំណើរខំស្វះស្វែងរកតាមផ្លូវទឹកផ្លូវគោកជានិច្ច ។

នៅក្នុងយុគខ្លះ បើមនុស្សលោកវិបប្រែប្រួលហើយ សង្ខារលោកក៏វិលប្រែប្រួលទៅតាមដែរ ឬថា មនុស្សលោកវិលទៅតាមសង្ខារលោកក៏ថាបាន សង្ខារលោកវិលទៅតាមមនុស្សលោក ក៏ថាបាន ។ សូមទាញឧទាហរណ៍មួយយ៉ាងឆាយ មកពិចារណាមើលចុះ ដូចគ្រឿងសម្លៀកបំពាក់មានខោ អាវជាដើម ដែលមនុស្សប្រើប្រាស់ សម័យខ្លះ ជើងខោធំទូលាយស្រុងចុះក្រោម, សម័យខ្លះជើងខោតូចចង្អៀតរួចឡើងលើ; ចំណែកខាងអាវសោតទៀត សម័យខ្លះគេប្រើឡេវតិច, សម័យខ្លះគេប្រើឡេវច្រើន គឺវិលទៅតាមលោកនិយម ។ ន័យឯទៀតក្រៅពីនេះ គប្បីលើកយកមកពិចារណាឯងចុះ តើវិនិច្ឆ័យថា មនុស្សវិលទៅតាមសង្ខារលោក ឬថាសង្ខារលោកវិលទៅតាមមនុស្ស? យើងអាចសន្និដ្ឋាន

បានថា អធ្យាស្រ័យគឺចិត្តគំនិត ព្រមទាំងការយល់របស់មនុស្សប្រព្រឹត្តទៅបែបណា សង្ខារលោកក៏ប្រព្រឹត្តទៅបែបនោះដែរ ។ ព្រោះហេតុនោះ ក្នុងសម័យណា អំពើទុច្ចរិតរបស់មនុស្សមានកម្លាំងខ្លាំងឡើង, ក្នុងសម័យនោះ អំពើទុច្ចរិតនោះឯង អាចទៅបំបែរបំបត់សង្ខារលោកដែលជារបស់គ្មានចិត្ត គ្មានវិញ្ញាណ ឲ្យទៅជារបស់ហាក់ដូចជាមានចិត្តមានវិញ្ញាណក្លាហានកាចសាហាវ អាចទៅបៀតបៀនមនុស្សឲ្យទទួលទុក្ខវេទនាឬទៅបៀតបៀនសង្ខារលោកដូចគ្នា ឲ្យដល់នូវសេចក្តីវិនាសអន្តរាយដោយសារកម្លាំងរបស់ខ្លួន ទីងចាំបាច់និយាយថ្វីដល់មនុស្សផងគ្នា ។ មួយទៀត ក្នុងសម័យណា អំពើសុចរិតរបស់មនុស្សមានកម្លាំងខ្លាំងក្លាឡើង, ក្នុងសម័យនោះ អំពើសុចរិតនោះឯង អាចទៅបំបែរបំបត់ផ្លែលកសង្ខារលោកដែលគ្មានចិត្ត គ្មានវិញ្ញាណ ឲ្យទៅជារបស់ហាក់ដូចជាមានចិត្តមានវិញ្ញាណឲ្យទៅជាស្លូតបូត ជារបស់មានប្រយោជន៍ ឲ្យសេចក្តីសុខដល់មនុស្សទូទៅ ដោយសារកម្លាំងរបស់ខ្លួន ។

មនុស្សទុច្ចរិត ច្រើនមានអធ្យាស្រ័យត្រូវគ្នានឹងមនុស្សទុច្ចរិតដូចគ្នា ឯមនុស្សសុចរិត ក៏ច្រើនមានអធ្យាស្រ័យត្រូវគ្នានឹងមនុស្សសុចរិតដូចគ្នា, ដែរ ។ ខាងពុទ្ធសាសនាចាត់មនុស្សពាលប្រព្រឹត្តទុច្ចរិតថាជាមនុស្សអសប្បុរសលាមកអាក្រក់ថោកទាប ជាមនុស្សអស់តម្លៃស្រាលស្មើកដូចសំបកឃ្លោក; មនុស្សសំបកឃ្លោកនេះ គួរតែមានទោសទុក្ខជាប់គុក ត្រូវទណ្ឌកម្មតាមយថាកម្មរបស់ខ្លួន តែមិនដូច្នោះ ត្រឡប់ជាគេលើកតំកើងឲ្យមានយសស័ក្តិ ជាមេបាគ្រប់គ្រងត្រួតត្រាក្នុងក្រុម ក្នុងសង្គម ឬក៏ក្នុង

គំណែនជាន់ខ្ពស់ ។ មួយទៀត សំដីរបស់មនុស្សសំបកឃ្លោក នោះឯង កាលបើបាននិយាយអ្វីទៅរកអ្នកធំអ្នកតូចហើយ សំដីនោះស្រាលស្ទើកគ្មានខ្លឹមសារអ្វីសោះ គួរណាសំដីតែអណ្តែតរសាត់បាត់ទៅ តែមិនដូច្នោះ សំដីនោះបែរទៅជាលិចចុះទៅប្រតិស្ឋានជិតដក់ជាប់នៅជានិច្ចក្នុងចិត្តគំនិតរបស់អ្នកធំអ្នកតូច ជាសំដីត្រូវគេជឿស្តាប់ធ្វើតាមទៅវិញ ដូចគ្នានឹងសំបកឃ្លោកជារបស់ស្រាលសោះ គួរតែអណ្តែតរសាត់បាត់ទៅ មិនដូច្នោះ បែរទៅជាលិចចុះក្នុងទឹកវិញក៏ដូច្នោះដែរ ។

ចំណែកខាង មនុស្សបណ្ឌិតប្រព្រឹត្តសុចរិតមានមេត្តានចិត្តសប្បុរសបេះដូងល្អ ទុកជាមនុស្សមានដំឡៃ ឬមានទម្ងន់ដូចអំបែងថ្មពេជ្រ ។ មនុស្សថ្មពេជ្រនេះ គួរតែគេលើកតំកើងក្នុងឋានៈខ្ពង់ខ្ពស់ មានតំណែងរដ្ឋមន្ត្រី តំណែងតុលាការវិនិច្ឆ័យកាត់ក្តីជាដើម តែបែរទៅជាអាប់ទុនធ្លាក់ខ្លួនចុះទៅកាន់ឋានៈដ៏ថោកទាប បាត់កេរ្តិ៍ឈ្មោះ គ្មានយសសក្តិទៅជាអាយត្តរបស់មនុស្សសំបកឃ្លោកទៅវិញ មួយទៀតមនុស្សថ្មពេជ្របើបាននិយាយពីអ្វីទៅរកអ្នកធំអ្នកតូច សំដីនោះសូម្បីពិតមានប្រយោជន៍មានខ្លឹមសារ មានទម្ងន់ធ្ងន់ដូចអំបែងថ្ម គួរតែលិចចុះប្រតិស្ឋានជិតដក់ជាប់នៅ ក្នុងចិត្តគំនិតរបស់អ្នកធំអ្នកតូច តែមិនដូច្នោះ ទៅជាសំដីស្រាលស្ទើកអណ្តែតរសាត់ជាត់បាត់ទៅ គេមិនអើពើជឿស្តាប់ធ្វើតាមទៅវិញ ដូចគ្នានឹងអំបែងថ្មជារបស់ធ្ងន់ គួរតែលិចចុះទៅក្នុងទឹក មិនដូច្នោះ បែរជាអណ្តែតរសាត់ទៅតាមទឹកវិញដូច្នោះឯង ។

ពាក្យថា "ឃ្លោកលិច អំបែងអណ្តែត" នេះ ជាសេចក្តីឧបមា

ជាព្រះផ្លូវទៅតាមស្ថានការណ៍លោកឬប្រទេស ដែលមានការវិបត្តិប្រែប្រួល ៗ សេចក្តីនេះមានពិតក្នុងគម្ពីរជាតកឯកនិបាត, យើងសូមទាញយករឿងនោះ មករៀបរៀងទុកក្នុងទីនេះថែមទៀត ដើម្បីបញ្ជាក់ឲ្យឃើញជាតួយ៉ាង ៖

ក្នុងសម័យ ដែលព្រះសព្វញ្ញុពុទ្ធជាម្ចាស់នៃយើង បានត្រាស់ឡើងក្នុងលោកហើយ, គ្រានោះឯង មានព្រះមហាក្សត្រមួយព្រះអង្គព្រះនាម បសេនទិកោសល ទ្រង់ផ្ទំលក់ស្កប់ស្កល់ក្នុងរាត្រីមួយ, ទ្រង់ឃើញសុបិននិមិត្តមួយចំឡែកអស្ចារ្យ ដែលព្រះអង្គមិនធ្លាប់ដែលប្រទះឃើញម្តងណាសោះឡើយ គឺទ្រង់ឃើញសំបកឃ្លោកស្ងួតស្រាលស៊ើកលិចចុះស្រមបាត់ទៅក្នុងទឹក, មួយទៀត ទ្រង់ឃើញដុំថ្មតាន់ធំៗ ប៉ុនទូកប៉ុនផ្ទះ អណ្តែតត្រោលទើរនៅលើទឹក. លុះដល់វេលាព្រឹក ទ្រង់តើនឡើងហើយ មិនអាចវិនិច្ឆ័យសុបិននិមិត្តនោះដោយព្រះអង្គឯងបានឡើយ, ទ្រង់រៀបព្រះរាជដំណើរចូលទៅគាល់ព្រះសម្ពុទ្ធ ដែលទ្រង់គង់នៅនាវត្ត-ជេតពន ដើម្បីទូលសូមឲ្យព្រះអង្គព្យាករសុបិននិមិត្តនោះ ៗ

ខណៈនោះ ព្រះអង្គទ្រង់ព្យាករថ្វាយថា បពិត្រមហារាជ, ក្នុងអនាគត កាលបើអធម្មិករាជ (ព្រះរាជាមិនប្រព្រឹត្តតាមធម៌ ឬមិនប្រព្រឹត្តតាមច្បាប់) កើតឡើង, លោកគឺប្រជាជន ក៏វិបត្តិប្រែប្រួលមិនប្រព្រឹត្តតាមធម៌ តាមច្បាប់ដែរ ៗ អធម្មិករាជនោះ ទ្រង់មិនលើកតំកើងមិនប្រទានយសស័ក្តិ អំណាចឲ្យដល់ពួកកុលបុត្តដែលមានជាតិខ្ពង់ខ្ពស់ដែលជាអ្នកសុចរិតមានចំណេះវិជ្ជាចេះដឹងច្រើនទេ តែបែរជាទ្រង់លើក

តម្កុតម្កើងប្រទានយសស័ក្តិអំណាចឲ្យដល់ពួកកុលបុត្រ ដែលមានត្រកូលទាបថោកជាមនុស្សទុច្ចរិតល្ងង់ខ្លៅ គ្មានបំណេះវិជ្ជាទៅវិញ, ម្ល៉ោះហើយពួកកុលបុត្តដែលមានត្រកូលថោកទាបនោះ ក៏ឡើងទៅកាន់ឋានៈជាឥស្សរៈជនកាន់ការផ្សេងៗ ឯពួកកុលបុត្តដែលមានជាតិខ្ពង់ខ្ពស់ក្រៅពីនេះ ក៏ធ្លាក់ខ្លួនចុះទៅកាន់ឋានៈជាទលិទ្ទភាព សំដីរបស់ពួកកុលបុត្តដែលមានត្រកូលថោកទាប ស្រដៀងគ្នានឹងសំបកឃ្លោក ប៉ុន្តែបែរទៅជាធ្ងន់លិចចុះទៅប្រតិស្ឋានជិតដក់ជាប់នៅជានិច្ច ក្នុងទីចំពោះព្រះភក្ត្រព្រះរាជាផង ក្នុងព្រះរាជទ្វារផង ក្នុងទីចំពោះមុខអាមាត្យមន្ត្រីផង ក្នុងទីសម្រាប់វិនិច្ឆ័យកិច្ចការផ្សេងៗផង ។

មួយទៀត បើខាងព្រះពុទ្ធសាសនាវិញ ពួកបព្វជិតល្ងង់ខ្លៅ ជាបុគ្គលបាបទុស្សីល ដែលស្រដៀងគ្នានឹងសំបកឃ្លោកស្រាលស្លើក មិនមានខ្លឹមសារអ្វី បែរជាបានប្រតិស្ឋានក្នុងតំណែងជាន់ខ្ពស់តាំងនៅក្នុងសង្ឃសន្និបាតផង ក្នុងសង្ឃកម្មផង ក្នុងទីសម្រាប់វិនិច្ឆ័យកិច្ចការរបស់សង្ឃផងទៅវិញ, ឯពួកបព្វជិតជាបណ្ឌិត អ្នកមានសីលមានសេចក្តីអៀនខ្មាស ពោលពាក្យសំដីប្រកបដោយប្រយោជន៍បានការគ្រប់អន្លើ មានទម្ងន់ដូចថ្ម គួរតែធ្ងន់លិចចុះប្រតិស្ឋានតាំងនៅក្នុងឋាន ជាន់លើ ទីដ៏ប្រសើរ មិនដូច្នោះបែរជាអណ្តែតរសាត់ទៅកាន់ឋានៈទន់ទាបវិញ ។

បពិត្រមហារាជ, សូមព្រះអង្គទ្រង់ជ្រាបថា សុបិននិមិត្តនេះ មិនមានហេតុកើតអ្វីដល់ព្រះអង្គក្នុងបច្ចុប្បន្ននេះទេ ជាសុបិននិមិត្តព្រះផលបង្អួលហេតុកើតដែលនឹងត្រូវកើតមានតទៅអនាគតខាងមុខ ។

សេចក្ដីប្រៀបធៀបយ៉ាងខ្លីថា  មនុស្សទុច្ចរិតនឹងសំដីរបស់មនុស្សទុច្ចរិត  ដូចជាសំបកឃ្លោកដែលលិចចុះទៅក្នុងទឹក,  មនុស្សសុចរិតនឹងសំដីរបស់មនុស្សសុចរិត  ដូចជាអំបែងថ្មដែលអណ្ដែតនៅលើទឹក ។

## គួរដាក់មនុស្សសំបកឃ្លោក
## គួរលើកមនុស្សថ្មរពេជ្រ

មនុស្សឃ្លោកទុំគឺមនុស្សពាលទុច្ចរិត
តែងប្រព្រឹត្តពិតបង្ខូចជាតិផងខ្លួន
ត្រូវកុំលើកកុំតំកើងឲ្យធំធួន
ត្រូវធ្វើទោសតាមសំនួនបទដែលលើស ។
ធ្វើយ៉ាងនេះជាតិប្រទេសនឹងថ្កុំថ្កើង
ព្រោះនាំយើងឲ្យសាមគ្គីគ្មានឃ្នងឃ្នើស ;
មនុស្សថ្មរពេជ្រគឺមនុស្សបណ្ឌិតទ្រើស
ចេះដឹងលើសហើយយិតយោងជាតិឲ្យថ្លៃ ។
ត្រូវលើកឡើងស្ទួយតំកើងឲ្យពេញមុខ
ត្រូវកុំទុកក្នុងឋានៈទាបពេកក្រៃ
ធ្វើយ៉ាងនេះទើបគេហៅស៊ីវិល្បៃ
ជាតិក៏ថ្លៃទៅដោយសារការណ៍នេះអើយ ។

យូរ - អ៊ុង

# បញ្ញាសជាតក

## ភាគទី ៣

បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ
នៅសាលាបាលីជាន់ខ្ពស់ ចាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង
កាលដែលនៅភេទបព្វជិតពី ព.ស. ២៤៨៦ គ.ស. ១៩៤៣

(តមក)

---

## មហាសុរសេនជាតក ទី ១៤

លោកអាចារ្យ ម៉ៀវ-ឆន វត្តលង្កា
ប្រែពីបាលី

---

បត្តំ ទត្វាន យោ ធីរាតិ ឥទំ សត្ថា ជេតវនេ វិហរន្តោ អដ្ឋបរិក្ខារទានំ អារព្ភ កថេសិ ។

សត្ថា កាលអង្គសម្តេចព្រះបរមសាស្តាគង់ក្នុងវត្តជេតពន ទ្រង់ផ្តើមអំពីការឲ្យទានគ្រឿងអដ្ឋបរិក្ខារ ហើយទើបសំដែងព្រះធម្មទេសនា មានបទគាថា ថា បត្តំ ទត្វាន យោ ធីរ ដូច្នេះជាដើម ។

សេចក្តីដំណាលថា កាលពីដើម ក្នុងក្រុងសាវត្ថី មានភិក្ខុ ១ រូប មានប្រាជ្ញាមុះមុតខ្លាំងក្លា បួសក្នុងសាសនាព្រះសម្មាសម្ពុទ្ធព្រះនាមកោនាគមនៈ, ជាអ្នកមានលាភដ៏ខ្ពង់ខ្ពស់ មានយសដ៏ថ្លៃថ្លា មានបរិវារច្រើន ជាអ្នកចេះចប់ព្រះត្រៃបិដក មានសិស្សគណរាប់មិនអស់ ស្ទើរតែមិនស្គាល់សិស្សានុសិស្សរបស់ខ្លួនផង លោកគិតបន់បូជាព្រះពុទ្ធរតនៈ ព្រះធម្មរតនៈ នឹងព្រះសង្ឃរតនៈ ទើបឲ្យដំណឹងដល់សិស្សានុសិស្សថា ខ្ញុំ

នឹងឲ្យមានគ្រឿងអដ្ឋបរិក្ខារនឹងបាយទឹកជាដើមច្រើនប្រការ ដល់ភិក្ខុ ១.០០០រូប សាមណេរ ១.០០០រូប នឹងឲ្យមានសំពត់ដល់ពួកអន្ធេរ្ត នឹងពួកគ្រហស្ថផង, អ្នកទាំងឡាយចូរនាំគ្នាចាត់ចែងពេងទានឲ្យបាន សមគួរផងចុះ ៗ ពួកបរិវារក៏បានធ្វើតាមបង្គាប់ ៗ កាលនោះព្រះពុទ្ធ ទ្រង់ព្រះនាមកោនាគមនៈ ទ្រង់ជ្រាបដោយសំណាញ់ញាណថា ភិក្ខុនេះ ជាពន្ធកនៃព្រះពុទ្ធខ្ពង់ខ្ពស់បំផុតក្នុងលោក ៗ ឯភិក្ខុនោះ លុះឲ្យគេធ្វើ មណ្ឌបរួចហើយ ទើបនិមន្តព្រះសង្ឃមកប្រគល់មណ្ឌប ហើយប្រគេន គ្រឿងអដ្ឋបរិក្ខារយ៉ាងច្រើន ៗ ភិក្ខុនោះ បានប្រគេនអដ្ឋបរិក្ខាររហូត ៧ថ្ងៃ ឥតមានចន្លោះថ្ងៃណាមួយឡើយ ហើយប្រគេនបរិក្ខារដទៃទៀត ឥតមានសេសសល់ហើយចូលទៅនៅក្នុងព្រៃ ប្រារព្ធវិធុតង្គទាំង ១៣ មានពួកភិក្ខុអកនៅព្រៃបោមរោមជាច្រើនៈ លោកចំរើនវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មានក៏ទទួលអនិច្ចកម្មទៅ បានទៅកើតក្នុងព្រហ្មលោក ៗ

សម្តេចព្រះដ៏មានជោគទ្រង់ព្រះនាមកោនាគមនៈ ទ្រង់ត្រាស់សរសើរនូវអំណោយគ្រឿងបរិក្ខារ ៨ យ៉ាងស្រេចហើយ ទើបទ្រង់ព្រះចិន្តាការគិតថា "ឥឡូវនេះ គួរតែតថាគតញុំាងសេចក្តីសោមនស្សឲ្យកើតឡើងដល់ភិក្ខុទាំងឡាយ" ទើបទ្រង់ត្រាស់ថា "អ្នកមានសទ្ធាត្រូវតែឲ្យទានដើម្បីជាប្រយោជន៍ដល់ពួកសមដែលមកដល់, មានអ្នកប្រាជ្ញពីបុរាណ បានឲ្យទានយ៉ាងច្រើន ព្រមទាំងឲ្យក្បាលរបស់ខ្លួនទៀតផង"; ព្រះអង្គមានព្រះពុទ្ធដីកាតែប៉ុណ្ណោះ ក៏ទ្រង់គង់ស្ងៀម, ទាល់តែពួកភិក្ខុ

អាពាធនា ទើបទ្រង់នាំរឿងក៏វដែលកន្លងទៅហើយមកសំដែងថា (១)

អតីតេ ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ, ក្នុងកាលកន្លងរំលងទៅហើយ មានព្រះមហាក្សត្រ ១ ព្រះអង្គទ្រង់ព្រះនាម មហាសុរសេន សោយរាជសម្បត្តិក្នុងនគរពារាណសី មានព្រះអគ្គមហេសីទ្រង់ព្រះនាម វិជ្ជុលតាទេវី ៗ ព្រះ ទមហាសុរសេនរាជ ទ្រង់ទូន្មានប្រៀនប្រដៅ អស់មហាជនមានអាមាត្យជាប្រធាន រាល់ព្រឹករាល់ល្ងាចថា អ្នកទាំង-ឡាយកុំធ្វេសប្រហែស, ចូរធ្វើបុណ្យ, ចូររក្សាសីល, ចូរឲ្យទាន ៗ បំណែកខាងព្រះអង្គ ទ្រង់សាងសាលាទាន៦ ហើយព្រះរាជទានអស់ទ្រព្យរាប់សែនក្នុងមួយថ្ងៃ ៗ, ទ្រង់រក្សាឧបោសថក្នុងថ្ងៃទី ១៤ ទី ១៥, ព្រះអង្គតែងទ្រង់ភក់ព្រះសិរអំពីព្រឹក ហើយទ្រង់គ្រឿងប្រដាប់សព្វអលង្ការឡើងគង់ព្រះទីនាំងគជេន្ទ្រឈ្មោះមហាបុណ្ណរិក ស្ដេចទៅកាន់សាលាទានទ្រង់ព្រះរាជទាន ដល់ពួកស្មូមដោយព្រះហស្តព្រះអង្គ ៗ ស្ដេចទ្រង់ប្រគល់ការឲ្យពួកអាមាត្យថា " អ្នករាល់គ្នា ចូរឲ្យទានតាមបែបនេះតទៅទៀតចុះ " ហើយព្រះអង្គឡើងគង់លើដំរីឈ្មោះមហា-បុណ្ណរិកស្ដេចត្រឡប់ចូលទៅព្រះរាជវាំងវិញ ៗ មានកាលសម័យថ្ងៃមួយក្នុងពេលព្រឹកព្រាងស្វាងព្រះសុរិយា ព្រះពោធិសត្វស្ដេចទ្រង់តើនចាកសយនាក្រឡាបន្ទំ គង់តែនឹករំពឹងដល់ទានរបស់ព្រះអង្គថា អញធ្លាប់ឲ្យតែពាហិរកទាន (ទានក្រៅពីខ្លួន), ទាននោះមិនទាន់ពេញ

---

១ ជាតកនេះ ប្លែកពីជាតកឯទៀតណាស់, ព្រោះជាតកឯទៀតសុទ្ធតែព្រះសមណគោតម ទ្រង់សំដែងពជាតិកំណើតរបស់ព្រះអង្គ, ជាតកនេះត្រឡប់ឃើញឯព្រះកោនាគមនះសំដែងវិញ។

ចិត្តអញនៅឡើយ ធ្វើម្ដេចនឹងមានស្មូមមកសូមអជ្ឈត្តិកទាន (ទានក្នុងខ្លួន) អញទៀតអេះ! ប្រសិនបើមានស្មូមមកសូមភ្នែករបស់អញក្ដី បេះដូងក្ដី ខ្លួនមួយកំណាត់ក្ដី, អញមុខជាឲ្យមិនខានឡើយ ។ កំពុងតែទ្រង់ព្រះចិន្ដាដូច្នោះ ក៏ស្រាប់តែក្ដៅរំជួលដល់ពិភពសម្ដេចឥន្ទ្រាធិរាជ; ព្រះឥន្ទ្រពិចារណាមើលហេតុ ក៏បានជ្រាបរឿងរ៉ាវនោះហើយត្រេកអរណាស់ ក្នុងព្រះហឫទ័យថា អើហ្ន៎! ព្រះបាទមហាសុរសេនជាពុទ្ធង្កុរបណ្ឌលសពេជ្ញ កំពុងតែបង់ឲ្យអជ្ឈត្តិកទានតើ, តទៅក្នុងអនាគតកាល ព្រះអង្គនឹងបានត្រាស់ជាព្រះពុទ្ធ ជាទីពឹងនៃសត្វក្នុងលោក, ព្រះពោធិសត្វពីដើមៗមក ក៏ធ្លាប់តែបំពេញមហាបរិច្ចាគទានទាំង ៥ ដែរ ទើបបានត្រាស់ជាព្រះពុទ្ធ; ហេតុនេះ អញនឹងបំពេញព្រះរាជហឫទ័យព្រះអង្គទើបគួរ” ។ លុះទ្រង់ព្រះចិន្ដាស្រេច ស្ដេចចុះចាកវិមានឋានទេវលោកមកនិម្មិតអាត្មាជាមាណពឥតក្បាល កាន់ឈើច្រត់ឈរបង្ហាញខ្លួននៅនាព្រះរាជលាន ។

ឯព្រះមហាសត្វ ទ្រង់តើនស្រេច ស្ដេចប្រដាប់គ្រឿងអលង្ការ មានមហាជនចោមរោមជាបរិវារ ឡើងគង់លើព្រះទីនាំងគជេន្ទ្រជាមង្គល ស្ដេចទៅព្រះរាជទានឯសាលាទាន ។ ឯសក្កទេវរាជក៏បង្ហាញខ្លួនក្នុងកណ្ដាលចំណោមនៃមហាជន លើកដៃស្ដាំឡើងនិយាយថា បពិត្រព្រះសម្មតិទេព, ខ្ញុំព្រះអង្គជាមនុស្សឥតក្បាល, មកសូមទានព្រះសិរព្រះអង្គ, សូមទ្រង់ព្រះមេត្ដាប្រោស ព្រះរាជទានដល់ខ្ញុំព្រះអង្គកុំខាន(១) ។

១ គួរឆ្ងល់ៈ បើគ្មានក្បាលម្ដេចក៏និយាយកើត ។

ពួកជនទាំងអស់បានឃើញផ្ទះហោះក៏មានចិត្តតក់ស្លុតរន្ធត់ជាអស្ចារ្យ ៗ ព្រះពោធិសត្វ ទតយល់ហើយទ្រង់ពិគ្រោះនឹងថា បុរសនេះជាអ្វី? ទើបទ្រង់សន្និដ្ឋានក្នុងព្រះទ័យថា " បុរសនេះមិនមែនជាមនុស្សទេ ពិតជាទេវតាហើយទ្រង់ព្រះចិន្តាការថា " ព្រាហ្មណ៍នេះមកបំពេញបំណងអញហើយ" ទើបព្រះអង្គមានព្រះរាជឱង្ការថា:

អ្នកសូមរបស់អ្វី, យើងក៏ឲ្យរបស់នោះឥតទើសទាល់, យើងនឹងបំពេញបំណងរបស់យើងផង របស់អ្នកផង, ថ្ងៃនេះយើងឲ្យទាន សូមឲ្យយើងបានត្រាស់ជាព្រះពុទ្ធប្រាកដក្នុងបីឃាត បានឈ្មោះមារសត្រូវទៅក្នុងអនាគត បង្រៀនពួកមនុស្សលោក ព្រមទាំងទេវលោកអំពីកតទាំងឡាយ យើងនឹងផ្ដាច់បង់នូវធម៌ជាឫសគល់នៃសង្សារ ប្រាជ្ញាពោធិញ្ញាណ ញុំាងសត្វទាំងប៉ុន្មាន ដែលងាកនៅឡើយឲ្យឆ្លងផុតអំពីទុក្ខភ័យ ៗ លុះព្រះមហាសត្វមានព្រះរាជឱង្ការយ៉ាងនេះហើយ ទើបទ្រង់ត្រាស់នឹងអាមាត្យឈ្មោះមហាសុបិនថា នែមហាសុបិន, ចូរអ្នកឯងនាំអ្នកឥតក្បាលនេះទៅឯរាជដំណាក់ ៗ អាមាត្យទទួលព្រះរាជឱង្ការថា "ព្រះករុណាថ្លៃពិសេស", ហើយនាំមនុស្សឥតក្បាលទៅឯរាជដំណាក់ ថ្វាយដល់ព្រះរាជាហើយ ក៏ឲ្យអង្គុយនៅក្នុងទីដ៏សមគួរមួយ ៗ ព្រះមហាក្សត្រគង់លើអាសនៈជាមួយនឹងមនុស្សឥតក្បាល ត្រាស់ហៅវរជោតិកុមារ ជាព្រះរាជបុត្រសំឡាញ់ ឲ្យមកគង់លើគំនរគេនវត្ថុហើយអភិសេកឲ្យសោយរាជ្យស្នងព្រះអង្គ ត្រាស់ហៅនាងទេវីមកថា "ប្អូន

អើយ, ចូរនាងស្ដាប់ពាក្យបង, ចូរនាងមើលតាមរបស់បង ជាតាមធ្វើឲ្យកើតប្រយោជន៍ ជាតាមដែលកម្រនឹងឲ្យបាន, ថ្ងៃនេះនាងមើលបងឲ្យតាមក្បាល ដែលព្រះពុទ្ធតែងទ្រង់សរសើរតប់ព្រះអង្គ ៗ

ពួកស្រីស្នំមាននាងទេវីជាប្រធាន នឹងពួកមហាជនមានអាមាត្យជាដើម ក៏កើតកោលាហលជ្រួលជ្រើមឡើង ៗ ឯព្រះនាងទេវីក្រាបចុះទៀបព្រះបាទានៃព្រះមហាក្សត្រ ហើយទ្រង់ព្រះកន្សែងថា បពិត្រព្រះសម្មតិទេព, ហេតុអ្វីក៏ទ្រង់ធ្វើយ៉ាងនេះ? ម្ចាស់ថ្លៃជូនអើយ, ខ្ញុំម្ចាស់បើព្រាត់ប្រាស់ព្រះអង្គហើយ ខ្ញុំម្ចាស់កើតទុក្ខធ្ងន់ណាស់ ៗ មហាសត្វទ្រង់ព្រះចិន្តាថា “តែអញនៅក្នុងទីនេះ មុខជាបំពេញបរមត្ថបារមីមិនបានទេ, បើដូច្នេះអញទៅខាងក្រៅនគរវិញចុះ”, ទើបព្រះអង្គទ្រង់ទូន្មានពួកស្រីស្នំមាននាងទេវីជាប្រធាន នឹងពួកមហាជនមានអាមាត្យជាដើម ទ្រង់ដំកល់ព្រះអង្គក្នុងពជធម៌ដ៏ប្រសើរ ត្រេកអរឆ្អែតកាយឆ្អែតចិត្ត ទ្រង់ចាប់យកព្រះខាន់រតន៍ នាំអាមាត្យនឹងមាណពឥតក្បាលទៅឯឧទ្យាន ៗ

កាលនោះ ពួកអ្នកនគរនឹងពួកមហេសីស្រីស្នំ សឹងរំសាយសក់គក់ទ្រូង ចុះចាកប្រាសាទសង្ហាតទៅតាមស្ដេច ៗ ព្រះពោធិសត្វមិនអាចបង្គាប់ឲ្យមហាជនត្រឡប់វិញបាន ទើបព្រះអង្គត្រាស់សួរអាមាត្យថា អ្នកណាសោយរាជ្យក្នុងនគរពារាណសី? អាមាត្យក្រាបបង្គំទូលថា “សូមទ្រង់ព្រះមេត្តាប្រោស ព្រះអង្គហ្នឹងហើយ” ៗ ទើបស្ដេចយកព្រះខាន់គូសផែនដី ហើយបញ្ញត្តថា តែអ្នកណាតាមមករំលងគំនូសនេះនឹងត្រូវអាជ្ញាជាទម្ងន់ ៗ អ្នកនគរមិនហានដើររំលងគំនូស ក៏ប្រះដេកទល់ក្បាល

ត្រឹមតំនូសនោះទទៀលទៅមកៗ ស្រែកទ្រហោយំអឺងអាប់សព្ទគងរំពងឹ ៗ ព្រះពជាបានដល់ឧទ្យាន ក៏យកខ្សែមាសមកចងព្រះអង្គត្រង់ពាក់កណ្តាលខ្លួន ផ្ចាប់នឹងឈើយ៉ាងធំ ហើយត្រាស់ហៅមាណពឥតក្បាលថា អ្នកសប្បុរសនៅឯណា? ពួកអាមាត្យនាំមាណពឥតក្បាលចូលទៅជិត ទើបព្រះអង្គត្រាស់បង្គាប់អាមាត្យឈ្មោះសុបិថា នែសុចិ, ប្រស្ពង់យកព្រះខាន់មកកាត់ក្បាលអញឲ្យទៅគាត់ចុះ ៗ អាមាត្យឈរសំរក់តែទឹកភ្នែក ៗ ទើបព្រះមហាសត្វចាប់ព្រះខាន់ដោយព្រះអង្គឯង បំរុងនឹងកាត់ព្រះសិរសា បែរព្រះភក្ត្រទៅអាកាសត្រាស់ថា ទេវតាអើយ, សូមអ្នកមើលការបរិច្ចាគរបស់ខ្ញុំ, ដោយការបរិច្ចាគនេះ ខ្ញុំមិនប្រាថ្នាសម្បត្តិចក្រពត្តិមិនប្រាថ្នាសម្បត្តិសួគ៌កាមាវចរទាំង ៦ ជាន់ មិនប្រាថ្នាសម្បត្តិព្រហ្ម មិនប្រាថ្នាសម្បត្តិព្រះបច្ចេកពុទ្ធឡើយ, ខ្ញុំប្រាថ្នាឲ្យតែបានជាបច្ច័យនៃសព្វញ្ញុតញ្ញាណ ដែលធ្វើប្រយោជន៍ដល់សត្វក្នុងលោកទាំងមូលតែម្យ៉ាង ៗ លុះទ្រង់ត្រាស់យ៉ាងនេះហើយ ទើបពោលពាក្យជាគាថាថា

ពុទ្ធោ បពោធេយ្យំ ជនំ បស្សន្តោ ទុក្ខសោកិកំ
អហំ តារយន្តោ ជនំ ពុទ្ធោស្មិ អនុត្តរោ

ព្រះសព្វញ្ញុពុទ្ធ កាលឃើញប្រជាជនមានទុក្ខសោក រមែងដាស់ឲ្យភ្ញាក់រលឹកឡើង; ខ្ញុំក៏សូមឲ្យបានត្រាស់ជាព្រះពុទ្ធមានប្រាជ្ញាញាណរកប់មិនបាន បានចម្លងប្រជាជនដូច្នោះ ៗ

បើខ្ញុំមិនទាន់បានត្រាស់នៅឡើយ នៅអន្ទោលទៅក្នុងវដ្តសង្សារក្នុងកាលជាអនាគត ទោះបីប៉ុន្មានរយជាតិក៏ដោយ ខ្ញុំសូមឲ្យបានជាអ្នកបេះសំដែងធម៌ ដល់សត្វទាំងឡាយក្នុងទីប្រជុំលោកិយជន កុំឲ្យមានឃាក់ ។

មហាសត្វទ្រង់ត្រាស់យ៉ាងនេះហើយ ក៏ឥតមានភិតភ័យ បីដូចជាទាហានធ្លាប់ចុះស្នាមក្នុងសង្គ្រាម មានជ័យជំនះច្រើនដងមកហើយ ។ ស្ដេចទ្រង់ប្រុងប្រៀបនឹងកាត់ព្រះសិររបស់ព្រះអង្គ ។ គ្រានោះក៏កក្រើកញាប់ញ័រខ្ទរមហាប្រឹថពីដល់ទីបំផុតទឹក សូរស័ព្ទសន្ធឹកផ្គរលាន់ក៏លាន់ឮគគ្រាំគគ្រេង មានទាំងភ្លៀងផ្កា ៥ ព័ណ៌បង្អុរចុះមកដោយតេជះទានៃព្រះមហាសត្វនោះ ។ ទេវតាទាំងឡាយសឹងថ្វាយស័ព្ទសាធុការ, សេចក្ដីអស្ចារ្យកើតឡើងប្លែកៗ ជាអនេកប្រការ; ព្រះអង្គទ្រង់កាត់ព្រះសិរសាហើយប្រទានដល់មាណពឥតក្បាល; មាណពនោះឈរនិយាយថ្វាយពរថា "សូមព្រះអង្គជាសប្បុរសទ្រង់ប្រកបដោយសេចក្ដីសុខ"; និយាយតែប៉ុណ្ណោះក៏បាត់ក្នុងទីនោះទៅ ។

(មានត)

# ផ្នែកអក្សរសាស្ត្រ

## រឿងសៅរ៍សោយ

(សិរិសោរជាតក)

ព្រះមហាឧត្តមវិជ្ជា ផលញាណោ ប៊ុង-ប៉ម
អាចារ្យសាលាបាលីវត្តបទុមវតី ក្រុងភ្នំពេញ
រៀបរៀងតាមតម្រាយសាស្ត្រស្លឹករឹត

(តមក)

---

យាយចាស់ព្រួយហើយ ពុំអាចអត់ឡើយ សើចឡើងបកស់ៗ! ថា"ទៅមិនទាន់ បានឃើញទឹកច្បាស់ ឈោមកក្រឡះ គិតកាត់បំពង់ៗ បើរឿងនេះគេច ពុំបានសម្រេច រូបឃើងនេះគង់ បានក្តីអៀនខ្មាស អាម៉ាស់យូរលង់ ណ្ហើយសុំបង្អង់ គិតបង់សិនក៏"ៗ ព្រឹកព្រានជាងដាក់ យាយតាពីរនាក់ ស្មៀកពាក់អាត្មា ហើយចូលទៅរក យកពូជនានា ទឹងអាលល័ណា ទៅចំការហោងៗ រកសព្វៗទៅ ពុំឃើញមានទៅ បាត់ទៅជាមួង យាយថា"ខ្ញុំខ្ចប់ គ្រប់សព្វហ្មត់ហ្មង កាលសព្វ១ដង ទៅហ្នឹងធម្មតាៗ ទើបតែយប់ជ្រៅ នេះមានមនុស្សក្រៅ មកស្ទាក់អាត្មា បាត់ពូជទាំងហ្នឹង ពុំដឹងទៅណា"; ព្រះមហាក្សត្រា ព្រួយហើយឆ្លើយថ្កានៗ ថា"ខ្ញុំនេះណា ពុំលួចយាយតា មេត្តាប្រោសប្រាណ ខ្ញុំលួចពូជឈើ មកធ្វើអ្វីបាន សូមកុំនឹកស្មាន

ថាខ្ញុំចោរឡើយ ។ គ្រាន់តែឲ្យស្នាក់ ពំនឹងពឹងពាក់ គុណណាស់ ទៅហើយ បើពុំដូច្នោះ ឆែកចុះលោកអើយ បើឃើញពិតហើយ ខ្ញុំពុំបើថា" ។ យាយតាទាំងពីរ ស្តាប់សព្វពាធី ម្នាម្នីត្រួតត្រា ឆែកឆេ សព្វគ្រប់ បានកប់កូសារ ឃើញជាយនោះណា ចង់ជាគំនួច ។ កើត ក្តីកង្វា ទើបសូមត្រួតត្រា កូសាដែលកួច ស្រាប់តែពេលនោះ បាប គ្រោះតិចតួច ដែលទ្រង់ផ្តើមផ្តួច ផ្ញើពីបុព្វ ។ បណ្តាលឲ្យពេជ្រ ដែលទ្រង់ចង់វេច គេចកៃខ្វែរ ទៅជាពូជណា យាយតាទាំងទ្វេ ពុំអត់ ទៀតទេ តាំងជេរជៀលថា ។ "អាចោរអប្បល័ក្ខណ៍ អញឲ្យផ្ទះស្នាក់ ពឹងពាក់អាត្មា ហ៊ានលួចពូជអញ គួរខ្មាញ់ណាស់ណា គ្រាប់ទឹងតើអា ប្រាថ្នាធ្វើអ្វី" ។ ព្រះមហាក្សត្រា ឮហើយឆ្លើយថា "មេត្តាប្រណី ខ្ញុំពុំ អ្នកលួច លបលួចអ្វី ។ ហ៊ានពេជ្ររង្សី នៃខ្ញុំពិតណា ។ ម្តេចលោក គ្រេវគ្រោធ បំពានបំពោត មកចោទខ្ញុំថា លបលួចគ្រាប់ពូជ ឃើញ ដូចមុសា សូមលោកយាយតា កុំថាច្នោះឡើយ" ។ បានឮហើយសោត យាយតារឹងគ្រោធ ប្រឡោតឥតស្បើយ ជេរថា "អាកេ! លួចគេពិត ហើយ នៅរឹងចចូងឆ្លើយ នៃវើយអាខ្វា! ។ អញឃើញទឹងក្អែក រឹងឈរដដែក ថា ពេជ្រផងអា មុខអាក់ទេច បានពេជ្រពីណា កុំឈរតវ៉ា មុសាណាវ៉ី!" ។ ថាហើយនាំគ្នា ប្រួតរ៉ាយរាជា ឥតត្រាប្រណី ដេញចេញពីផ្ទះ រហ័ស រឹ ៗ យកពេជ្ររង្សី ដែលក្លាយនោះទុក ។ ព្រះបាទសិរីសារ ទុក្ខក្តួល អួលក្តៅ ហ្មងសៅខ្មៅមុខ ចាកផ្ទះយាយតា យាត្រាបុកលុក ណាមួយ សោយទុក្ខ បុកចប់សព្វកាយ ។ ព្រះពោធិសត្វ ពន្ទុកប្រមាត់ ទុកឥត

រសាយ រកទោសខុសគ្មាន កូនប្រាណអង្គកាយ ស្រាប់តែគេហៅ ឥតបីមេត្តា ។ ស្តេចចរចេញទៅ ពុំដឹងទីដៅ ឆ្ពោះទៅទីណា កន្លែងកណ្តាប ត្រមោចកំព្រា តែឯងឯកា ឥតគ្នាពីរផង ៗ លេចវាលចូលព្រៃ សឹងស្បូវស្បាតព្រៃ ដាសព្រៃនោះហោង ហួសពីព្រៃក្រាស់ ដល់វាលធំផង រូតរះច្ងុះច្ងង ពុរពងបាទា ៗ លំបាកយ៉ាកអង្គ ស្មារតីហ្វីនហ្វង់ ចិត្តផង់យាត្រា ទ្រាំគំដៅថ្ងៃ ក្សត្រថ្ងៃឈឺផ្សា ពុរពងប៉ុទា លីលាទាំងទុក្ខ ៗ ទ្រង់ព្រះកន្សែង សោកាថ្វាថ្វែង កន្លែងកណ្តុក កណ្តាបខ្ទោបក្រំ ដាលដំដោយទុក្ខ ទឹកនេត្រហូរច្រុក ស្រក់ស្រោចក្រា ៗ ព្រះបាទក្សត្រថ្ងៃ នឿយនិត្យល្ហិតល្ហៃ ស្ទើរក្ស័យជីវ៍ អត់ក្រយាស្ងោយ ទន់ខ្សោយកាយា ពេងពោងអង្គា វេទនាអស់អង្គ ៗ បរមបមកត ស្រេចស្តេចគេចឈប់ ក្រោមម្លប់ហើយគង់ សំរាកកាយា ក្សត្រាវរវង្ស ត្រមោចត្រមង់ លន្ទង់ណាស់ណា ៗ ពុំតែសត្វស្រែក ក្នុងព្រៃវិវេក សត្វសេកសារិកា លលកចាបព្រាប ទំទៀបគ្នាហ៍ មាន់ព្រៃទទា អាអូតប្រចៃឡ ៗ ប៉ោលគោកតាកើ យំព្រុកអៅ ទំនៅដកម៉ៃ ករវិក ឈ្មោលញី យំពីរោះព្រៃ ស្រឡាត់ទាំងព្រៃ សូរឆ្ងាយលន្ទោច ៗ គេងកងទុកទ្រូ កូហ៍ងហូហូ ទាំងលលកខ្មោច យំដោយព្រៃព្រឹក្ស គួរទឹកស្រណោច សូរមាត់ស្វាទោច លន្ទោចទៅឆ្ងាយ ៗ អង្គព្រះប្លាស់ប្លង ពុំមាត់សត្វផង កូនទ្រូងស្មើរឆ្ងាយ ឥតមានគ្នីគ្នា កំព្រាអង្គកាយ ទុក្ខឥតរសាយ រលាយឡើយណា ៗ កាលព្រះបមកត ស្តេចទ្រង់គង់ឈប់ ក្រោមម្លប់ព្រឹក្សា ទ្រង់គង់សញ្ជឹង ពុំដឹងទីងថា ទៅឋានឋានណា

ក្សត្រារឹងទុក្ខ ៗ បន្តិចរាជា ក្រោកឡើងម្នីម្នា លីលាទៅមុខ កណ្ដាន
ឯងឯក ជ្រៀតជ្រែកវែកលុក ពារពានភនរុក បានទុក្ខស្ទើរមរណ៍ ៗ
យូរទៅទសពល ក្សត្រក្សាន្តបានដល់ អចលនគរ នៅព្រឹកនោះណា
ក្សត្រាកូធរ ឃើញស្វាមីកវរ ត្រាច់ចរសូមទាន ៗ បរមចមកព
ស្ដេចទ្រង់រង់ឈប់ ទតគ្រប់សព្វប្រាណ លុះស្វមស្រឡះ ទើបព្រះ
ផ្ទាស់ថ្កាន បួមប៉ឹងតែងប្រាណ សូមទានដែរណា ៗ ពេលនោះទស
ពល បានអស់កស្តុផល ល្មមស្កល់អាត្មា ស្រេចស្ដេចគេចក្រោយ
មកសោយក្រយា ត្រង់តៀម ១ ណា ក្នុងផ្សារជិតនោះ ៗ ជាតៀម
លក់ទំ មានតូចមានធំ សក្តិសមឥតៈមោះ សោយស្រេចស្ដេចស្ដែង
ថ្វាថ្វែងចំពោះ ប្រាប់ស្រីលក់នោះ ដោយស្មោះចិន្តា ៗ ថា "ហៃប្អូន
ស្រី ! ខ្ញុំបងក្រក្រី ឥតអ្វីពីសារ ចង់សុំទំនាង សូមនាងមេត្តា ឲ្យទាន
តិចពា គោត្តាបានម្ដង" ៗ ឯស្រីលក់ទំ យល់ព្រះបរម ឧត្តមច្បាស់
ច្បង មានរូបល្អស្រស់ ប្លែកអស់ប្រុសផង មានចិត្តជិតចង់ ប៉ុនប៉ង
ស្នេហា ៗ ទើបនាងរើសរក ទំនែកចែកមក ពន្ធកក្សត្រា ស្ដេច
ទទួលយក ទំមកហើយណា ក៏បរិភោគា នៅទានោះនៃ ៗ សោយ
ស្រេចស្ដេចស្នាក់ ចាំទឹងពឹងពាក់ សំណាក់អាស្រ័យ នៅពនទោះថ្កាន
កំសាន្តព្រ ទ័យ អស់២-៣ថ្ងៃ ឥតបីទៅណា ៗ រយៈស្នាក់នៅ
ស្ដេចស្ដែងតែងទៅ សុំទូរក្រយា ពីតៀមជិតនោះ ឥតលោះថ្ងៃណា
ចិញ្ចឹមអាត្មា ជាប់ជាប្រក្រតី ៗ រីដំណើរនេះ បញ្ឈប់ទប់ស្មុះ ត្រឹម
ណោះឯងខ្មី ទឹងតារថ្វាថ្វង់ សំដែងសេចក្ដី ពីព្រះចក្រី ធិបតីមណ្ឌល ៗ

កាលណោះមែនមាន ស្ដែងស្ដេច១ព្រាណ សំពនកាយពល គង់ក្នុង
នគរ បវរទិមិល ឈ្មោះនោះសោតសល់ អចលនគរ ៗ រីឯស្ដេចនោះ
មាននាមចំពោះ ជាឈ្មោះបវរ ថាកិន្នវត្ត ប្រាកដនាមករ មហេសីបវរ
ល្អល្អិមប្រិមប្រិយ ៗ មហេសីនោះ នាមសមចំពោះ សុទ្ធវតី មានបុត្រមួយ
ជាត្រ្មយប៉ែតី ល្អល្អះលើសស្រី បុរីនគរ ៗ នាមករសោភី សុខត្ដទេវី
ជាទីត្រេកអរ ល្អល្អះរស្មី ហាក់ស្រីអប្សរ ស្រស់បស់បវរ ល្អល្អះ
ណាស់ណា ៗ ព្រះជន្មប្អូនចប់ ប្រាំមួយជណ្ដាប់ គប់ព្រះវស្សា
សក្តិសមទ្រង់ទ្រាយ ធោមធាយកាយា ពេញចិត្តមាតា បិតាពេកក្រៃ ៗ
យប់មួយនោះណា ព្រះបាទក្សត្រា សោយព្រាហើយនៃ ដល់ពេលពាទុះ
បច្ចុសសម័យ ជិតព្រឹកក្សត្រថ្ងៃ តើនបាកបន្ទុំ ៗ ទ្រង់ដម្រិះថា
“ព្រះរាជធីតា អាត្មាក៏ធំ កាលណាទៅហ្ន៎! ទើបវរឧត្ដម មានគូផ្គួផ្គង
សក្តិសមល្មមគ្នា” ៗ ព្រឹកព្រានស្វាងច្បាស់ បរមអម្ចាស់ ទ្រង់
ត្រាស់បញ្ជា ឲ្យបុរោហិត ចូលជិតម្ទីម្ទា គាល់ព្រះរាជា វេលាឆាប់ៗ ៗ
កាលរាជហោរា មកដល់ហើយណា ក្សត្រាទ្រង់ប្រាប់ ឲ្យមើលរាសី
បុត្រីចំណាប់ ជាគូសប្អាប់ ប្រញាប់ឆាប់ខ្ញី ៗ “ហោរើយឥឡូវ
បុត្រីអញគួរ រាំនៅគ្មានប្ដី ចូរហោរគុណហារ ផ្ដាភសីអំពីបុត្រី
មានប្ដីកាលណា ។ រីប្ដីនោះឯង ជាតិជាស្ដេចស្ដែង គួរស្នេហ៍បេស្ដា
ឬមួយអ្នកខ្សត់ ទុគ្គតឯកា ចូរហោរទាយថា ឆាប់រ៉ហោរអើយ” ៗ

(មានត)

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាជការចាស់បើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

## កណ្ឌទី ២១

តាំងពីខុងយ៉ុងនាំរឿងរ៉ាវទៅក្រាបទូលព្រះបាទហៀនតេ រហូតដល់ចូឆូគិតលើកទ័ពទៅចាប់មាត់ថងនឹងឡៀពី ដែលសមគំនិតគ្នានឹងតាំងស៊ិន ។

---

លុះវេលាព្រឹកឡើង នាហ្មឺនសព្វមុខមន្ត្រីទាំងពួងចូលក្រាបបង្គំគាល់ព្រះពជាព្រមគ្នា ៗ ខុងយ៉ុងក៏នាំរឿងរ៉ាវនោះទៅក្រាបបង្គំទូលថ្វាយព្រះចៅហៀនតេ។ ទ្រង់ទតហើយមិនបានត្រាស់ថាប្រការម្ដេច ទើបយកសំបុត្រនោះទៅឲ្យចូឆូហើយត្រាស់ថា ការទាំងនេះតាមតែមហាឧបរាជនឹងរិះគិតចាត់ចែងចុះ ៗ ចូឆូបានទទួលព្រះតម្រាស់ហើយ លុះត្រឡប់មកផ្ទះក៏ឲ្យបំរើទៅហៅយ៉ុអេង ៗ ចូលមកដល់គំនាប់ចូឆូ ៗ មិនបានទទួលគួរសមមិនបានប្រស្រ័យតាមយ៉ាងទំនៀមធម្មតា ៗ យ៉ុអេងមានសេចក្ដីតូចចិត្តណាស់ក៏នៅស្ងៀមហើយដកដង្ហើមធំ ទើបនិយាយដោយកំឡាំងវោហារ

ថា ផែនដីនេះធំទូលាយណាស់ ប្រសិនបើខាតបង់មនុស្សម្នាក់ចេញទៅ ក៏មិនជាអ្វីណាស់ណាទេ ។

ចូចូបានឮ យ៉ុអេងនិយាយប្រៀបធៀបដូច្នោះ មិនទាន់ដឹងជាប្រាកដ ក៏សង្កេតខុសទៅ ទើបសួរថាផែនដីយើងនេះ ទីប្រឹក្សានិងសេនាទាហាន ដែលមានថ្វីដៃក៏ច្រើន ហេតុម្តេចខ្លួនក៏ថាមិនមានមនុស្សល្អ ។ យ៉ុអេង បានស្តាប់ដូច្នោះ ឃើញថាចូចូដឹងមិនដល់ ទើបតបថា មហាឧបរាជ អ្នកថាមានទីប្រឹក្សានិងទាហានដែលមានថ្វីដៃនោះតើនរណាខ្លះ? ខ្ញុំបាទ មិនស្គាល់ច្បាស់ ។ ចូចូថា ស៊ុនហុក, ស៊ុនហ៊ុវ, គុយកែ, ធៀយ៉ុក, ទីប្រឹក្សារបស់យើង ៤ នាក់នេះ សុទ្ធតែមានជំរះប្រាជ្ញាយ៉ាងជ្រៅទូលាយ សូម្បីសៀវហោនិងតាន់ផេង ដែលជាអ្នកប្រាជ្ញរបស់ព្រះចៅកោចោពី បុរាណក៏មិនបានស្មើ ដល់ទាំងទីប្រឹក្សារបស់យើង, ឯទាហានឯករបស់ យើងដែលមានថ្វីដៃនោះគឺ កៀវលៀវ, ខៅធូ, លីទៀន, ឆាក់ជិន ៤ នាក់នេះ សុទ្ធតែមានថ្វីដៃខ្លាំងពូកែជំនាញស្ទាញស្ទាត់ក្នុងការរឿណរង្គ សង្គ្រាម លើសជាងឆៀមផែងនិងម៉ាប៊ូដែលជាសេនាព្រះចៅហានគង់ប៊ូ ទៅទៀត. ឯលីយ៉យនិងម៉ាន់ថង ២ នាក់នេះ ជាទីប្រឹក្សាផងរបស់យើង ហែហូទុន, អ៊ុគីម, ស៊ីឡុង ជាសេនាយ៉ាងនេះក៏ពៈរយនាក់ ហេតុម្តេចខ្លួន ថា ផែនដីនេះនឹងរកអ្នកមានសតិបញ្ញានិងថ្វីដៃខ្លាំងពូកែមិនមានសោះ ។

យ៉ុអេងបានឮដូច្នោះ ក៏អស់សំណើចហើយតបថា លោកមាន ប្រសាសន៍នេះ ខ្ញុំមិនយល់ឃើញផងទេ មនុស្សទាំងអស់នេះខ្ញុំក៏បាន ដឹងយល់ស្គាល់ គំនិតមារយាទនិងជំរះប្រាជ្ញាហើយនិងថ្វីដៃអស់ហើយ

ឯស៊ុនហុកនោះមុខប័ដ្ខចជាគេយំ គួរតែប្រើទៅសួរជម្ងឺ ឬ សក្ការសព, ស៊ុនហ៊ីវនោះសមតែធ្វើអ្នកក្កុករក្សាសព, ធៀយ៉ុកនោះសមតែប្រើឲ្យអង្គុយចាំជើងក្រាន, គុយកៃនោះសមតែតែងឃ្លាំងទឹងឲ្យមើលបទសាស្ត្រា, តៀវលៀវនោះសមតែវាយស្គរទីងរគាំង, ទៅធូនោះសមតែឃ្វាលគោទឹងសេះ, លីទៀននោះសមតែឲ្យមើលពាក្យក្តី, ផាក់ជិននោះសមតែប្រើឲ្យដើរចែកសំបុត្រ, លីយ៉ែយសមតែប្រើឲ្យជុសខាត់គ្រឿងអាវុធ, មាន់ថងនោះសមតែប្រើឲ្យផឹកស្រាទំពាជ្ជូងជ្រូក, អ៊ុកិមនោះសមតែប្រើឲ្យរកក្តារទៅធ្វើបន្ទាយ, ស៊ុយ្យុងនោះសមតែប្រើឲ្យកាប់ជ្រូកលក់, ហែហូទុននោះសមតែប្រើឲ្យចាំរក្សាខ្លួន កុំឲ្យសត្រូវកាត់ក្បាលទីងជើងធ្វេងស្តាំទៅបាន, ឯទ័ព្រើក្សាទឹងសេនាទាហានក្រៅអំពីនេះ សមតែប្រើឲ្យរែកស្បៀងជូនកងទ័ព ដែលលោកទឹងរាប់ថា មានដំរេះប្រាជ្ញាខ្លាំងពូកែនោះ ខ្ញុំមិនឃើញផងសោះ ។

ប៉ូធ្វបានស្តាប់ដូច្នោះក៏ខឹងខ្លាំងណាស់ ទើបសួរថា ខ្លួនមកតិះដៀលទ័ព្រើក្សាទឹងសេនាទាហានរបស់យើងដូច្នេះ ខ្លួនចេះដឹងអ្វីខ្លះឲ្យលើសគេ ។ យ៉ីអេងតបថា ខ្ញុំចេះមើលផ្កាយលើអាកាស មើលធ្លុះរហូតទៅក្រោមផែនដី ខ្ញុំចំណានស្ទាត់មើលដឹងយល់ស្គាល់ភូមិលំនៅល្អទីងអាក្រក់ ១ វិញទៀត ខ្ញុំបានពិតទូលព្រះមហាក្សត្រ ឲ្យតាំងនៅក្នុងយុត្តិធម៌ ដូចព្រះចៅធៀវស៊ុននោះក៏បាន ប្រការ ១ ខ្ញុំនឹងបញ្ចុះបញ្ចូលទូន្មានប្រជាអាណាប្រជានុរាស្ត្រ ឲ្យមានចិត្តសុចរិតទៀងត្រង់ទឹងផែនដី ដូចគ្រាខុងជូទឹងផាន់អៀន ដែលជាគ្រូប្រដៅមនុស្សទាំងពួងឲ្យទៀងត្រង់ក៏បាន

ដែលខ្ញុំសន្ទនានឹងលោកគ្រានេះ ឧបមាដូចជានិយាយនឹងមនុស្សឆ្កួត ដែលមិនចេះភាសាមនុស្ស ។

គៀវលៀវបានឮដូច្នោះខឹងណាស់ ហូតគ្រប៉ីចេញនឹងកាប់យ៉ុអេង ។ បូធូក៏ហាមឃាត់ថា កុំអាលធ្វើវីវរឡើយ ព្រោះសព្វថ្ងៃនេះ យើងនៅខ្វះមនុស្សម្នាក់សម្រាប់វាយស្គរទទួលភ្ញៀវ បើទៅសម្លាប់យ៉ុអេងចេញក៏ឃើញថាស្លាប់ទៅទទេ ត្រូវតែយកវាទៅប្រើឲ្យវាយស្គរទទួលភ្ញៀវល្អជាង ។ គៀវលៀវក៏ស្ដាប់ពាក្យបូធូ ។ ក៏ប្រើយ៉ុអេងឲ្យទៅចាំវាយស្គរ ទទួលភ្ញៀវ ។ គៀវលៀវថា យ៉ុអេងនោះនិយាយពាក្យចាក់ដោតដល់លោកច្រើនណាស់ ហេតុម្ដេចបានជាលោកអត់ធន់មិនសម្លាប់វាចេញ ។ បូធូតបថា យើងបានឮដំណឹងរឿយៗថា យ៉ុអេងនេះជាមនុស្សមានសតិបញ្ញាក្លាហាន គ្មានកោតញញើតនរណាសោះ ដែលវាមកនិយាយទ្រគោះឲ្យយើងនោះ បើយើងទៅសម្លាប់វាចេញ មនុស្សទាំងពួងនឹងគរហានិន្ទាថា មានមនុស្សចេះដឹងល្អហើយសម្លាប់ចោលជាអសារប្រការ ១ អ្នកមានសតិបញ្ញាឯណាប្រាថ្នាចូលមកនៅនឹងយើង ក៏ឲ្យរួញព ញញើតថាយើងមិនបានទំនុកបំរុងមនុស្សល្អ ឯយ៉ុអេងនេះជាមនុស្សឆ្កួតចេះ យើងត្រូវយកខ្លួនវាទុកឲ្យវាយស្គរ ។

លុះថ្ងៃ ១ បូធូឲ្យអញ្ជើញនាហ្មឺនសព្វមុខមន្ត្រីមកស៊ីលៀង, យ៉ុអេងពាក់អាវកណ្ដាចចេញមកវាយស្គរទទួលភ្ញៀវ, នាហ្មឺនទាំងពួងបានឮសំឡេងស្គរដែលយ៉ុអេងវាយនោះក៏ពីរោះចាប់ចិត្តបង្កើតកិស្សរង់, តាហាន ដែលបំរើភ្ញៀវឃើញយ៉ុអេងសំដែងអាកប្បកិរិយាមិនសមគួរ ក៏និយាយ

ជាថ្ងៃនេះមហាបោកជទទួលក្បៀវធំ ហេតុម្តេចខ្លួនមកពាក់អាវកណ្តាប ដូច្នេះ ៗ យ៉ុអេងបានឮទាហានស្រែកថាដូច្នេះ ក៏ដោះអាវទឹងស្បែកជើងចេញអស់ ក្លែងវាយស្គរនៅតែខ្លួនទទេ ៗ នាហ្មឺនទាំងពួងឃើញដូច្នោះ ក៏ទឹងអៀនខ្មាសយកដៃខ្ទប់មុខទាំងអស់គ្នា ៗ ចូច្ចូឃើញយ៉ុអេងធ្វើដូច្នោះក៏ខឹងណាស់ស្រែកថា ឯកធ្វើផ្តេសផ្តាសដូច្នេះប្រាថ្នាទឹងឲ្យអញលក់ឈ្មោះឬ? ៗ យ៉ុអេងឆ្លើយតបថា អញដោះអាវទឹងស្បែកជើងចេញនៅតែខ្លួនទទេដូច្នេះ ដោយយល់ថា ជាការចេញមុខ ព្រោះកាយនេះជាទីស្អាត មាតាបិតាឲ្យអញកើតមក ៗ ចូច្ចូថា ឯងឃើញថារូបកាយនរណាស្មោកគ្រោកនោះ ៗ យ៉ុអេងតបថា ខ្លួនមិនចូលចិត្តឬ? យើងនឹងអធិប្បាយរូបកាយស្មោកគ្រោករបស់ខ្លួនឲ្យស្តាប់ : ប្រការ ១ ខ្លួនមិនស្គាល់ច្បាស់មនុស្សល្អនឹងអាក្រក់ ភ្នែករបស់ខ្លួននោះជាទីស្មោកគ្រោក, ប្រការ ១ ដែលនរណាមានចិត្តសុចរិតទៀងត្រង់យល់ឃើញថាខ្លួនធ្វើការអាក្រក់កំរិលកហាមប្រាមខ្លួនដោយសុចរិត ខ្លួនមិនបានស្តាប់ ត្រចៀករបស់ខ្លួនក៏ជាទីស្មោកគ្រោក, ប្រការ ១ ខ្លួនមិនមានចិត្តជូរទូលាយរួសរាយរាប់អាននាហ្មឺនសព្វមុខមន្ត្រី នឹងចៅហ្វាយខែត្រទាំងពួង ហើយខ្លួនគិតក្បត់ចិត្តប្រទូសរ៉ាយ ឲ្យព្រះចៅហៀនតេព្រួយព្រះរាជហឫទ័យបានសេចក្តីក្តៅក្រហាយ ចិត្តរបស់ខ្លួនក៏ជាទីស្មោកគ្រោក, សព្វថ្ងៃនេះមនុស្សក្នុងផែនដីរាប់អានថាយើងមានដំរេះប្រាជ្ញា ហើយខ្លួនមកប្រមាថមើលងាយឲ្យយើងជាអ្នកវាយស្គរ ព្រោះមិនបានស្គាល់យើងជាមនុស្ស

ល្អ ពេលនេះខ្លួនគិតការដ៏ធំពន្លឹក មិនគួរខ្លួនមិនកប់អានយើងជាអ្នកមាន សតិបញ្ញាសោះ ៗ

ខុនយ៉ុងបានឮយ៉ុអេងជាដូច្នោះ ខាងចង្ក្រមិនអត់ទីង្រ្គោធទីងឲ្យសម្លាប់យ៉ុអេងៗសារ ខុនយ៉ុងក៏គំនាប់ចុច្ចូហើយថា កាលពីដើមខ្ញុំបាទឃើញថា យ៉ុអេងជាមនុស្សមានសតិបញ្ញា ទើបបង្ហួលមកដើម្បីនឹងឲ្យទៅបញ្ចុះបញ្ចូលឡេវពៀវ ស់ឡូវយ៉ុអេងនិយាយទ្រគោះមើលងាយលោកជាច្រើនហួសពេក ទោសនោះដល់ស្លាប់ ខ្ញុំបាទសុំអាយុជីវិតទុកម្តងចុះ ៗ ចង្ក្របានស្តាប់ខុនយ៉ុងនិយាយក៏សួរទៅយ៉ុអេងថា ទោសដែលខ្លួនពោលប្រមាថមើលងាយដល់យើងនោះ យើងលើកលែងទោសហើយ តែខ្លួនអួតអាងថាមានដំរេះប្រាជ្ញាល្អនោះ យើងនឹងប្រើឲ្យទៅនិយាយបញ្ចុះបញ្ចូលឡេវពៀវចៅហ្វាយស្រុកកេងជីវ បើបានការនឹងឲ្យបំណាច់រង្វាន់ ហើយនឹងតាំងឲ្យខ្លួនធ្វើនាហ្មឺនធំ ៗ យ៉ុអេងមិនព្រមទទួលពាក្យចង្ក្របើ ចង្ក្រឃើញយ៉ុអេងធ្វើពាដើយកន្តើយ ក៏ជយខ្លួនទៅឡប ប្រាប់ស៊ុនហុកទីងនាហ្មឺនទាំងពួងថា ឲ្យទៅរៀបតុតាំងនៅទ្វារទិសខាងកើតឲ្យស្រេច បើឃើញយ៉ុអេងចេញទៅដល់ទ្វារស្រុកកាលណា ត្រូវនាំគ្នាសែនបញ្ជូនឲ្យចេញទៅផុតដែនស្រុកទៅចុះ ៗ

ស៊ុនហុកទីងនាហ្មឺនទាំងពួង ក៏ត្រូវទៅរៀបតុតាំងពលិការទុកជាស្រេចតាមពាក្យចង្ក្របង្គាប់ ហើយស៊ុនហុកនិយាយទីងនាហ្មឺនទាំងពួងថា បើយើងសែនបញ្ជូនហើយ អ្នកទាំងឡាយកុំបីនិយាយសាកសួរយ៉ុអេងថាប្រការម្តេចឡើយ ៗ

ចូចូក៏និយាយនឹងយ៉ុអេងទៀតថា បើខ្លួនមិនព្រមទៅ យើងត្រូវសម្លាប់ករិយាបុត្ររបស់ខ្លួនឲ្យអស់ ៗ ពេលនោះយ៉ុអេងក៏ព្រមទទួលពាក្យថានឹងចេញទៅបញ្ចុះបញ្ចូលឡៀពៀវ ៗ ចូចូក៏បង្គាប់ឲ្យយកសេះ ១ មកឲ្យយ៉ុអេងជិះ ហើយឲ្យទាហាន ២ នាក់កាន់កាប់ទៅជាមួយនឹងយ៉ុអេងផង ៗ ឯយ៉ុអេងនឹងទាហាន ២ នាក់ក៏ជិះសេះ នាំគ្នាទៅដល់ទ្វារស្រុកទិសខាងកើត មិនបានឃើញនាហ្មឺនទាំងពួងចំអកដំទយដូចម្តេច យ៉ុអេងចុះពីលើសេះចូលទៅឈរកណ្តាលទីប្រជុំនាហ្មឺនទាំងពួង ហើយយ៉ុអេងក៏ធ្វើជាយំ ៗ ស៊ុនហុកមិនបានដឹងកលយ៉ុអេងក៏សួរថា មហាឧបភជប្រើខ្លួនឲ្យទៅជាកជការ ហេតុម្តេចបានជាឈរយំស្រែកដូច្នេះ ៗ យ៉ុអេងឆ្លើយតបថា យើងយល់ឃើញអ្នកទាំងអស់គ្នា ឧបមាបីដូចជាសាកអសុក យើងដើរចូលមកដូចជានៅកណ្តាលអសុក ទើបមានសេចក្តីអាណិតយំស្រែកទឹកភ្នែកដូច្នេះ ៗ

ស៊ុនហុកនឹងមន្ត្រីទាំងពួង លុះបានឮយ៉ុអេងនិយាយដូច្នោះក៏ឆ្លើយតបថា ដែលថាខ្លួនយើងជាអសុកនោះ ខ្លួនអ្នកឯងក៏ជាខ្មោចឥតក្បាលដែរ ៗ មន្ត្រីទាំងនោះក៏នាំគ្នា ចង់ប្រឡោតហូតក្រប៊ីប្រែងនឹងកាប់យ៉ុអេង ៗ ស៊ុនហុកក៏ហាមឃាត់ថា យ៉ុអេងនេះឧបមាដូចជាសត្តតិរច្ឆានទៅហើយ អ្នកពលគ្នានឹងមកប្រកាន់ទោសសម្លាប់វាចេញនោះគ្មានប្រយោជន៍អ្វីសោះ នាំឈាមប្រឡាក់ក្រប៊ីទេ ៗ យ៉ុអេងឆ្លើយតបថា ខ្លួនយើងមានសេចក្តីខឹងនឹងមិនខឹងគង់នៅចេះនិយាយត្រឹមត្រូវ ហេតុម្តេចអ្នកឯងដំណាលថា យើងជាសត្តតិរច្ឆាន ឯអ្នកឯងពលគ្នាឧបមាដូចសត្វមមាចមិនខ្វាចគំនរ

ក្មេង នាំគ្នាហើរឡើងចូលក្នុងក្មេងនោះក៏ខឹងដល់ទូវសេចក្ដីស្លាប់ ៗ នាហ្មឺនទាំងអស់ស្លាប់ហើយក៏ខឹងខ្លាំងណាស់ តែហាមប្រាមគ្នាឲ្យនៅស្ងៀម ហើយតាំងអុជទៀនធូបសែនបណ្ដាញយុំអេងឲ្យចេញទៅ ហើយក៏នាំគ្នាត្រឡប់មកផ្ទះវិញ ៗ

យុំអេងនិងទាហាន ២ នាក់ ក៏នាំគ្នាទៅដល់ស្រុកកេងជ័វ ទើបចូលទៅនិយាយនឹងឡៅពៀវ តាមដែលចូឆឲ្យទៅនិយាយបញ្ចុះបញ្ចូល ហើយយុំអេងនិយាយអួតបេះដូង លើកខ្លួនបន្ទាបគេ ធ្វើកិរិយាមើលងាយឡៅពៀវថាជាមនុស្សល្ងង់មិនមានជំរេះប្រាជ្ញា ៗ ឡៅពៀវឃើញកិរិយាយុំអេងចរចាមើលងាយដូច្នោះក៏ខឹងណាស់ តែគិតទប់ចិត្តបាន ព្រោះចិត្តឡៅពៀវនោះ ជាមនុស្សធូរទូលាយស្រកាយកប់អានអ្នកទាំងពួង ហើយនិយាយនឹងយុំអេងថា ដែលចូឆូប្រើឲ្យអ្នកឯងមកនិយាយបញ្ចុះបញ្ចូលយើង ៗ នៅមិនទាន់ចុះចិត្តទេ បើកាលណាអ្នកឯងទៅនិយាយបញ្ចុះបញ្ចូលហានចបៅហ្វាយស្រុកកាំងហែ ព្រមល្មមចុះចូលទៅនឹងចូឆូហើយ យើងនឹងចុះចូលព្រមផង យុំអេងក៏លាឡៅពៀវទៅស្រុកកាំងហែទៀត ៗ

(មានត)

ដំណឹងតាមខ្យល់ក្នុងកន្តារ

# លោក ផេង-ជ្រើវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

( តមក )

---

ចំណែកអ្នកកំឡោះនិងនាងនារីដើរឆ្ងាយបន្តិចទៅ, មានអារ៉ាប់ម្នាក់ញែកហ្វូងមនុស្សដើរចូលមក អារ៉ាប់នេះត្រូវនៅក្បែរនោះក្នុងវេលាកើតហេតុនោះ, គេឃើញអាការជំលោះរវាងអ៊ុស្មាអ៊ុល និងនាយទាហានរង គ្មានខ្វះត្រង់សេចក្តីណា ព្រមទាំងការចរចាគ្នាតមកទៀត ។ គេចូលទៅរកនាយទាហានដែលទើបនឹងអត់ទោសឲ្យអ៊ុស្មាអ៊ុល នៅកណ្តាលមហាជន ។ គេជូនគំនាប់តាមទំនៀមស្រុក ហើយនិយាយថា:

— “ ខ្ញុំឈ្មោះ រស្សីម បេន អាប់ដាឡ: ” រួចស្ងៀមមួយស្របក់ទើបចាប់និយាយទៀតថា :

— “ លោកមិនដឹងទេឬ កំឡោះដែលលោកមើលឃើញនុះ គឺជាមនុស្សឃាដទេតើ? ” ។

នាយទាហានគួរតែសំឡឹងអារ៉ាប់នោះសព្វ ។ ក៏ស្គាល់ឈ្មោះស្គាល់សារគារ ថាគេនេះជាមេភូមិក្នុងក្រុងតូចមួយនឹងគេដែរ តែពាក្យអ្នកស្រុកពោលថាគេជាមនុស្សប្រណាននឹងអ៊ុស្មាអ៊ុល ។

នាយទាហានដែលមានរឿងហេតុជាមួយនឹងអ៊ុស្មាអ៊ុលឆ្លើយថា:

– ‹‹ កូនប្រុសរបស់លោក អៃយ៉ាដ ចូលក្នុងបទសម្លាប់ដើម្បីការពារខ្លួន ។ ម្យ៉ាងទៀត រឿងនេះ ជាកិច្ចការរបស់យើងទេ ព្រោះនិយាយអំពីការស្លាប់របស់ទាហានយើង ។ នៃសំឡាញ់ ត្រូវចាំថា គេមិនមានប្រយោជន៍អ្វីនឹងទៅជួយរវល់គ្រាប់ស្រូវក្នុងកញ្ជើដទៃឡើយ » ។

ស្មៀមខឹងខាំមាត់ ។ នាយទាហានគួរគីប្រដៅស្មៀមដោយសូត្រអានពាក្យទំនៀមអាក៏ប ។ ក្នុងពេលនោះ ស្មៀមមិនផ្លាប់ចិត្តនឹងលះបង់បំណងអាក្រក់ដោយគ្មានជំឡោះព្រួញដ៏ដក់ទៅរកអ៊ុស្មាអ៊ុលឡើយ ព្រោះអ៊ុស្មាអ៊ុលដក់យកពីមុខនូវស្រីដែលស្មៀមត្រូវការ គឺជាស្រីតែមួយដែលស្មៀមស្រឡាញ់ជាងស្ត្រីទាំងពួង ។ ស្មៀមខំទប់កំហឹងដែលជិះជាន់សន្តានចិត្ត ហើយធ្វើជាសើចនិយាយថា:

‹ ខ្ញុំសូមសរសើរលោក អំពីការស្គាល់ទំនៀមទំលាប់របស់យើងយ៉ាងច្បាស់លាស់ ប៉ុន្តែបើគេមិនបេះកប់ខ្លួនឯង ត្រូវតែពឹងអ្នកធ្នាតក្នុងវិធីនត្តដែលគេស្គាល់ច្បាស់ ណាជាស្រូវខ្ចី ណាជាស្រូវស ណាជាស្រូវ ណាជាស្រូវដៃ ។ គឺអ៊ុស្មាអ៊ុលជាអ្នកនយោបាយអាក្រក់ ក៏មានគំនុំនឹងសាសន៍គួរតី ហើយមើលងាយសាសន៍យើងផង » ។

នាយទាហានអផ្សុកអំពីការកាយកប់ឥតប្រយោជន៍ ហើយមានបំណងនឹងបញ្ចប់ការចរចា ខ្ជិលនិយាយតទៅទៀត ក៏ឆ្លើយដោយសេចក្តីគួរសមថា:

– ‹‹ ត្រូវមែន ! ខ្ញុំអរគុណចំពោះយោបល់ដ៏ប្រពៃរបស់អ្នកហើយសូមឲ្យព្រះអាឡស់តាមរក្សាអ្នកជានិច្ចកុំបីឃ្លាត » ។

លុះពោលដូច្នោះហើយ លោកងាកមុខចេញ នាំពួកម៉ែត្រសំឡាញ់ដើរសំដៅទៅទីក្រុង ។

* * *

ផ្ទះលោកអ៉ៃយ៉ាដ ជេកស្វាត់ឈីង កាលដែលអ៊ុស្មាអ៊ុលនិងនាងក្រមុំឡីឡាដើរជូនគាត់ជាទីមួយខាងក្នុង, នៅតាមក្បែរខាងផ្ទះនេះ មានផ្ទះអ្នកបំរើនិងក្រោលសេះ ។ នៅពីមុខៈពង់សេះ មានទ្រុងសម្រាប់ចិញ្ចឹមបក្សីពណ៌ផ្សេងៗ ដូចជាអន្ទេប កុកសាប់ ក្ងោក និងមាន់ថៃពណ៌អុជៗ យកពីបូព៌ាប្រទេសមក ។ នៅក្បែរទ្រុងនោះ មានកូនក្រោលមួយកំពស់មួយដំហរមនុស្ស ជាកន្លែងសម្រាប់ទុកចិញ្ចឹមសត្វឈាសៀម (gazelle) អ្នកកំឡោះនិងនាងក្រមុំគ្មាននិយាយស្តីអ្វីឆ្លើយឆ្លងគ្នាសោះ តាំងពីសុខ្ទុពេកាសដែលអ៊ុស្មាអ៊ុលឆក់នាងពីកណ្តាប់ដៃអសប្បុរស ម៉ារ៉ៃយោមក ។

តើជនទាំងពីរនឹងគិតបែបណា ?

ខ្លួននាងឡីឡាទន់ដូចសំឡី ត្រាច់ចរល្វាសល្វន់ក្នុងដៃអ៊ុស្មាអ៊ុល ហើយសង្វាក់ដំណើរសិមៗ បង្ខិតចូលរកគ្នាបន្តិចម្តងៗ ។ ម្ល៉ោះហើយយុវជនទាំងពីរដូចជាគ រកនិយាយកាន់គ្នាទៅវិញទៅមកថាដូចម្តេចមិនកើត ។ គេសោយឥដ្ឋារម្មណ៍ គឺសន្តានដ៏ក្លាហានយ៉ាងទន់ ហើយសេចក្តីស្នេហាចំពោះគ្នានឹងគ្នាយ៉ាងចុះរហូតដួងហឫទ័យរៀងខ្លួន ព្រមទាំងស្រោចស្រពដោយពន្លឺយ៉ាងត្រជាក់ ។ កាមរាគដែលស្ថិតនៅយូរណាស់ក្នុងសន្តានសត្វជាអ្នកអត់ធន់ និងជាអ្នកខ្មាស កំលោផុះផុលឡើងក្លាមដោយកំឡាំងមួយ រកអ្នកណាជំងគ្មាន ។

សេចក្ដីទុកក្ដុកច្រើន ៗ បានផុះប៉ុចឡើងក្នុងដួងវិញ្ញាណនៃនាងនារី ឡូឡា សេចក្ដីទុកក្ដុកនេះចាំតែរីក ចាំតែបញ្ចេញពន ចាំតែក្លាយទៅ ជាការណ៍ពិតដែលនាំឲ្យរំភើបចិត្ត ៗ

ចំណែកខ្លួនអ៊ីស្មាអ៊ីលឯង ក៏មិនអាចទប់ទល់អាត្មាអំពីសន្ដានដ៏រំភើប នៅចំពោះមុខនាងក្រមុំជាតិជាមួយគ្នា ៗ គេស្រឡាញ់ជាប់ចិត្តក្នុងនាង ឡូឡា ហើយទុកនាងនេះជាករិយាឯក នៅបណ្ដាស្ត្រីទាំងឡាយ ក្នុងក្រុមញាតិ ៗ គេឈប់ត្រង់កណ្ដាលទ្វារ ពីមុខកញ្ច្រែបទឹកប្រែកប ដោយសូរស័ព្ទស្រេះស្រណោចលាយឡំទីងសូរសន្ធឹកសំឡេងផ្សេងៗក្នុង អាកាសរហៀកៗពេលពេក ៗ ទ្វារក្រោលសេះរបើកឡើង នៅទីកណ្ដាល ក្រោលដែលគេមើលឃើញ ពងសេះខ្មៅ សស្កុង ៗ ដេកលើចម្បើង មាន ចង្កៀងគោមមួយអុជភ្លឺប្លុងចុះប្លុងឡើងដូចជាភ្លើងអាបត្រាប់ក្នុងពេលស្រែ ៗ

អ៊ីស្មាអ៊ីលនិយាយខ្សឹបៗ ដាក់ត្រចៀកនាងឡូឡាថា:

– ''តាឡូបមិនទាន់ដេកទេ! តាមបងមក!'' ៗ

នាងដើរពីក្រោយចូលតាមទៅក្នុងក្រោលសេះ ដែលមានស្មៅ ក្លិនប្រហើរទើបនឹងច្រូតមកថ្មី ៗ ប្រាប់ឲ្យដឹងថាអ្នកម្ចាស់ផ្ទះសម្បូរស្មៅ ណាស់ ៗ

អ្នកបំរើគេមកជួបមីងហៅហ្វាយកំឡោះ គឺជាមនុស្សប្រុសអាយុ ប្រហែលហាសិបឆ្នាំ បើគេសំឡឹងមើលតាមស្បែកមុខជ្រួញស្វិត តែដែល តាមពិតនោះ អ្នកនោះមិនជាចាស់ប៉ុន្មានទេ ៗ គាត់ជាអ្នកកំព្រា, គេបោះបង់ ចោល, លោកអៃយ៉ាដ រើសយកមកចិញ្ចឹមទុកប្រើដូចជាខ្ញុំសម្រាប់ចាំ

ផ្ទះ ។ តាឡិបស្រឡាញ់ក្រុមគ្រួសារលោកអៃយ៉ាដ ដោយចិត្តស្មោះស្ម័គ្រ អស់ពីពោះពីពុង តែដែលគាត់ស្រឡាញ់ជាងគេគឺ អ៊ុស្មាអ៊ុល ដែលគាត់បានឃើញកើតមក ហើយដែលជាអ្នកបង្ហាត់ឲ្យរៀនដើរ ខាងក្រោយប្រពន្ធទីមួយរបស់លោកអៃយ៉ាដអនិច្ចកម្មទៅ ។ តមកគឺគាត់ហ្នឹងហើយជាអ្នកមើលថែទាំតខាងបង្រៀនអ៊ុស្មាអ៊ុល ឲ្យចូលចិត្តក្នុងការបាញ់ ។ គាត់បង្រៀនចំណេះចាប់សត្វស្លាប ដោយយកបាមទៅលាបបង្គុំ គង់កន្ទុងដែលសត្វធ្លាប់ទំ ។ គាត់ប្រាប់របៀបក្លួនសេះកៀបនឹងទំនង់ជិះលើខ្នងអូដ្ឋ រាប់គីឡូម៉ែត្រមិនអស់កំឡាំង ។

តាឡិបបានធ្វើឲ្យស្គាល់មហាលំអនៃធម្មជាតិ ដ៏ក្លាខ្លាំងសំបុកទ្រយុក បានធ្វើឲ្យស្គាល់ទស្សនាការដ៏ពាសពេញក្នុងពេលខ្យាច់ ចំពោះដួងតរុណវិញ្ញាណដែលកំពុងចូលចិត្តបង់ជីងចង់យល់ ដែលទើបនឹងឈានចូលក្នុងពិភពលោក កាលណាខ្យល់បក់មកពីត្បូង ហាក់ដូចពេលដើមទ្រូង កាលណាបក្សីអកចេញពីសំបុក ហើរបោះពួយ យ៉ាងខ្ពស់ពីខាងលើខ្យល់លើ ដូចជាអ្នកនាំដំណឹងអាក្រក់ កាលណាលំអចាប់ចិត្តពេលល្ងាចពណ៌ក្រហមរន្ទាល កាលណាព្រះអាទិត្យរៀបលិចឯណោះ ក្នុងសាគរ ៖ទៅត្រើយនាយខាងទ្រីប៉ូលី ជាទីដែលតាឡិបមិនស្គាល់ តែគាត់ប្រាប់ថាបង់ជីងក្រៃពេកតែក្នុងចិត្ត ព្រោះគាត់នឹកដល់សំពៅក្តោងក្រមៅ ដល់នាវាស្រាល ៗ នឹងនាវាធំ ៗ ដូចជាផ្ទះដែលផ្សែងហុយចេញពីបំពង់ត្រើងខ្មៅខ្ពស់ ហើយរសាត់អណ្តែតទៅលាយឡំនឹងពពកឯអាកាសវេហាស៍ ។

រឿងព្រេងនិងរឿងស្រមាក់ស្រមៃនៃអតីតកាលតែងមានជាប់នៅក្នុងដួងព្រលឹងតាឡិបជាធម្មតា អតីតការណ៍បណ្ដាលឡើងនឹងធ្វើឲ្យចាំងរស្មីឡើង កាលណាគាត់ទុកចិត្តអ្នកដែលគាត់ស្រឡាញ់ ហើយគាត់និយាយបើកកកាយប្រាប់ឥតមានលាក់ ។

តាឡិបបើកក្រពេះចេញពីក្បាលត្រងាល ដើម្បីសំដែងសេចក្ដីគួរសម ។ គេឃើញមុខគាត់ដោយសារពន្លឺភ្លើងគោម ។ មុខនោះជារបៀបធម្មតាតែស្បែកបែបក្រាស់បន្តិច ភ្នែកមានប្រាជ្ញា ផ្គត់បបូរមាត់ស្ដើងប្រាប់ឲ្យដឹងថាជាអ្នកមានល្បិច កិច្ចកលឧបាយ ថ្វីដ្បិតកាយគាត់គំពង់ឃាំង ។

អ៊ីស្មាអ៊ីលរុញនាងឡីឡាចូលទៅហើយប្រាប់ថា:

— " លោកតា! ខ្ញុំសុំផ្ញើដុំមាសមួយនេះនឹងតាផង!" ។

តាឡិបងក់ក្បាលចំពោះនាងក្រមុំដែលគាត់ស្គាល់ជាស្រីជាតិជាមួយគ្នា ហើយគាត់និយាយខ្សឹបៗថា:

— " សូមព្រះអាឡស់តាមរក្សាអ្នក!" ។

អ៊ីស្មាអ៊ីលប្រាប់ទៀតថា:

— " លោកនាងទុកឲ្យស្រួលណា! មិនត្រូវឲ្យអ្នកណាសង្ស័យថាមាននាងនៅក្នុងទីនេះឡើយ ។ សូមលោកតាឆ្លើយដោយងក់ក្បាលបានហើយ!" ។

តាឡិបងើយសំឡឹងមេឃ នឹកអំពាវនាវរកព្រះជាម្ចាស់ ហើយយកដៃដាក់ត្រង់ដើមទ្រូង គាត់ស្បថចំពោះព្រះនាមនៃម៉ាហូម៉េត ។ (មានត)

## រឿងបល្ល័ង្កនិត្យ សាមសិបពីររឿង

រឿងព្រេងតំណាល

### លោកសមិន មូត្យួងជមៈ តែង
### លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

ដល់សាយណ្ហសម័យ, ពានរបានយល់ថា: ព្រះរាជបុត្រទ្រង់នឿយព្រះកាយពល ក៏ក្រាបទូលថា: "ឱព្រះអង្គម្ចាស់ ខ្លានៅក្រោមដើមឈើនេះ, សូមផ្ទំសម្រាកព្រះកាយតាមព្រះទ័យនៅទីនេះហើយ ។ ព្រះអង្គ-ម្ចាស់ទ្រង់ក៏រៀបចំព្រះកាយដើម្បីនឹងផ្ទំនៅទីនោះ" ។ ខ្លាពោលទៅកាន់ពានរថា: "ឱពានរ អ្នកកុំទុកចិត្តជាតិមនុស្សឲ្យសោះ. អ្នកឯងត្រូវបោះព្រះរាជបុត្រមកឲ្យខ្ញុំមក; ចំណីខ្ញុំមកពីសេចក្ដីសោមនស្សរបស់អ្នកឯងដោយពិត" ។ ពានរក៏តបទៅវិញថា: "បងខ្លា ចូរអ្នកស្ដាប់ខ្ញុំ, ព្រះរាជបុត្របានទុកចិត្តខ្ញុំ ។ មិនធ្វើឃាតទ្រង់ទេ" ។ ដល់ខ្លាបានស្ដាប់វាចាពានរក៏ស្ងិតនៅស្ងាត់ស្ងៀម ។

ដល់យូរបន្តិច, ព្រះរាជបុត្រទ្រង់តើនពីក្រឡាព្រះបន្ទំ ។ ពានរក៏យកក្បាលដាក់លើភ្លៅព្រះរាជបុត្រហើយក៏ដេកលក់ទៅ ។ ខ្លាក៏ពោលទៅកាន់ព្រះរាជបុត្រថា: 'ឱព្រះអង្គម្ចាស់, ហេតុដូចម្ដេចបានជាទ្រង់សព្វព្រះទ័យនឹងពួកពានរ, សូមទ្រង់បោះពានរនេះមកខាងក្រោម, ពានរនេះជាអាហាររបស់ទូលបង្គំ, កុំឲ្យទ្រង់ខ្លាចទូលបង្គំឡើយ" ។

ព្រះអង្គម្ចាស់ទ្រង់ព្រះសណ្ដាប់នូវកថារបស់ខ្លា ទ្រង់ក៏បោះពាននោះទៅខាងក្រោម ។ តែក្នុងខណៈនោះ, ពានបានចាប់មែកឈើគោងទាន់, មិនបានធ្លាក់មកដល់ដី ។ ព្រះរាជបុត្រដល់ឃើញដូច្នោះ ទ្រង់ខ្មាសអៀនពន់ពេក ។ ពានក្រាបបង្គំទូលព្រះរាជបុត្រថា: "កុំឲ្យទ្រង់ព្រួយបារម្ភអ្វីឡើយ" ។

ដល់បុព្វណ្ហសម័យ, ខ្លាក៏ចេញពីទីនោះ ចំណែកព្រះរាជបុត្រទ្រង់ត្រឡប់ទៅជាមានឧម្មត្តកភាព ឆ្កួត) ក៏បានត្រាច់ទៅក្នុងអរញ្ញប្រទេសនោះ ទ្រង់ចេះតែមានព្រះបន្ទូលថា: វិ.សេ.មិ.រា. វិ.សេ.មិ.រា.។

ព្រះទីនាំងអស្សតរព្រះអង្គម្ចាស់ បានវិលត្រឡប់ទៅព្រះរាជធានីកម្រង់ទៅកាន់អស្វសាលាវិញ ។ ព្រះមហាក្សត្រិយ៍ទ្រង់ទតយល់ពាជីត្រឡប់វិលមកព្រះរាជនិវេសនដ្ឋានវិញ ដោយបាត់ព្រះអង្គម្ចាស់ដូច្នោះ ក៏ទ្រង់ព្រួយព្រះរាជហឫទ័យពន់ពេក ។ ព្រះមហាក្សត្រិយ៍ទ្រង់ស្តេចយាងជាមួយនឹងព្រះរាជបរិវារទៅក្នុងអដវីប្រទេស ដើម្បីនឹងស្វែងរកព្រះរាជបុត្រ; ទ្រង់បានជួបនឹងព្រះរាជបុត្រដែលត្រាច់ទៅក្នុងវនប្បទេស កំពុងមានព្រះឧក្ការថា: វិ.សេ.មិ.រា. វិ.សេ.មិ.រា. ។ ព្រះមហាក្សត្រិយ៍ទ្រង់បាននាំព្រះរាជបុត្រ ត្រឡប់ទៅព្រះបរមរាជវាំងវិញហើយ ទ្រង់បានឲ្យប្រសិទ្ធនូវមន្ត្រនឹងឲ្យសោយនូវឱសថ យ៉ាងចំណាន, តែទោះបីព្រះអង្គទ្រង់ប្រើនូវព្រះមធ្យោបាយយ៉ាងណាក៏មិនអាចធ្វើឲ្យសះស្បើយនូវឧម្មត្តកភាពនៃព្រះរាជបុត្របានឡើយ ។ ព្រះ

មហាក្សត្រិយ៍មានព្រះឱង្ការថាៈ "បើលោកគ្រូសារពានទូនៅទីនេះ លោកអាចជ្រាបនូវព្រះរោគនៃព្រះរាជបុត្រនេះបាន តែយើងបានចាត់ឲ្យគេយកលោកទៅពិឃាដបាត់បង់ទៅហើយ ។ គង់ពេលនោះព្រះរាជទីប្រឹក្សាបានក្រាបបង្គំទូលព្រះមហាក្សត្រិយ៍ថា "សូមមហារាជទ្រង់ព្រះមេត្តាប្រោស, ទូលព្រះបង្គំជាខ្ញុំ សូមស្នើព្រះរាជយោបល់ថាៈ ទ្រង់ប្រើឧសថទាំងអស់មិនបានការ ព្រះអង្គនៅតែទ្រង់ព្រួយព្រះរាជហឫទ័យដដែល តើព្រះអង្គនឹងទ្រង់ព្រះចិន្តាដូចម្តេចទៀត? សូមទ្រង់ចាត់ឲ្យអាមាត្យស្រែកអំពាវនាវអ្នកជុំវិញព្រះរាជធានី ដោយព្រះរាជ-ប្រកាសនេះថាៈ "អ្នកណាមើលព្រះរោគព្រះអង្គម្ចាស់ជាសះស្បើយបាន យើងនឹងប្រគល់ព្រះរាជអាណាចក្រពាក់កណ្តាល ឲ្យគ្រួតត្រាកាន់កាប់" ។ ព្រះមហាក្សត្រិយ៍ក៏ទ្រង់ព្រមតាមយោបល់ព្រះរាជទីប្រឹក្សា ហើយក៏ចាត់អាមាត្យស្រែកឃោសនាផ្សាយព្រះរាជប្រកាស ឲ្យប្រជាជននៅជុំវិញទីក្រុងឮគ្រប់គ្នា ។ ព្រះរាជទីប្រឹក្សា បានវិលត្រឡប់មកកាន់គេហដ្ឋានវិញ ហើយក៏បាននិទានរឿងនេះឲ្យលោកគ្រូសារពានទូជ្រាប ។ លោកសារពានទូ ក៏ពោលទៅកាន់ព្រះរាជទីប្រឹក្សាថាៈ "ចូរលោកអញ្ជើញទៅក្រាបបង្គំទូលព្រះមហាក្សត្រិយ៍ថា ខ្ញុំមានយុវតីមួយនាក់អាយុ ៧ ឆ្នាំ បើនាងយុវតីនេះមើលចំពោះព្រះរាជបុត្រ ៗ នឹងបានជាសះស្បើយរោគភ្លាម" ។ ព្រះរាជទីប្រឹក្សាបានយកសេចក្តីនោះទៅក្រាបបង្គំទូលព្រះមហាក្សត្រិយ៍ ៗ ទ្រង់សវនាហើយ ទ្រង់បាននាំព្រះ

រាជបុត្រមកកាន់គេហដ្ឋាន នៃព្រះរាជទីប្រឹក្សា ៗ បានយកកាំងននមួយបាំង ត្រង់បន្ទប់ដែលលោកសារទានន្ទនៅ, ព្រះមហាក្សត្រិយ៍នឹងព្រះរាជបុត្រ ទ្រង់គង់នៅខាងក្រៅកាំងនន ។

លោកសារទានន្ទនៅពីក្រោយកាំងនន ពោលថា "អ្នក វិស្សាសៈណាដែលទំព្រលក់លើក្លៅមិត្ត ហើយបានបេ្តជ្ញាថាទុកចិត្តមិត្តនោះហើយ អ្នកនោះបោកបញ្ឆោតទៅវិញ, តើនឹងទុកអ្នកនោះ ថាជាអ្នកសប្បុរសបានឬ? (គេបានយករឿងនោះទៅនិពន្ធជាកាព្យ) ។

ព្រះរាជបុត្រទ្រង់សវនាទូវពំចាជាសុភាសិត នៃលោកគ្រូសារទានន្ទ ក៏បំបាត់អក្សរ វិ. ចេញបាន ត្រឡប់ពោលតែពាក្យថា សេ.មិ.រា. ។

លោកសារទានន្ទពោលថា: "តាំងពីស្ពាន សេតុពន្ធ[១] បានផ្ញើធ្ងន់ទៅដល់ទន្លេគង្គា, ការប្រព្រឹត្តិបទទ្រុឹដ្ឋទៅលើព្រាហ្មណ៍ឬបទទ្រុឹដ្ឋដែលប្រព្រឹត្តទៅលើកល្យាណមិត្តរបស់ខ្លួន មិនអាចនឹងរលុបរលាយបានឡើយ" ។ ព្រះរាជបុត្រទ្រង់ព្រះសណ្តាប់នូវពាក្យជម្ងន់នោះ លោកគ្រូសារទានន្ទហើយ ក៏បំបាត់អក្សរ សេ· ចេញ, ទ្រង់ពោលតែត្រឹមពាក្យ មិ.រា. វិញ ។

លោកសារទានន្ទថ្លែងតទៅទៀតថា "អ្នកណាដែលព្យាបាទមិត្តរបស់ខ្លួន (មិត្រេហិម្សកៈ) ជាអ្នកអកតញ្ញូ, ជាបុគ្គលពាលប្រព្រឹត្តទុច្ចរិត

១ សេតុពន្ធ គឺស្ពានព្រះរាម នៅខាងត្បូងប្រទេសឥណ្ឌា ឬ ជាកោះតូច ៗ ដែលស្ថិតនៅរវាងប្រទេសឥណ្ឌានឹងកោះលង្កា ។

អ្នកនោះត្រូវទៅសោយទុក្ខឯនរក ក្នុងរយៈវេលាកំណត់តាមកាលដែល ព្រះអាទិត្យនឹងព្រះចន្ទស្ថិតនៅក្នុងលោក" ។

ព្រះរាជបុត្រទ្រង់បានសណ្តាប់នូវគាថាលោកសារភានន្ទហើយ ក៏បំបាត់អក្សរ មិ. ចេញ, ទ្រង់ពោលតែអក្សរ វា. វិញ ។

លោកសារភានន្ទ ពោលតទៅទៀតថា: វាមិៈ បើទ្រង់ចង់ឲ្យបានសេចក្តីសុខ ដល់ព្រះរាជបុត្រ, ទ្រង់ត្រូវតែបរិច្ចាគទ្រព្យសម្បត្តិផ្សេងៗ ឲ្យទៅដល់ពួកព្រាហ្មណ៍ ។ ការធ្វើព្រះរាជអំណោយដល់ពួកម្ចាស់គេហដ្ឋាននេះនាំឲ្យលត់រលាយនូវបាបអកុសល ដែលទ្រង់បានប្រព្រឹត្ត" ។

ព្រះរាជបុត្រទ្រង់ព្រះសណ្តាប់នូវពាក្យនេះហើយ ទ្រង់ក៏ជាសះស្បើយនូវឧម្មត្តកភេទនោះជ្រះស្រឡះ ។

កាលអ្នកទាំងអស់គ្នានេះ បានស្តាប់នូវរឿងព្រះរាជបុត្រ, ខ្លានឹងពានរហើយ ក៏មានចិត្តសោមនស្សពន់ពេក ។

ព្រះមហាក្សត្រិយ៍ទ្រង់វិចិកិច្ឆាក៏មានព្រះឱង្ការសួរទៅនាងទារិកាថា "ឱនាងទារិកា, គេហដ្ឋាននាងឯងនៅឯណា? ឬជានាងឯងស្ថិតនៅក្នុងគុហានេះ, ម្តេចក៏នាងឯងបានដឹងរឿងរ៉ាវខ្លា, ពានរនឹងព្រះរាជបុត្រនេះសព្វគ្រប់ ដែលជារឿងកើតមាននៅក្នុងអរញ្ញប្រទេស ។ លោកសារភានន្ទ កាលបានស្តាប់ព្រះរាជឱង្ការនេះហើយ ក៏ក្រាបបង្គំទូលថា: "ដោយសេចក្តីអនុគ្រោះនៃពួកអាទិទេពដ៏ប្រកបដោយពលភាពអស្ចារ្យ, ព្រះនាងសរស្វតី (អាទិទេវីនៃវេទសិល្បៈ) ស្ថិតនៅចុងជិវ្ហាប្រសាទ

ទូលបង្គំនាំឲ្យទូលបង្គំដឹងទាំងអស់ ដូចជាទូលបង្គំបានមើលឃើញគ្រាប់លំអ (កិនសោកា) នៅឡើងក្នុងព្រះនាងការណ៍មត៌ដូចោះដែរ" ។ ព្រះមហាក្សត្រិយ៍ដល់ទ្រង់ព្រះសណ្ដាប់ នូវពាក្យក្រោយបង្អស់កំមានព្រះបន្ទូលហៅ "លោកគ្រូសារទានន្ទ" ហើយទ្រង់ក៏បើកវាំងននឡើងរួចទ្រង់សរសើរសំណាងព្រះរាជបុត្រ ដែលបានជួបលោកគ្រូសារទានន្ទ។ ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះរាជនុត្តរសរសើរ ជាយ៉ាងក្បោះក្បាយចំពោះព្រះរាជទីប្រឹក្សាថា "ព្រះរាជទីប្រឹក្សា! លោកជាមហាបុរស, យើងត្រូវទុកលោកជាអ្នកមានគុណជាយ៉ាងក្រៃលែង ដោយលោកបានឲ្យជីវិតដល់លោកគ្រូនិងព្រះរាជបុត្រយើង" ។

ទុគ្គតបុរសកាលបានថ្លែងរឿងនេះថ្វាយព្រះមហាក្សត្រិវិក្រមទិត្យចប់ហើយទើបក្រាបទូលថា "មហារាជ, សូមព្រះអង្គទ្រង់ជ្រាបថា អ្នកណាមួយសេពគប់នឹងបុគ្គលសប្បុរសអ្នកនោះតែងបានប្រយោជន៍ជាអនេកប្បការ" ។

ព្រះមហាក្សត្រិយ៍វិក្រមទិត្យ ទ្រង់ព្រះសណ្ដាប់នូវសុទ្ធរកថាដែលព្រាហ្មណ៍នេះពោលហើយ ទ្រង់មានព្រះរាជហឫទ័យសោមនស្សពន់ពេក ហើយទ្រង់បូជាប្រាក់ដប់លានប៉ាកូដ (កហាបណៈ) ដល់ព្រាហ្មណ៍នេះ ។ ទុគ្គតបុរសទទួលព្រះរាជអំណោយហើយ ក៏វិលត្រឡប់ទៅគេហដ្ឋានវិញ ។

ព្រះបាទវិក្រមទិត្យ ទ្រង់មានព្រះរាជនុត្តរទៅកាន់រាជគោដ្ឋាគារិក

អគ្គហរិញ្ញិកថា "បើមានសូមយាចកមកក្នុងទីនេះ ឲ្យលោកចំណាយប្រាក់មួយពាន់ប៉ាកូដប្រគល់ឲ្យជាទានកុំខាន; លោកឲ្យមួយម៉ឺនប៉ាកូដ ចំពោះពួកទុគ្គតបុរសណាដែលគ្រាន់តែសូម, ដប់ម៉ឺនប៉ាកូដ ចំពោះពួកទុគ្គត-បុរសណាបានថ្លែងរឿងដែលមាននៅក្នុងសាស្ត្រៈ; លុះត្រាតែមានបង្គាប់ពីយើង ទើបលោកឲ្យដប់លានប៉ាកូដបាន" ។

រូបទេពនិម្មិតទី១ពោលបន្ថែមថាៈ សូមទ្រង់ព្រះមេត្តាប្រោស, សូមទ្រង់ព្រះសណ្ដាប់, បពិត្រព្រះមហារាជគោជៈ ទូលព្រះបង្គំជាខ្ញុំបានក្រាបបង្គំទូលនូវព្រះរាជតេជានុភាព, ព្រះមហាសប្បុរសធម៌, ព្រះពលភាពនៃព្រះបាទវិក្រមាទិត្យ ដូចសំដែងមកនេះ ។ បើព្រះរាជគុណសម្បត្តិទាំងនេះ មាននៅចំពោះព្រះអង្គៗអាចនឹងគង់លើបល្ល័ង្កទិព្យនេះបាន ។

(មានត)

## ឱវាទឪពុក

ឱកូនអើយ អ្នកកើតមកជាមនុស្សហើយ ត្រូវឲ្យមានគុណធម៌ក្នុងខ្លួន បើមិនដូច្នោះទេ កូនឯងមិនប្លែកអំពីសត្វតិរច្ឆានឡើយ ។

មួយទៀត កូនឯងត្រូវរៀនវិជ្ជា បើគ្មានវិជ្ជាទេ កូនឯងក៏មិនខុសអំពីសត្វតិរច្ឆានដែរ ។

យ. អ.

# កំណត់ដំណើរប្រវត្តិការណ៍

## ពិធីចែកព្រហ្មទាន

## ដល់សមណសិស្សសាលាបាលីជាន់ខ្ពស់,

## ក្រោមអធិបតីភាពឯកឧត្តម ឃឹម-ទិត ជាព្រះរាជតំណាង

របស់ពុទ្ធសាសនបណ្ឌិត្យ

---

កាលពីថ្ងៃទី ៦ កុម្ភៈ ១៩៥៥ នៅឯសាលាបាលីជាន់ខ្ពស់ មាន ធ្វើពិធីចែកព្រហ្មទានយ៉ាងឧឡារិក ដល់សមណសិស្សសាលាបាលីជាន់ ខ្ពស់ ដែលប្រឡងកាលពីថ្ងៃទី ១ ខែ កុម្ភៈ ជាប់បានសញ្ញាបត្រចំនួន ៩១ អង្គ និងសិស្សដែលប្រឡងជាប់បានឡើងថ្នាក់ប្រចាំឆ្នាំ ១៩៥៥ ពីទី ១-២-៣ ដល់ទី ៤ ចំនួន ៦០ អង្គ ក្រោមអធិបតីភាពនៃឯកឧត្តម ឃឹម ទិត ជាព្រះរាជតំណាងនៃព្រះករុណា ជាម្ចាស់ជីវិតលើត្បូង ។

ពិធីបុណ្យនេះ សមាគមមិត្តសាលាបាលី បានផ្ដើមធ្វើឡើងរៀង រាល់ឆ្នាំ ចាប់តាំងពីឆ្នាំ ១៩៥០ ដរាបមក ។ គេចាត់ទុកជាកុសល បរិយាយមួយដែលជួយឧបត្ថម្ភដល់កិច្ចសិក្សាខាងព្រះពុទ្ធសាសនា ឲ្យមាន វឌ្ឍនភាព កាន់តែដុះដាលឡើងក្នុងប្រទេសកម្ពុជា ។

ចាប់តាំងពីម៉ោង ១៦-៣០ នាទីទៅ គេឃើញឯកឧត្តមឡេង-ង៉ែត នាយករដ្ឋមន្ត្រី, ឯកឧត្តមប៉ាក់-ប៉ាព្រឿង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិង ការពារលើផ្ទៃប្រទេស, ឯកឧត្តមម៉ី-នរស៊ីហ៍ រដ្ឋមន្ត្រីក្រសួងធម្មការ, សមាជិករាជរដ្ឋាភិបាល, លោកឯកអគ្គរាជទូតអង់គ្លេស-ជប៉ុន និងលោក

ហ្គាក្សជាហូត៍កុម្មីស៊ែរ ប្រទេសបារាំង ប្រចាំប្រទេសកម្ពុជា បានអញ្ជើញទៅ ។ ក្នុងពេលជាបន្ទាប់មកទៀត គេឃើញព្រះសង្ឃគឺសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា, ព្រះអរិយកស្សបៈ អ៊ុច ជាតំណាងសម្តេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្តិ, ព្រះពោធិវង្ស ហួត-តាត ចាងហ្វាងសាលាបាលីជាន់ខ្ពស់, ព្រះមហាព្រហ្មមុនី អ៊ូ ចាងហ្វាងរងនឹងព្រះសង្ឃជាសាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ ព្រមទាំងឧបាសកឧបាសិកាជាពុទ្ធបរិស័ទច្រើននាក់ បាននិមន្តបានយាងអញ្ជើញទៅជាអធិបតីក្នុងពិធីបុណ្យនេះ ។

នៅម៉ោង ១៧ ឯកឧត្តម យ៉ឹម-ទិត ជាព្រះរាជតំណាងព្រះករុណាជាអម្ចាស់ជីវិតលើត្បូងអញ្ជើញទៅដល់, លុះគោរពភ្លេងជាតិរួចហើយ ឯកឧត្តមអញ្ជើញទៅអង្គុយលើកៅអី ដែលគេបានរៀបតាក់តែងជូនជាកិត្តិយសក្នុងសាលាបាលីជាន់ខ្ពស់ ។

ពេលក្រោយទៀត ដែលបានយាងនិមន្តអញ្ជើញទៅជួបជុំហើយ លោកភ៉ែ-ប៉ុក ប្រធានសមាគមមិត្តសាលាបាលី ក៏បានសូត្រសុន្ទរ-កថាមួយ អធិប្បាយអំពីកំណើតនៃពិធីបុណ្យព្រហ្មទាន នឹងប្រយោជន៍នៃសមាគមមិត្តសាលាបាលី ដែលបានឧបត្ថម្ភការសិក្សាខាងព្រះពុទ្ធ-សាសនា ឲ្យបានចំរើនរុងរឿងទៅតាមសមត្ថភាពរបស់សមាគមនេះ ។ បន្ទាប់មក ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត ចាងហ្វាងសាលា-បាលីជាន់ខ្ពស់ បានសូត្រសុន្ទរកថាមួយ អធិប្បាយអំពីកិច្ចសិក្សាខាងព្រះពុទ្ធសាសនាក្នុងប្រទេសនឹងក្រៅប្រទេស ដើម្បីរំលឹកដាស់តឿន

ដល់សិស្សទាំងនោះ ឲ្យកើតមានវិរិយៈនិងឧស្សាហៈក្នុងការសិក្សាបន្តទៅទៀត ដើម្បីជាប្រយោជន៍ដល់ខ្លួននិងព្រះពុទ្ធសាសនា ឲ្យមានវិវឌ្ឍនាការទៅមុខជាលំដាប់ ។

ក្រោយដែលចប់សុន្ទរកថាទាំងពីរនេះ មានការប្រគេនព្រហ្មទានដល់ព្រះសង្ឃជាសិស្ស តាមលំដាប់លំដោយ ព្រហ្មទានទី ១ ដែលជាទេយ្យវត្ថុនៃសម្តេចព្រះនរោត្តម-ស៊ីហនុ ត្រូវឯកឧត្តម ឃីម ទិត ជាព្រះរាជតំណាងប្រគេនដល់ព្រះមហា សម-សុខ គង់វត្តលង្កា ដែលប្រឡងជាប់លេខ១; ព្រហ្មទានទី២ ដែលជាទេយ្យវត្ថុនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ត្រូវលោកហ្វាក្សជាហូត៍កុម្មីស៊ែរប្រទេសបារាំងប្រចាំប្រទេសកម្ពុជា ប្រគេនដល់ព្រះមហា ឈឹម មួន គង់នៅវត្តឧណ្ណាលោម ដែលប្រឡងជាប់លេខ ២; ព្រហ្មទានទី ៣ ជាទេយ្យវត្ថុនៃសម្តេចព្រះអគ្គមហេសី ត្រូវឯកឧត្តមនាយករដ្ឋមន្ត្រីប្រគេនដល់ព្រះមហាអ៊ិត ពា គង់នៅវត្តឧណ្ណាលោម ដែលបានប្រឡងជាប់លេខ ៣ ។ ក្រៅពីនេះ ក្រុមចាត់ការពិធីបុណ្យ បានលើកព្រហ្មទានឯទៀតៗ ជូនឥស្សរជនខ្មែរនិងបរទេសឲ្យប្រគេនព្រះសង្ឃជាសិស្សទៅតាមលំដាប់ ។

ដោយចំនួនសិស្សច្រើនពេក វេលាក៏កាន់តែខើច ការចែកព្រហ្មទាននេះក៏បានផ្អាកសិន ដែលនៅពេលនោះ ឯកឧត្តមជាព្រះរាជតំណាងបានថ្លែងសង្កថាមួយ ដោយឥតបានព្រាងទុកជាមុនទៅកាន់ព្រះសង្ឃជាសិស្សទាំងនោះយ៉ាងពីរោះក្បោះក្បាយ ។ ឯកឧត្តមបានមានប្រសាសន៍អំពីការសិក្សាភាសាបាលីក្នុងព្រះពុទ្ធសាសនា ដែលមានវឌ្ឍនាការរើបៗ

តាំងពី ៤០ ឆ្នាំកន្លងមកហើយ មកទល់នឹងសម័យបច្ចុប្បន្ននេះ ដែលមានសេចក្ដីរីកចម្រើនចេះតែជឿនទៅមុខជាលំដាប់ ៗ តមក ឯកឧត្ដមអធិប្បាយអំពីការសិក្សាខាងផ្លូវលោកនឹងផ្លូវធម៌ ដែលមានសេចក្ដីបំរើនជាបន្ដបន្ទាប់គ្នា ហើយជាគំរូល្អដល់បរទេស ៗ លុះដល់ម៉ោង ១៧ ទឹង ៥៥ ឯកឧត្ដមក៏បញ្ចប់ ហើយថ្វាយបង្គំហៅព្រះសង្ឃអញ្ជើញត្រឡប់ទៅវិញ ៗ ឯការចែកព្រហ្មទានក៏ចាប់ផ្ដើមធ្វើតទៅទៀត ដែលបានចប់សព្វគ្រប់នៅម៉ោង ១៨,៣០ នាទី ក្នុងបរិយាកាសប្រកបដោយសេចក្ដីរីករាយជាកិរិយាភាព ៗ

តអំពីនេះ យើងលើកយកសុន្ទរកថារបស់សមាគមមិត្តសាលាបាលីនឹងរបស់សាលាបាលីជាន់ខ្ពស់ មកទុកក្នុងទីនេះ ដូចតទៅនេះ ៖

## សុន្ទរកថា របស់សមាគមមិត្តសាលាបាលី

សូមព្រះតេជះជំគាល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង
សូមទ្រង់ជ្រាបក្រោមលួងធូលីព្រះបាទ ៗ

ក្នុងនាមនៃសមាគមមិត្តសាលាបាលី ទូលព្រះបង្គំជាខ្ញុំសូមថ្វាយសេចក្ដីកតញ្ញូ នឹងសេចក្ដីគោរពយ៉ាងជ្រាលជ្រៅ ចំពោះព្រះករុណាជាអម្ចាស់ជីវិត ដ៏ទ្រង់ព្រះមហាករុណាទិគុណ ដែលបានទ្រង់ស្ដេចយាងមកជាព្រះរាជាធិបតីភាព ក្នុងពិធីចែកព្រហ្មទាននៅពេលនេះ ដើម្បីលើកកិត្តិយសចំពោះសមាគម នឹងធ្វើឲ្យពិធីនេះបានទៅជាឧឡារិកផង ៗ

ការចែកព្រហ្មទានដល់សិស្សសាលាបាលីជាន់ខ្ពស់ ដែលប្រឡង

ជាប់សញ្ញាប័ត្រ ទាំងសិស្សដែលប្រឡងជាប់ឡើងថ្នាក់នេះ សមាគម បានចាត់ចែងធ្វើជាលើកដំបូងនៅឆ្នាំ ១៩៥០ ឥឡូវនេះ ពិធីនេះក៏ក្លាយជាប់ទៅជាប្រពៃណីមួយផ្នែកក្នុងព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជាតទៅអនាគត ដើម្បីទ្រទ្រង់ព្រះពុទ្ធសាសនាដែលកំពុងតែល្បីរន្ទឺខ្ចរខ្ចាយពេញសាកលលោកទៅហើយ ឲ្យរីករិតតែចំរើនជាកិត្យានុភាពឡើងទៀត ព្រមទាំងដើម្បីលើកទឹកចិត្តសិក្ខាកាមកុលបុត្រដែលបានខំព្យាយាមរៀនសូត្រដកពបដល់បានផលល្អប្រពៃនៃបំណាច់ឆ្នាំសិក្សាម្តងៗផង ។

បពិត្រព្រះសម្ពុទ្ធទេព ! សមាគមមិត្តសាលាបាលីនេះ តាំងពីចាប់កំណើតមកមិនទាន់បានរីងដំហរ ដោយគោគទ្រព្យនៅឡើយទេ ដោយប្រាក់ចំណូលក្នុងមួយឆ្នាំៗ ដែលបានមកពីភាគទានប្រចាំខែស្តួចស្តើងពន់ពេក ប៉ុន្តែ ទោះបីស្តួចស្តើងយ៉ាងណា ក៏សមាគមនៅតែខំត្រដរបំពេញសកម្មភាពរបស់ខ្លួន ដែលល្អមកម្ខាំងធ្វើទៅបានរាល់តែឆ្នាំពុំដែលអាក់ខាន ។ ដែលសមាគមបំពេញសកម្មភាពបាន ក៏ដោយសារព្រះករុណាជាអម្ចាស់ជីវិត បានទ្រង់សព្វព្រះរាជហឫទ័យប្រោសព្រះរាជទានព្រះរាជទ្រព្យជាអំណោយ និងដោយសារសេចក្តីសប្បុរសរបស់អស់លោក-អ្នកជាពុទ្ធបរិស័ទជួយជាកម្លាំង យកមកជួយទំនុបប្រាក់របស់សមាគមបន្តិចបន្តួចផង ។

សកម្មភាពដែលសមាគមបានបំពេញក្នុងឆ្នាំ ដែលកន្លងទៅហើយនោះ មានដូចេះជាដើម គឺ ៖

១ — ទំនុកបំរុងសមណនិស្សិតដែលនិមន្តទៅ បន្តវិជ្ជានៅប្រទេស នេប៉ាល់ ជាមួយនឹងពុទ្ធិកសមាគមមជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋ;

២ - ធ្វើបុណ្យផ្កាយកកម្រៃទៅជួយសាងសង់វិហារមួយខ្នងសម្រាប់ ព្រះសង្ឃក្នុងព្រះពុទ្ធសាសនា នៅក្រុងវ៉ាស៊ីនតុនប្រទេសអាមេរិក ជា នៃមួយនឹងពុទ្ធិកសមាគមកម្ពុជរដ្ឋ,

៣ - រៀបទទួលជាកិត្តិយសចំពោះព្រះពុទ្ធរូបពីរព្រះអង្គជាវិការៈ មាស ទឹងក្នុកដែលពុទ្ធបរិស័ទនៃប្រទេសភូមា នឹងថៃ បានឧទ្ទិសបូជា ចំពោះប្រទេសកម្ពុជា;

៤ - បញ្ជូនសមណនិស្សិត ៣ រូបឲ្យទៅបន្តវិជ្ជាព្រះពុទ្ធសាសនា នៅវិជ្ជាស្ថានទាលន្ទាប្រទេសឥណ្ឌា ក្រោមការឧបត្ថម្ភដោយអាហា- រូបករណ៍នៃវិជ្ជាស្ថាននេះ ។

ទើបនឹងខ្វល់ខ្វាយបញ្ជូនសមណៈនិស្សិតទៅនៅពេលថ្មីៗ ដូនពេល ត្រវចែកព្រហ្មទានក៏លូនចូលមកដល់ទៀត ម្ល៉ោះហើយសមាគមត្រូវតែ ប្រឹងក្រោកឈរបំពេញករណីយកិច្ចដែលខានពុំបាន ដោយការអំពាវនាវ ដល់កម្លាំងរបស់អស់លោក អ្នកសប្បុរសមានព្រះករុណាជាអម្ចាស់ជីវិតជា ដើម សូមទ្រង់ជួយនឹងជួយទំនុកបំរុង ។ សេចក្តីអំពាវនាវរបស់សមាគម ក៏បានទទួលនូវលទ្ធផលដ៏ល្អដូចប្រាថ្នា ។ សមាគមមិត្តសាលាបាលី សូមឆ្លៀតឱកាសនេះ ថ្លែងសេចក្តីកតញ្ញូចំពោះព្រះករុណាជាអម្ចាស់ជីវិត ព្រមទាំងអស់លោក-អ្នកដែលបានបរិច្ចាគធនធាន ដើម្បីជួយជាកម្លាំងឲ្យ ចាត់ចែងពិធីនេះបានដូចបំណង ដូចមានទេយ្យវត្ថុត្រៀបត្រាខ្ចប់ដោយ

ក្រដាសរំលេចពណ៌ នៅលើតុនេះ គួរឲ្យចាប់ចិត្តជាភស្តុតាងស្រាប់ ៗ

មុននឹងបញ្ចប់សុន្ទរកថានេះ ទូលព្រះបង្គំជាខ្ញុំ សូមទ្រង់ព្រះមេត្តាប្រោស ព្រះបរមរាជឱកាស សំណេះសំណាលជាមួយនឹងសមណៈ ដែលត្រូវបានរង្វាន់នេះ ៗ

បពិត្រព្រះសមណសិស្សទាំងឡាយ! នៅពេលដែលសេចក្តីចំរើនរបស់វិទ្យាសាស្ត្រធ្វើឲ្យផែនដីរួញចូលគ្នា ឲ្យមនុស្សត្រាច់ចរកាន់គ្នាបានយ៉ាងឆាប់រហ័ស ខុសពីសម័យបុរាណនេះ យើងខ្ញុំទាំងឡាយទុកសង្ឃឹមទៅអនាគតថា ព្រះពុទ្ធសាសនានឹងបានបញ្ចេញមុខផ្សព្វផ្សាយ ក្នុងលោកយ៉ាងឆ្ងាយទូលាយពុំខាន ព្រោះ៖

១ – ពុទ្ធិកសមាគមពិភពលោក នឹងចាត់ធម្មទូតឲ្យទៅផ្សាយអនុត្តរធម៌ព្រះសម្ពុទ្ធនៅប្រទេសដទៃនៅពេលឆាប់ៗ នេះហើយ ៗ

២ – នៅប្រទេសយើងបានបង្កើតឲ្យមានមហាវិទ្យាល័យព្រះពុទ្ធសាសនាជាគ្រឹះស្ថានសិក្សាជាន់ខ្ពស់ ដែលនឹងបើកទ្វារឲ្យសិក្ខាកាមកុលបុត្រចូលរៀននៅពេលឆាប់ ៗ នេះ ៗ

ដូច្នេះ ដើម្បីកិត្តិយសចំពោះព្រះពុទ្ធសាសនានឹងការប្រព្រឹត្តទៅនៃអនាគតពុទ្ធិកមហាវិទ្យាល័យនេះ សមាគមមិត្តសាលាបាលីសូមអង្វរព្រះទ័យ ចំពោះលោកម្ចាស់អង្គណា ដែលមានសុខភាពល្មមទ្រទ្រង់ការរៀនសូត្រទៅមុខទៀតបាននោះ ឲ្យអត់ទ្រាំបំពេញប្រយោជន៍ដ៏ឧត្តមនេះតទៅទៀត ហើយទៅអនាគតបើសមាគមមានកម្លាំងល្មមទំនុកបំរុងបាន ក៏មុខជាមិនមើលបំណាំក្នុងការឧបត្ថម្ភនេះសោះឡើយ ៗ

នៅអវសាននេះ សមាគមមិត្តសាលាបាលី សូមគុណព្រះរតន-ត្រ័យជួយឧបត្ថម្ភព្រះករុណាជាអម្ចាស់ជីវិត សូមទ្រង់គង់នៅជាសុខគង់សេពិជសម្បត្តិព្រមទាំងព្រះរាជវង្សានុវង្ស, សូមតេជានុភាពនៃព្រះរតនត្រ័យរក្សាព្រះពុទ្ធសាសនាព្រមទាំងពុទ្ធមាមកជន ទោះនៅប្រទេសកម្ពុជាក្តី នៅក្នុងពិភពលោកក្តី ឲ្យប្រកបតែនឹងសេរីសួស្តីជយមង្គលគ្រប់ប្រការកុំបីឃ្លៀងឃ្លាតឡើយ ។

## សុន្ទរកថារបស់សាលាបាលីជាន់ខ្ពស់

សូមចំរើនពរឯកឧត្តម ជាព្រះរាជតំណាងព្រះករុណាជាម្ចាស់ជីវិត !

សូមថ្វាយបង្គំដោយគោរពចំពោះសម្តេច !.

សូមថ្វាយព្រះពរទ្រង់ !

សូមចំរើនពរឯកឧត្តមនឹងអស់លោកទាំងឡាយ !

អាត្មាភាពជាតំណាងបុគ្គលិកទាំងអស់ក្នុងសាលានេះ មានអំណរដ៏ក្រៃលែងចំពោះឯកឧត្តមជាព្រះរាជតំណាង ចំពោះសម្តេច, ទ្រង់; ឯកឧត្តមនឹងអស់លោក អ្នកទាំងឡាយ ដែលបានអញ្ជើញមក និមន្តមកស្តេចមកជាអធិបតី ជាកិត្តិយស នឹងជាមង្គលក្នុងឱកាសបុណ្យ ចែកព្រហ្មទាននេះ ព្រោះទស្សនកិច្ចក្នុងទីនេះ ប្រាកដដូចជាបាននាំយកនូវកិត្តិយសដ៏ខ្ពង់ខ្ពស់ នូវសិរីសួស្តីដ៏ប្រសើរ នូវជោគជ័យដ៏ឧត្តម មកប្រគល់ដល់សាលាបាលីជាន់ខ្ពស់នេះ ។ កិត្តិយសជាដើមនេះហើយ ដែលនាំឲ្យសាលានេះមានដំណើរទៅកាន់សេចក្តីចំរើន ដោយស្រួលក្នុងអនាគតបាន ។

លំដាប់អំពីនេះ អាត្មាភាពសូមឱកាសបន្តិច ដើម្បីថ្លែងអំណរចំពោះ

សមាគមមិត្តសាលាបាឡី នឹងដើម្បីគ្រាន់រំលឹកប្រស្រ័យនឹងព្រះសង្ឃជានិស្សិតនៃសាលានេះ ដូចតទៅនេះ :

• អម្បាញ់មិញនេះ លោកប្រធាននៃសមាគមមិត្តសាលាបាលីបានថ្លែងសេចក្តីអំពីការប្រគេនរង្វាន់ដល់ព្រះសង្ឃជានិស្សិត ដែលទើបប្រឡងចេញពីសាលានេះ នឹងសិស្សខ្លះកំពុងសិក្សាដែលបានពិន្ទុប្រសើរក្នុងថ្នាក់រៀន ។

ការចែករង្វាន់ដូច្នេះ អាចរាប់បញ្ចូលទៅក្នុងការកុសលដែលនឹងជូនលទ្ធផលក្នុងបច្ចុប្បន្ននឹងបរលោកបាន ។ សាលាបាលីជាន់ខ្ពស់សូមទទួលអំណរដ៏ក្រៃលែង ចំពោះសមាគមមិត្តសាលាបាលីដែលផ្តើមធ្វើការកុសលដូច្នេះជាច្រើនឆ្នាំមកហើយដោយឥតរួញរា ប៉ុន្តែសមាគមដែលអាចធ្វើដូច្នេះបាន ដោយអាស្រ័យការឧបត្ថម្ភអំពីព្រះករុណាជាអម្ចាស់ជីវិតអំពីទ្រង់ ឯកឧត្តម នឹងឥស្សរជនទាំងឡាយ ព្រមទាំងពួកពុទ្ធបរិស័ទជួយដោយសទ្ធាជ្រះថ្លាផងដែរ ទើបអាចធ្វើកល្យាណកម្មនេះឲ្យសម្រេចបាន ។

សាលាបាលីជាន់ខ្ពស់សូមអរគុណចំពោះសមាគមមិត្តសាលាបាលីជាច្រើនអនេក ដោយឃើញថាសមាគមនេះបានបំពេញកិច្ចដ៏ប្រសើរច្រើនយ៉ាង ដែលជាកិច្ចជួយឲ្យកម្លាំងដល់ការសិក្សាវិជ្ជាព្រះពុទ្ធសាសនា មានការចែកវត្ថុសម្រាប់សិក្សាដល់សាលាបាលីរងជាង ៤០០ សាលាក្នុងព្រះរាជាណាចក្រកម្ពុជាផង ជួយផ្តើមធ្វើបុណ្យចែកព្រហ្មទានដល់សិស្សក្នុងសាលាបាលីជាន់ខ្ពស់រាល់ឆ្នាំផង មិនតែប៉ុណ្ណោះ ឆ្លៀតឱកាសជួយឧបត្ថម្ភក្នុងការចាត់ព្រះសង្ឃជានិស្សិតចេញពីសាលានេះ ឲ្យទៅបន្ត

ការសិក្សាក្នុងប្រទេសក្រៅផងទៀត ដូចកាលពីថ្ងៃសុក្រទី ៤ មីនានេះ មាននិស្សិត ៣ រូបបានចេញទៅបន្តការសិក្សាក្នុងវិជ្ជាស្ថានបាលី នៅនាលន្ទាប្រទេសឥណ្ឌា, ការចាត់ឲ្យទៅសិក្សានេះជាបន្ទុកនៃសមាគមមិត្តសាលាបាលី ។

គតិនេះ សូមរំលឹកប្រស្រ័យដល់ព្រះសង្ឃ ជានិស្សិតនៃសាលានេះ

អស់លោកជានិស្សិតទាំងឡាយ! ការសិក្សារៀនសូត្រចំណេះវិជ្ជាគ្រប់ប្រភេទក្នុងលោកនេះ រមែងដឹកនាំមនុស្សជាតិទីងពិភពលោកឲ្យមានការប្រែប្រួល ត្រឡប់ពីអាក្រក់ទៅល្អ ពីឋានៈថយថោកទៅកាន់ឋានៈដ៏ខ្ពង់ខ្ពស់ ពីការល្ងង់ខ្លៅទៅកាន់ការចេះដឹង ដូចយើងបានឃើញនឹងភ្នែកស្រាប់ហើយ, សេចក្តីចំរើន សេចក្តីចំរើនរុងរឿងជាផលបានមកអំពីចំណេះវិជ្ជាៗ បានមកអំពីការសិក្សារៀនសូត្ររបស់មនុស្សក្នុងលោក ។ បណ្តាចំណេះវិជ្ជាទាំងនោះ ការសិក្សាព្រះបរិយត្តិធម៌ នឹងការសិក្សាវិជ្ជាផ្សេងៗ ក្នុងសាលាបាលីជាន់ខ្ពស់នេះមានវិទ្យាសាស្ត្រ បវត្តិសាស្ត្រ គណិតសាស្ត្រ នឹងភូមិសាស្ត្រជាដើម អាចរាប់បញ្ចូលទៅក្នុងចំណេះវិជ្ជាផ្នែក ១ ក្នុងលោកបានដែរ បើចំពោះប្រទេសកម្ពុជាយើងនេះ ជនជាតិខ្មែរយើង ក្នុងអតីតកាលបានធ្លាប់និយមរាប់អានថាជាចំណេះវិជ្ជាជាន់ខ្ពស់បំផុតរបស់ជាតិព្រោះគោលចារិកសំខាន់ៗ នៃវប្បធម៌ខ្មែរមានអក្សរសាស្ត្រជាដើម តាំងពីសម័យបុរាណរហូតមកដល់សម័យបច្ចុប្បន្ននេះ រមែងពឹងផ្អែកទៅលើព្រះពុទ្ធសាសនាស្ទើរតែទាំងអស់ ។

អស់លោកជាសិស្សទាំងឡាយ! អស់លោកដែលបានប្រឡងចេញ

ពីសាលាហើយ ទុកជាចប់កិច្ចរបស់លោកក្នុងសាលានេះហើយ ប៉ុន្តែ សូមកុំឲ្យគ័ន្ធប្រចាំថា "កិច្ចសិក្សាចំណេះវិជ្ជាចប់ស្រេច ត្រឹមបានទទួលសញ្ញាប័ត្រពីសាលានេះ" ដូច្នេះឡើយ ហើយបោះបង់គំនិត ក្នុងការសិក្សាតទៅទៀត ។ រីឯការសិក្សាក្នុងសាលាបាលីជាន់ខ្ពស់នេះ កាលបើយកទៅប្រៀបផ្ទឹម នឹងការសិក្សាក្នុងសាលារៀនខាងព្រះពុទ្ធសាសនា នៅប្រទេសឯទៀត នៅអន់ថយច្រើនជាងគេ ។ ដូចប្រទេសដែលមានព្រះពុទ្ធសាសនាដូចប្រទេសយើងសព្វថ្ងៃនេះ គឺប្រទេសថៃ, ភូមា, និងសេរីលង្កា គេបានបង្កើតមហាវិទ្យាល័យ ទីងវិទ្យាល័យខាងព្រះពុទ្ធសាសនាឲ្យមានឡើងជាយូរឆ្នាំមកហើយ ព្រោះប្រទេសទាំងនោះមានឧត្តមគតិដ៏ប្រសើរ ១ យ៉ាង គឺចង់ឲ្យព្រះសង្ឃបានចេះដឹងវិជ្ជាខាងផ្លូវលោកនឹងផ្លូវធម៌ឲ្យមាំមួន ព្រមទាំងភាសាបរទេសផង កាលបើព្រះសង្ឃបានចេះដឹងហើយ នឹងបញ្ជូនព្រះសង្ឃទាំងនោះទៅកាន់នានាប្រទេស នឹងប្រកាសពីព្រះពុទ្ធសាសនា ដើម្បីឲ្យប្រទេសទាំងនោះបានស្គាល់នូវព្រះពុទ្ធសាសនាយ៉ាងជាក់ច្បាស់ ។

សព្វថ្ងៃនេះ ប្រទេសលង្កាក៏កំពុងបាត់ព្រះសង្ឃចេញទៅកាន់ប្រទេសផ្សេង ៗ, ប្រទេសភូមាក៏កំពុងខំប្រឹងបង្កើតវិទ្យាល័យធម្មទូតសម្រាប់ព្រះសង្ឃរៀនសូត្រ ។ ក្នុងវិទ្យាល័យធម្មទូតនៅប្រទេសភូមានោះ សព្វថ្ងៃនេះ មានព្រះសង្ឃខ្មែរជានិស្សិតនៃសាលានេះចំនួន ១១ រូប បានចូលទៅសិក្សារួមជាមួយនឹងព្រះសង្ឃភូមា បានចេះភាសាភូមានឹងភាសាអង់គ្លេសយ៉ាងមធ្យមហើយ, គោលបំណងនៃពុទ្ធសាសនសកា

នៅប្រទេសភូមាដែលមានរដ្ឋាភិបាលជួយឧបត្ថម្ភ ព្រោះថាទីណែព្រះសង្ឃដែលរៀនក្នុងវិទ្យាល័យនោះ មានវិជ្ជាគ្រប់គ្រាន់ ល្មមធ្វើជាធម្មទូតចេញទៅប្រកាសព្រះពុទ្ធសាសនាក្នុងនានាប្រទេសបាន ។

កុំថាច់ពោលចំពោះប្រទេសដែលមានព្រះពុទ្ធសាសនា យ៉ាងបរិបូណ៌ ដូចប្រទេសថៃ, ភូមា ទីងលង្កាដូច្នោះឡើយ សូម្បីតែប្រទេសឥណ្ឌាដែលក្នុងសម័យនេះ មានអ្នកកាន់ព្រះពុទ្ធសាសនាមានចំនួនតិច មានពួកបព្វជិតត្រឹម ២០ ឬ ៣០ រូបប៉ុណ្ណោះ ក៏គេបានបង្កើតវិជ្ជាស្ថានខាងព្រះពុទ្ធសាសនា ១ នៅនាលន្ទា មានភិក្ខុ ១ រូបឈ្មោះកស្សប ជាអធិបតី អាចណែនាំជនអ៊ីរ៉ុបឲ្យបួលបួសបានខ្លះ; វិជ្ជាស្ថាននោះ គេប្រុងនឹងរៀបចំឲ្យទៅជាមហាវិទ្យាល័យខាងព្រះពុទ្ធសាសនាក្នុងពេលយ៉ាងខ្លីខាងមុខនេះ ។ សព្វថ្ងៃនេះ គេបានផ្សាយដំណឹងទៅក្នុងលោកថា បើមានអ្នកណាទៅសិក្សាក្នុងសាលានោះ គេនឹងជួយឧបត្ថម្ភដោយអាហារូបករណ៍ផងទៀត ។ សាលានៅនាលន្ទានោះហើយ ដែលសិស្សសាលាយើងនេះចំនួន ៣ រូបចេញទៅសិក្សាពីថ្ងៃមុនក្រោមនោះក្នុងសេចក្តីឧបត្ថម្ភនៃសមាគមមិត្តសាលាបាលី ។

តាមដំណឹងពីភិក្ខុកស្សប ជាអធិបតីនៃវិជ្ជាស្ថាននោះថា សាលាសិក្សាព្រះពុទ្ធសាសនានោះ រដ្ឋាភិបាលប្រទេសឥណ្ឌាដែលមានលោកបណ្ឌិតណេរូ ជាប្រមុខជួយឧបត្ថម្ភ ។ ឯរដ្ឋាភិបាលឥណ្ឌាមិនមែនជាក្រុមអ្នកកាន់ព្រះពុទ្ធសាសនាទេ តែជួយឧបត្ថម្ភក្នុងឋានៈជាអ្នកគ្រប់គ្រងកិច្ចការក្នុងប្រទេស ។

ចំណែកខាងប្រទេសយើងវិញ សម័យបច្ចុប្បន្ននេះ ព្រះករុណាជាអម្ចាស់ជីវិតព្រះបាទសម្តេចព្រះនរោត្តម-សីហនុ វរ្ម័ន ទ្រង់ជាអគ្គសាសនូបត្ថម្ភក៍ ទ្រង់សព្វព្រះរាជហឫទ័យបង់ឲ្យការសិក្សាក្នុងព្រះពុទ្ធសាសនាមានដំណើរលឿនទៅមុខ ឲ្យសមតាមកាលៈទេសៈ ដើម្បីកុំឲ្យអន់ថយជាងប្រទេសនានា ដែលកាន់ព្រះពុទ្ធសាសនាដូចគ្នា ទើបទ្រង់មានព្រះរាជបញ្ជាឲ្យក្រសួងធម្មការ (កាលឯកឧត្តម សម-ញាណ ជារដ្ឋមន្ត្រី) បាត់ការពិនិត្យ ព្រមទាំងរៀបចំការសិក្សាខាងព្រះពុទ្ធសាសនា ឲ្យមានសេចក្តីចំរើនឡើងដូចប្រទេសជិតខាង ។ ក្រសួងធម្មការក៏បានបាត់ការរៀបចំកែប្រែការសិក្សាក្នុងសាលាបាលីជាន់ខ្ពស់ ព្រមទាំងបង្កើតឲ្យមានការសិក្សាជាន់ខ្ពស់ឡើងទៀត គឺបង្កើតឲ្យមានមហាវិទ្យាល័យ ខាងព្រះពុទ្ធសាសនា មានឈ្មោះថា ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ។ មហាវិទ្យាល័យនេះ កើតឡើងដោយព្រះរាជក្រមលេខ ៨៧៩ ន. ស. ចុះថ្ងៃទី ១ កក្កដា ១៩៥៤ ។

មហាវិទ្យាល័យនេះ សព្វថ្ងៃពុំទាន់បានបើកទ្វារបញ្ចូលសិស្សឲ្យរៀននៅឡើយទេ ដោយមានការរៀបចំពុំទាន់ហើយស្រេច ។ ព្រះករុណាជាអម្ចាស់ជីវិត កាលក្រោយដែលទ្រង់លាលះរាជសម្បត្តិហើយបាន ២-៣ ថ្ងៃ ទ្រង់នៅមានព្រះរាជហឫទ័យប្រារព្ធមកលើពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជនេះឲ្យមានដំណើរទៅមុខ ទើបទ្រង់ប្រោសព្រះរាជទានប្រាក់ ១ លាន ៥ សែនរៀល ក្នុងការកសាងគ្រឹះស្ថានឲ្យបានគ្រប់គ្រាន់ ។ ឯគ្រឹះស្ថានដែលកំពុងសង់សព្វថ្ងៃ គឺឧបាសក បេ-យាង

អ្នកដំនួញមានសទ្ធាជ្រះថ្លាចំណាយធនធានរបស់ខ្លួនកសាង ដើម្បីឧទ្ទិសចំពោះព្រះពុទ្ធសាសនា ជូនដល់ព្រះរាជរដ្ឋាភិបាលឲ្យចាត់ចែងជាកន្លែងសិក្សានៃពុទ្ធិកមហាវិទ្យាល័យតទៅ ។

មហាវិទ្យាល័យនេះហើយ ដែលបម្រុងខ្លួនទទួលអស់លោកជានិស្សិតទាំងឡាយ ដែលចេញពីសាលានេះឲ្យសិក្សាតទៅទៀត ។ ដូច្នេះ សុំឲ្យអស់លោកទាំងឡាយតាំងចិត្តព្យាយាមឲ្យមាំមួន ក្នុងការបន្តកិច្ចសិក្សាទៅទៀត ។ សុំឲ្យអស់លោកតាំងចិត្តអាណិតខ្លួន កុំឲ្យខ្លួនអន់ថយដោយចំណេះវិជ្ជា, អាណិតព្រះពុទ្ធសាសនា កុំឲ្យព្រះពុទ្ធសាសនាទន់ខ្សោយ ដោយខ្វះខាតអ្នកចេះដឹង, អាណិតប្រទេសជាតិ កុំឲ្យប្រទេសជាតិខ្វះខាតបណ្ឌិតដែលមានចំណេះវិជ្ជាច្រើន ។ សុំឲ្យអស់លោកទាំងឡាយតាំងចិត្តអធិដ្ឋានដំកល់ព្យាយាម ឲ្យរឹងប៉ឹងក្នុងការសិក្សាវិជ្ជាផ្លូវសាសនា និងផ្លូវលោកតទៅទៀត ឲ្យត្រាតែបានសម្រេច កុំអាលបោះបង់ចោលការសិក្សាទៅមុខ ត្រូវយកតម្រាប់តាមព្រះបរមគ្រូនៃយើង កាលដែលព្រះអង្គនៅជាព្រះបរមពោធិសត្វមាននាមថា មហាជនកៈ ព្រះអង្គបានស្រែកប្រកាសក្នុងមហាសមុទ្រចំពោះទេវតាថា "កើតមកជាកូនប្រុស ត្រូវតែខំព្យាយាមត្រាតែបានសម្រេចប្រយោជន៍ "។

អស់លោកជាសិស្សទាំងឡាយ ! ខ្ញុំសូមរំលឹកជាថ្មីម្តងទៀត សូមលោកជាសិស្សទាំងឡាយ កុំបីមានគំនិតគិតថា ការជ្រោមជ្រែងព្រះពុទ្ធសាសនា ឲ្យចំរើនរុងរឿងឲ្យធំទូលាយឡើង ទុកឲ្យអស់លោក

ឯទៀតៗ ចុះ ប្រសិនបើគិតដូច្នេះតែទាំងអស់គ្នា តើបព្វជិតរូបណានឹងនៅ ទ្រទ្រង់ព្រះពុទ្ធសាសនាទៅមុខ? ព្រោះព្រះពុទ្ធសាសនាក្នុងអនាគត មានសង្ឃឹមជាយច្រើន ចំពោះលើអស់លោកជានិស្សិតភិក្ខុបព្វជិត ជាអ្នករៀនសូត្រ បានចេះដឹងវិជ្ជាខាងព្រះពុទ្ធសាសនាទាំងនេះហើយ,ព្រោះ បព្វជិតទោះបីមានចំនួនច្រើនរាប់ពាន់រាប់ហ៊ឺន ប៉ុន្តែបើឥតមានចំណេះវិជ្ជា ឥតមានសណ្ដាប់ធ្នាប់ល្អ ឥតមានការប្រព្រឹត្តត្រឹមត្រូវ ឥតមានការៈរាងវៃ ជាបព្វជិតពុំសូវមានតម្លៃ មិនគួរដល់ការទទួលយកនូវសេចក្ដីគោរពរាប់ អានអំពីមហាជន, តើបព្វជិតទាំងនោះឬ ដែលអាចជួយជ្រោមជ្រែង ព្រះពុទ្ធសាសនាក្នុងអនាគត? ឃើញថាជួយជ្រោមជ្រែងពុំកើតទេ ។

ហេតុនេះ សុំឲ្យអស់លោកជានិស្សិតទាំងឡាយ ខំគិតរំពឹងពិចារ-ណាឲ្យវែងឆ្ងាយ, ធ្វើចិត្តឲ្យធ្ងន់ឲ្យនឹងធឹងហើយខំសិក្សាចំណេះវិជ្ជាឲ្យ បានចេះដឹង ឲ្យបានសមល្មមជាទីពឹងជាបង្អែកនៃពុទ្ធសាសនិកជនទូទៅ ។

ក្នុងអវសានកថានេះ អាត្មាភាពសូមសំបូងស្រ្បឹងគុណព្រះស្រីរតនត្រ័យ សូមឲ្យជួយអភិបាលរក្សាព្រះករុណា ជាអម្ចាស់ជីវិត សូមព្រះអង្គបានប្រកបដោយជោគជ័យសុវត្ថិមង្គលគ្រប់ប្រការ សូមបានប្រកបដោយព្រះជន្មាយុយឺនយូរ សព្វកាលជាអង្វែង, ទាំងសម្ដេច, ទ្រង់, ឯកឧត្តម, ព្រះតេជព្រះគុណនូវអស់លោក អ្នកទាំងឡាយជាពុទ្ធ-បរិស័ទទូទៅ ក៏សូមឲ្យបានប្រកបដោយសេចក្ដីសុខសេចក្ដីចំរើន អស់កាលជានិរន្តរ៍កុំបីអាក់ខានឡើយ ៗ

# ពិធីបុណ្យបូជាសពលោកគ្រូ ចិន-ធិត

ចៅអធិការវត្តបឹងវៃ ឃុំក្រោលគោ ខេត្រស្វាយរៀង

## លោក ញ៉ែម-ខឹម

### លេខាធិការនៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

---

កាលពីថ្ងៃ ១-២-៣ រោច ខែផល្គុន ឆ្នាំមមីឆស័ក ព.ស. ២៤៩៧ ត្រូវនឹងថ្ងៃទី ៩-១០-១១ មីនា ១៩៥៥ មានធ្វើពិធីបុណ្យបូជាសពលោកគ្រូ ចិន-ទិត ជាចៅអធិការវត្តបឹងវៃ ឃុំក្រោលគោ ខេត្រស្វាយរៀង ដែលអនិច្ចធម្មពីថ្ងៃ ៣ កើតខែអស្សុជឆ្នាំមមីឆស័ក ព.ស ២៤៩៧ ក្រោមអធិបតីភាពនៃព្រះតេជព្រះគុណព្រះឧបាលិវង្ស សូរ-ហាយ វត្តឧណ្ណាលោម ភ្នំពេញ ។

ពិធីបុណ្យនេះ មានបាត់ជាគណៈកម្មការ ៧ ក្រុម ដើម្បីជាការស្រួលក្នុងកិច្ចកុសលដ៏ធំនេះ គឺគណៈកម្មការផ្គត់ផ្គង់ទឹក ១ គណៈកម្មការភោជន ១ គណៈកម្មការភេសជ្ជៈ ១ គណៈកម្មការអុជបង្កៀង ១ គណៈកម្មការទទួលភ្ញៀវគ្រហស្ថ ១ គណៈកម្មការទទួលភ្ញៀវព្រះសង្ឃ ១ គណៈកម្មការអគ្គានុភ័យ ១ ។ ក្នុងគណៈកម្មការមួយៗ មានសមាជិក ៥ នាក់ខ្លះ, ១០ នាក់ខ្លះ, ១៥ នាក់ខ្លះ ។

ខ្ញុំជាសិស្សម្នាក់ នៃលោកគ្រូព្រះសពអង្គនេះ ប៉ុន្តែខ្ញុំនៅរៀនសូត្រឯក្រុងភ្នំពេញ បានទៅធ្វើបុណ្យនោះដែរ ។ កាលខ្ញុំចុះពីរថយន្តភ្លាមក៏ដើរចូលទៅក្នុងវត្តក្រោមកំដៅនៃព្រះអាទិត្យ បានឃើញក្លោងទ្វារ

វត្តរចនាដោយស្ទីករុក្ខជាតិផ្សេងៗ  មានផ្ទាំងសំពត់សស្គុសសន្ធឹងពីលើ ស៊ុមស្ទីកឈើ ចារឹកដោយអក្សរធំៗថា បុណ្យបូជាព្រះសពព្រះនាម បិន-ទិត ។ នៅអមក្លោងទ្វារនោះ មានទង់ជាតិនិងទង់ពុទ្ធសាសនា កំពុងតែបក់រវិចៗ រកគ្នាតាមដំនោរខ្យល់បក់ ហាក់ដូចជាឲ្យសញ្ញា ដល់អ្នកមកបុណ្យថា "ប្អូនយើងបំពេញសេចក្ដីល្អឲ្យហើយ ទាន់មានជីវភាពទៅឡើយ, យើងកុំសប្បាយ ក្នុងផ្លូវកាមគុណពេក, យើងកុំភ្លេចព្រះពុទ្ធសាសនា!" ។

នៅក្បែរខាងផ្លូវចូលទៅវត្ត មានពានតូចៗ អមផ្លូវរៀបតម្រង់ជួរគួរឲ្យល្អមើលណាស់ ។ ពួកពាននេះជាកន្លែងលក់ដូររបស់អ្នកជំនួញខ្មែរ ដែលកំពុងរៀនរកស៊ីលក់ដូរ នាំគ្នាអង្គុយរហាន់លក់នំចំណីទឹកកក ទឹកក្រូចជាដើម ។

បន្ទាប់ពីនោះមក ខ្ញុំក៏ដើរចូលបន្តិចម្ដងៗ ដល់ទៅក្នុងវត្ត ដោយសេចក្ដីគោរព និងសេចក្ដីរីករាយចំពោះបុណ្យជាអនេក ព្រោះឃើញទីវត្តស្អាតល្អ ទាំងការរៀបចំកំប្លែកអស្ចារ្យ, មនុស្សប្រុសស្រីតូចធំត្រៀបត្រាមីដើរដាស ។ នៅគ្រប់មាត់ទ្វារកុដិនិងពេទបុណ្យ សុទ្ធតែប្រដាប់ដោយទង់ជាតិ, ទង់ព្រះពុទ្ធសាសនា, ផ្កាភ្ញីនិងស្ទីករុក្ខជាតិ ដែលគេចងស្រោបគ្រប់សសរបាកំកំពូលនិងពេទបុណ្យ មានពណ៌ខៀវស្រឆាត់ជាលំអគួរឲ្យស្បែនៃប្រជាជន ។ នៅទិសទាំង ៨ នៃវត្តបឹងរៃនេះ សុទ្ធតែមានផ្ទាំងសំពត់បិទអក្សរធំៗ ដែលជាពុទ្ធភាសិតយ៉ាងពីរោះៗ ។

ការរៀបចំបុណ្យបូជាព្រះសពនេះ មានរបៀបល្អណាស់ជាងទីឯទៀតដែលខ្ញុំធ្លាប់បានឃើញ ។ លំអភាពដោយការរៀបចំនេះ ជាទស្សនីយភាពនៃខ្ញុំដោយឡែកហើយ ប៉ុន្តែពុំមែននាំឲ្យខ្ញុំប្លែកចិត្តនឹកស្ងើចប៉ុន្មានទេ គឺនៅមានទស្សនីយភាពដែលនាំឲ្យខ្ញុំចង់មើលហើយចង់មើលទៀតនោះ គឺបាក់កំពូល ( ទីបូជាព្រះសព ) នឹងក្ដារមឈូស ។ ព្រោះបាក់កំពូលសង់ក្នុងទីធ្លាធំខាងត្បូងឧបដ្ឋានសាលា មានលំអប្លែកអស្ចារ្យណាស់ ទាំងក្ដារមឈូសក៏ល្អត្រកាលដោយបិទក្បាច់រលេចរចនាផ្កាភ្ញី អំពីក្រដាសទឹកមាសចាំងពណ៌ផ្លេក ៗ ទាំងគំរបក្ដារមឈូសក៏រលេចដោយផ្កាឈើច្រើនពណ៌ មានក្លិនក្រអូបឈ្ងុយឈ្ងប់គួរជាទីមនោរម្យ ដែលបង្កើតខ្ពស់ត្រដែតនៅក្នុងបាក់កំពូល ។ លំអដ៏ឆើតឆាយនៃបាក់កំពូលនឹងក្ដារមឈូសនេះកើតឡើងដោយស្នាដៃនៃជាង ស៊ុម នឹងជាង ជា ជាឧបាសកវត្តនិពេធរង្សី ឃុំច្បារអំពៅ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។ បណ្ដាជនដែលបានមកទស្សនាបុណ្យនេះ ច្រើនតែលាន់មាត់សរសើរថា " បាក់កំពូលនឹងក្ដារមឈូសនេះចំជាល្អរុងរឿងមែន " ។ បាក់កំពូលនោះ មានកំពស់ប្រមាណ ១២ ម៉ែត្រ, មានទំពទាយសារពើសូត្រនៃបាក់នោះ ៨ ម៉ែត្រ ៤ ជ្រុង សុទ្ធតែធ្វើអំពីសំពត់ទេសឯក, មានក្លោងទ្វារ ៤, មានសំពត់បាំងសែន ៤, មានសន្ទិយាក៏ ៤ ដែរ ។ សំពត់ទាំងអស់សុទ្ធតែមានពយផ្កាយ នឹងជរពណ៌មាស, នៅវេលាយប់មានរលេចដោយភ្លើងអគ្គិសនី ដាក់អំពូលតូច ៗ មានពណ៌ ៥ ព័ទ្ធជុំវិញក្ដារមឈូសនឹងបាក់កំពូល ភ្លឺផ្លុះចាំងចិញ្ចាច ។

ម៉ោង ៩ យប់នៃថ្ងៃចូលបុណ្យគឺថ្ងៃ ១ កើតខែផល្គុន ពួកឧបាសកឧបាសិកានាំគ្នានមស្ការព្រះរតនត្រ័យ, សមាទានសីល, និមន្តព្រះសង្ឃចំរើនព្រះបរិត្ត រួចនិមន្តព្រះតេជព្រះគុណព្រះមុនីកោសល វត្តនិពេធរង្សី មេគណខេត្តកណ្តាល ទេសនាធម្មគោរពទីងមបម ត្រាស់តាមប្រពៃណីនិយម ។ សំឡេងដែលធ្លាប់តែឮអ៊ូអរក្នុងពេលមុនទេសនា លុះដល់ពេលទេសនា ស្រាប់តែស្ងប់ស្ងាត់ឈឹងដោយពុទ្ធបរិស័ទគោរពស្តាប់ធម៌ផង គោរពចំពោះវិញ្ញាណក្ខន្ធនៃព្រះសពផង ។

លុះស្អែកឡើងជាថ្ងៃ ២ កើតខែផល្គុន ពុទ្ធបរិស័ទជិតឆ្ងាយក៏ប្រមូលគ្នាចាត់ចែងយាគូប្រគេនព្រះសង្ឃក្នុងវេលាព្រឹក, លុះដល់ថ្ងៃត្រង់វេរចង្ហាន់សង្ឃទៀត ។ ប៉ុន្តែថ្ងៃ ២ កើតនេះ មានពួកឧបាសកឧបាសិកាកាន់តែច្រើនណាស់លើសពីថ្ងៃមុន ព្រោះក្នុងវេលារាត្រីនៃថ្ងៃ ២ កើតនោះ ត្រូវទេសនាសង្គាយនាត្រៃ ៣ លុះចប់ហើយទើបធ្វើឈាបនកិច្ចបូជាសពជាក្រោយ ។ មុននឹងទេសនាសង្គាយនា ព្រះតេជព្រះគុណព្រះឧបាលិវង្ស ស៊ូរ - ហាយ ថ្លែងសុន្ទរកថាមួយក្នុងកណ្តាលពុទ្ធបរិស័ទរាប់ពាន់ ពណ៌នាអំពីគុណសម្បត្តិលោកគ្រូព្រះសព ចិន - ទិត ព្រមទាំងថ្លែងទទួលអំណរគុណពុទ្ធបរិស័ទដែលជួយឧបត្ថម្ភក្នុងការកុសលនេះ ។

លុះព្រឹកឡើងថ្ងៃ ៣ កើតក៏មានការប្រគេនយាគូចំពោះព្រះសង្ឃ ថ្ងៃត្រង់វេរភត្តឧទ្ទិសផល ប្រគេនចំពោះវិញ្ញាណក្ខន្ធលោកគ្រូព្រះសព ចិន - ទិត, ព្រមទាំងប្រគេនទេយ្យទានមានសៀវភៅធម៌នឹងចីវរជាដើម

ចំពោះព្រះសង្ឃ ៦៤ អង្គ តាមជន្មាយុនៃព្រះសព រួចធ្វើបុណ្យ
បង្ហើយកុនថ្ងៃ ៣ ពេលនោះ ។

## សុន្ទរកថា

## ព្រះឧបាលិវង្ស ប៉ែង

ព្រះតេជព្រះគុណមេគណ, ព្រះថេរានុត្ថេរៈទាំងឡាយ !
លោកចៅហ្វាយស្រុក ព្រមទាំងអស់លោកជាសហការី !
លោក-អ្នកសប្បុរស ពុទ្ធបរិស័ទទាំងឡាយ !

ពេលឱកាសនេះជាពេលដែលខ្ញុំព្រះករុណា អាត្មាភាពនិងពុទ្ធបរិស័ទ ជាសិស្សានុសិស្សនៃព្រះសព ផ្តើមធ្វើបុណ្យបូជាសពនៃលោកគ្រូចៅអធិការវត្តបឹងរ៉ៃនេះ តាមប្រពៃណីរបស់ពុទ្ធសាសនិកជន ។

នៅពេលរៀបចំពិធីបូជាសពនេះ បានបួលបុណ្យកន្លងមកមួយយប់ហើយ ។ ក្នុងវេលាយប់ទីពីរនេះ និងបូជាព្រះសពព្រមទាំងទេសនាសង្គាយនា ។ ឥឡូវនេះ ព្រះតេជព្រះគុណមេគណនិងលោកចៅហ្វាយស្រុក, អស់លោកជាសហការី បានឆ្លៀតពេលឱកាសល្អ និមន្ត-អញ្ជើញមកជួយបំពេញកិច្ចបុណ្យ ដើម្បីជាកិត្តិយសនៃបុណ្យផង ដើម្បីសំដែងមិត្តភាព សាមគ្គីភាពក្នុងរវាងប្រជាជននិងលោក-អ្នករាជការផង ដែលតែងតែប្រស្រ័យទាក់ទងគ្នាឲ្យជិតស្និទ្ធ តាំងពីព្រេងនាយមកហើយ ។ វេលានក្ខត្តឫក្ស រាត្រីទីពីរនេះ ខ្ញុំព្រះករុណា-អាត្មាភាពសូមថ្លែងវិយោគ (ការព្រាត់ប្រាស) និងការទទួលអំណរគុណនាមនៃពុទ្ធបរិស័ទ ចំពោះ

លោកទៅហើយ ទើបអស់លោក-អ្នកទាំងឡាយ ដូចសេចក្ដីរៀបរាប់តទៅនេះ ៖

លោកគ្រូព្រះសពព្រះនាមចិន-ទិតនេះជាបព្វជិតមួយរូបដែលមានសំវរធម៌ គឺការសង្រួមឥន្ទ្រិយល្អហ្មត់ចត់ណាស់ ទាំងមានការពេញចិត្តក្នុងកិច្ចសិក្សាធម៌វិន័យក៏យូរឆ្នាំណាស់ហើយ ប៉ុន្តែពេលនេះពុំបានថ្លែងថេរប្បវត្តិរបស់លោកទៀតទេ ព្រោះមានថ្លែងពីយប់ ១ ពេល ម្ដងរួចហើយ ។

លោកគ្រូព្រះនាមចិន-ទិត អង្គនេះ ជាព្រះថេរៈ ស្រគត់ស្រគំ ពុំសូវមានមាត់ពាក្យច្រើនខ្លាំងទេ មានពុទ្ធដីកាតិចៗ ជាលក្ខណៈវាចារបស់អ្នកកាន់វិន័យ ប៉ុន្តែរបៀបតម្រង់ពាក្យរបស់លោក មានប្រយោគប្រធានរៀបរៀងត្រូវតាមអក្ខរាវិរុទ្ធមានដើមចុងល្អណាស់, មានពុទ្ធដីកាសុទ្ធតែវាចាពិតវាចាមែន មិនដែលនិយាយលេងសើចឡេះឡោះទេ ៗ ព្រះថេរៈអង្គនេះមានព្រះច័យធ្ងន់ គំនិតជ្រៅ ឃើញកាលវែង តាមដែលខ្ញុំព្រះករុណា-អាត្មាភាព បានសន្ទនាជាមួយនឹងលោកអំពីហេតុការណ៍ផ្លូវលោកផ្លូវធម៌ជារឿយៗ ។ លោកចេះមានពុទ្ធដីកាត្រូវច្រើនដង ច្រើនកន្លែងណាស់ដោយគំនិតលោកមានស្រាប់ ។ កាលពីគ្រិស្តសករាជ ១៩៣៣ គឺឆ្នាំដែលខ្ញុំព្រះករុណាអាត្មាភាពប្រឡងចេញពីសាលាបាលីជាន់ខ្ពស់ ហើយបានមកឯវត្ត ជួបនឹងលោកក៏លោកមានវាចាសាកសួរអំពីការប្រឡងចេញ លុះខ្ញុំព្រះករុណា-អាត្មាភាព ពិតលោកតាមដំណើរនៃការប្រឡងហើយ លោកក៏អរណាស់ហើយមានថេរដីកាថា "លោក!

ខ្ញុំសង្ឃឹមលោកណាស់ អំណើះតទៅលោកនឹងបានជាមុខជាមាត់ជាចន្លល់នៃព្រះពុទ្ធសាសនាមួយរូប ខ្ញុំនឹកសង្ឃឹមលើលោកហើយ, លោកនៅបំរើព្រះពុទ្ធសាសនា ទាំងភេទបព្វជិតអីចឹងហើយ កុំសឹកទៅបំរើកាមគុណឲ្យសោះ ឯខ្លួនខ្ញុំទោះបីជាបព្វជិតល្ងង់ខ្លៅមែន ប៉ុន្តែជាតិនេះខ្ញុំមិនត្រូវការទៅបំរើកាមគុណទេ ខ្ញុំស៊ូនៅប្រគល់កាយថ្វាយខ្លួនបំរើព្រះសាសនាអស់មួយជីវិតហើយ " ។ ថេរគាថានេះជាគាថាប្រសើរបំផុតត្រូវល្អណាស់ ។ សង្កេតអំពីបវត្តិការណ៍របស់លោក ឃើញថាលោកមានការប្រតិបត្តិធម៌វិន័យត្រឹមត្រូវពិតមែន ។ ព្រះថេរៈព្រះនាម ចិន ទិត មានជីវភាពស៊ូនៅបំរើព្រះសាសនា ទាំងភេទបព្វជិតទាល់តែស្លាប់ក្រោមទង់ជ័យនៃព្រះពុទ្ធសាសនា; ទាហានពិជ័យសង្គ្រាមដែលលើកទ័ពទៅតទល់នឹងសត្រូវហើយ ចេះតែលុកចូលរុលទៅមុខមិនព្រមថយក្រោយ ស៊ូស្លាប់ក្នុងកណ្ដាលសមរភូមិបានយ៉ាងណា ព្រះថេរៈអង្គនេះក៏តស៊ូនឹងមច្ចុសង្គ្រាមនៅក្នុងភេទបព្វជិតពុទ្ធសាសនា មិនរួញរាថយក្រោយ ចេះតែលុកចូលទៅមុខទាល់តែស្លាប់ក្នុងទីសមរភូមិពុទ្ធសាសនា យ៉ាងនោះដែរ ។

បពិត្រព្រះសព ! ក្រោយកាយតាំងមូលរបស់ព្រះសព នៅក្នុងក្ដាម្ឈូសដែលជាងរចនាដ៏ប្រសើរ. ប៉ាក់កំពូលក៏រចនាដ៏វិចិត្រត្រកាលល្អអស្ចារ្យណាស់ នេះជាសេចក្ដីប្រឹងប្រែងរបស់ពុទ្ធបរិស័ទសិស្សគណដោយសេចក្ដីគោរពចំពោះព្រះសពដោយកតញ្ញូភាពនៃសិស្សានុសិស្ស។ ឥឡូវនេះ យើងខ្ញុំជាពុទ្ធបរិស័ទទាំងបព្វជិតទាំងគ្រហស្ថ តាំងកម្មវិធីបុណ្យ

បូជាព្រះសពពីរយប់បីថ្ងៃ នឹងបូជាក្នុងវេលានេះហើយ ។ ព្រះសពដែលបាននិមន្តទៅកាន់បរលោកនាយ សុំឲ្យបានសុខ សប្បាយចុះ សុំកុំមានព្រះទ័យព្រួយបារម្ភដល់យើងខ្ញុំឡើយ ។

ការងារក្នុងវត្តអារាមដែលព្រះសពបានគ្រោងទុកហើយ ដែលព្រះសពបានបំពេញសកម្មភាពទាំងប៉ុន្មាន យើងខ្ញុំទទួលធានាកាប់រងទាំងអស់ សុំកុំឲ្យព្រួយគំនិតគិតសារមកក្រោយវិញ សុំឲ្យព្រះសពគិតតែទៅមុខ ឲ្យបានសុខសួស្តី ចំរើនទៅចុះ ។

បពិត្រព្រះសព! វិយោគធម៌គឺសេចក្តីព្រាត់ប្រាសក្នុងរវាងព្រះសព នឹងពុទ្ធបរិស័ទសិស្សានុសិស្សនេះតែងមានជាធម្មតា ។ ការព្រាត់នេះជាទីបំផុតហើយ លែងបានជួប លែងបានឃើញគ្នាទៀតហើយ ។ ឱ! ព្រះសព! កាលបើមានជន្មាយុគង់នៅទៅក៏គ្មាននឹងបានសិស្សគណប្រគេនវត្ថុណាមួយ មានចីវរជាដើមដោយផ្ទាល់អង្គបានភ្លាមៗ ចុះបើទទួលអនិច្ចធម្មបាត់ឈឹងទៅហើយ តើនឹងអាចប្រគេនផ្ទាល់ដូចម្តេចកើត? ករណីនេះ មានតែផលនៃបុណ្យកុសលដែលយើងខ្ញុំបានបរិច្ចាគធ្វើបុណ្យពេលនេះ មានប្រដាប់បរិក្ខារ ត្រៃចីវរគ្រប់គ្រាន់ប្រគេនចំពោះព្រះសង្ឃ ២៨ វត្ត មានព្រះធម៌ទេសនាតាំងពីយប់ចូលបុណ្យ ដល់មកយប់នេះទេសនាសង្គាយនា ត្រៃបី ធ្ងន់សម្រេចនៅថ្ងៃស្អែកមួយពេលទៀត ។

ផលអាមិសទាន ធម្មទានទាំងនេះ យើងខ្ញុំសូមបង្អោនដោយគោរពឧទ្ទិសប្រគេនចំពោះទៅព្រះសព សូមព្រះសពទទួលអនុមោទនាយកនូវផលនៃកុសលកម្មនេះដោយបីតិសោមនស្សចុះ ហើយសូមព្រះសព

ប្រមើលមើលមកយើងខ្ញុំដែលនៅឋានអាយ ដោយការផ្សាយមេត្តាករុណាដល់យើងខ្ញុំជាពុទ្ធបរិស័ទ សិស្សគណឲ្យបានសុខសប្បាយចំរើនគ្រប់ៗគ្នា ។

នៅទីបំផុតនៃសុន្ទរកថានេះ សូមប្រកាសនូវអំណរគុណដ៏ឧឡារិកចំពោះព្រះតេជព្រះគុណមេគណៈ ចំពោះព្រះថេរានុត្ថេរៈគ្រប់អង្គ, ចំពោះលោកចៅហ្វាយ ព្រមទាំងអស់លោកអ្នកគ្រប់គ្នា ដែលបេះឆ្លៀតឱកាសនិមន្តអញ្ជើញមកជាអធិបតីជាកិត្តិយសនៃបុណ្យនេះ យើងខ្ញុំមានសេចក្តីត្រេកអរសោទរជាអនេក, សូមជូនបុណ្យកុសលនេះ ឲ្យបានសម្រេចដោយសេចក្តីសុខចំរើនតាំងពីវេលានេះតរៀងទៅ ។

កាលបើអស់លោកអ្នកសប្បុរសខាងគ្រហស្ថទាំងឡាយ មានចិត្តសុន្ទរកថាដូចថ្លែងមកនេះហើយ សូមបញ្ចេញនូវវាចាជាភស្តុតាងនៃត្រេកអរចំពោះអំណរថា សាធុ ឲ្យព្រមៗទៅហោង ។

## រស់ក៏គាប់ ងាប់ក៏គួរ

កើតមកជាអង្គប្រុសក្នុងលោក ត្រូវធ្វើឲ្យជាប្រយោជន៍ដល់ជាតិប្រទេសនិងសាសនា ល្មមជាទិដ្ឋានុគតិនៃជនខាងក្រោយយកតម្រាប់តាមដូច្នេះ ឈ្មោះថា រស់ក៏គាប់ ងាប់ក៏គួរ ។

បូរ - អ៊ុន

# បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី

## របស់ក្រសួងធម្មការ

(តមក)

---

សញ្ញាប័ត្រលេខ ៩៤៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូពត-គាត នាមឆាយា ឥន្ទជោត កើតឆ្នាំមមី អាយុ ៥៦ វស្សា ២៣ ជាចៅអធិការវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៤៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូអ៊ុយ-ម៉ក់ នាមឆាយា ឥន្ទបញ្ញា កើតឆ្នាំខាល អាយុ ២៤ វស្សា ៥ ជាគ្រូសូត្រឆ្វេង វត្តអំពិលបី ឃុំសំពេង ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៤៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូប៉ែន ប៉ុន នាមឆាយា ធម្មសរ កើតឆ្នាំម្សាញ់ អាយុ ៣៣ វស្សា ១៣ ជាចៅអធិការ វត្ត ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៤៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូសា-ភយ-តុញ នាមឆាយា ឥន្ទបញ្ញា កើតឆ្នាំកុរ អាយុ ២៧ វស្សា ៨ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៤៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូពេជ្រ-ជុំ នាមឆាយា ឥន្ទត្តេរ កើតឆ្នាំរកា អាយុ ៦៥ វស្សា ៤៥ ជាចៅអធិការវត្តទន្លាប់ ឃុំសឹង ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៤៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ

គង់-ជួន នាមឆាយា សុធម្មបញ្ញា កើតឆ្នាំមមី អាយុ ៥៦ វស្សា ៣៧ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៤៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គិម-សុខ នាមឆាយា ជោតគោ កើតឆ្នាំខាល អាយុ ២៤ វស្សា ៥ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៥០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុក-ម៉ម នាមឆាយា ធម្មគោ កើតឆ្នាំម្សាញ់ អាយុ ៥៦ វស្សា ១១ ជាចៅអធិការវត្តអង្គសូឃ្លាំង ឃុំដំរះពេន ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៥១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ហ៊ីង-ចក់ នាមឆាយា ឥន្ទគោ កើតឆ្នាំជូត អាយុ ៥០ វស្សា ២៩ ជាចៅអធិការ វត្តអង្គចង្អេរ ឃុំស្លា-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៥២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គារ-ញ៉ែម នាមឆាយា ធម្មជោត កើតឆ្នាំឆ្លូវ អាយុ ៤៩ វស្សា ២៩ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៥៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គារ-ស៊ុន នាមឆាយា ព្រហ្មគោ កើតឆ្នាំថោះ អាយុ ៤៧ វស្សា ២៧ ជាគ្រូសូត្រឆ្វេង-ឃុំ-ស្រុក-ខេត្តដដែល ។

(មានត)